ស.ប.ស.ខ
ាគមបុគ្គលិកសិក្សាខ្មែរ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

* ចំណងមិត្តភាពនិងការឧបត្ថម្ភគ្នាទៅវិញទៅមក
* ការពង្រឹងនិងពង្រីកចំណេះដឹង និង វិជ្ជាជីវៈ
* ការការពារផលប្រយោជន៍គ្នាទាំងផ្លូវចិត្ត - សម្ភារៈ

៥៦

# ទស្សនាវដ្តី គ្រូបង្រៀន




**សាលាបឋមសិក្សា ឆែប ខេត្តព្រះវិហារ**

**ត្រីមាសទី១ ឆ្នាំ២០១៩**

ផ្សាយចេញរាល់ត្រីមាសពីទីចាត់ការសមាគមបុគ្គលិកសិក្សាខ្មែរ
១២៨B មហាវិថីព្រះនរោត្តម (ភ្នំពេញ)
ទូរស័ព្ទ : ០២៣ ២១៦ ១៨៤_០១៧ ៤៨៨ ៨៧៦
Facebook: kta amcek

# មាតិកា


## គណៈកម្មការរៀបរៀង និង និពន្ធ

- លោក ជ័យ សយ្យនា
- លោក ថោង បូរ៉ាន់
- លោកស្រី គុយ ផល្លា
- លោក ជន ឈាងលី
- លោកស្រី ម៉ក់ ណាង
- លោក វង្ស សុគន្ធ
- លោក អ៊ុម ជា
- សមាជិកសមាជិកា ស. ប. ស.ខ

## គណៈកម្មការត្រួតពិនិត្យ

- លោក យស់ អ៊ាង
- លោកស្រី ប្រាក់ សូលីដា
- លោក ព្រុំ សាមិត
- លោក សួង សារុណា
- លោក ស៊ុង វ៉ាន់ថន
- លោក ស៊ិន ស៊ីម
- លោក លី ហាក់សេង

## ការីកុំព្យូទ័រ

លោកស្រី លី មីស្មៀល


## ក្របខាងក្រៅ

- ពីមុខ : សាលាបឋមសិក្សាឆែប ខេត្តព្រះវិហារ
- ពីក្រោយ : ប្រាសាទ និងព្រះសង្ឃ


| ល.រ | ចំណងជើងអត្ថបទ | ទំព័រ |
|---|---|---|
| ១ | វិចារណកថា | ១ |
| | **វប្បធម៌ទូទៅ** | |
| ២ | ប្រភពនៃការអប់រំក្នុងពិភពលោក (ត) | ២ |
| ៣ | វត្តអារាមជាមជ្ឈមណ្ឌលវប្បធម៌របស់ប្រជារាស្ត្រខ្មែរ (តចប់) | ៥ |
| ៤ | សាស្ត្រាកឹងកន្ត្រៃ (តចប់) | ៧ |
| ៥ | ទេវកថា កូរសមុទ្រទឹកដោះ | ៩ |
| ៦ | រឿងទាក់ដំរី | ១២ |
| | **ចិត្តវិទ្យាអប់រំ** | |
| ៧ | មាតាបិតាពុំមែនជាតុលាការ ពុំមែនជាឆ្មាំគុកតែជាអ្នកនាំផ្លូវសម្រាប់បុត្រធីតា (តចប់) | ១៤ |
| ៨ | វត្តបំណងរបស់សិស្សគឺចង់រៀនពូកែ | ១៦ |
| ៩ | បំណងរបស់គ្រូបង្រៀនគឺសិស្សឡើងថ្នាក់ប្រកបដោយគុណភាព | ១៨ |
| | **ការអប់រំ និងគរុកោសល្យ** | |
| ១០ | តើសាលារៀនរៀបចំឲ្យសិស្សឡើងថ្នាក់និងត្រួតថ្នាក់តាមរបៀបណា? | ២០ |
| ១១ | អំពីសិលាចារឹកនៃប្រទេសកម្ពុជា | ២២ |
| ១២ | អត្ថប្រយោជន៍នៃទិវាអំណានកម្ពុជា | ២៥ |
| ១៣ | អំពីនិបាតស័ព្ទ និងអាយតនិបាត(ត) | ២៨ |
| | **កំណាព្យ និងកម្សាន្ត** | |
| ១៤ | ស្នាដៃតែងកំណាព្យជ័យលាភីលេខ២ "គុណភាពគ្រូបង្រៀនបង្កើតធនធានអភិវឌ្ឍន៍" | ៣០ |
| ១៥ | ស្នាដៃតែងកំណាព្យជ័យលាភីលេខ៣ "គុណភាពគ្រូបង្រៀនជាគុណភាពមូលធនមនុស្សសម្រាប់ការអភិវឌ្ឍដោយចីរភាព" | ៣១ |
| ១៦ | កំហុសអ្នកណា (ត) | ៣៣ |
| | **វេទិកាស្វែរិន** | |
| ១៧ | របបប្រជាធិបតេយ្យ (តចប់) | ៣៥ |
| ១៨ | អត្ថន័យនៃការសិក្សា | ៣៧ |
| | **ព័ត៌មាន** | |
| ១៩ | ប្រវត្តិសាស្ត្រ និងរឿងព្រេងនិទានអំពីប្រាសាទភ្នំជីសូរ | ៣៩ |
| ២០ | យោបល់និងការពន្យល់ខ្លះៗអំពីតារាងប្រវត្តិកាលនៃអក្សរសាស្ត្រខ្មែរខ្លះ | ៤១ |
| ២១ | ស្ថិតិសពពីខែកុម្ភៈ ដល់ខែមេសាឆ្នាំ២០១៨ | ៤៤ |



## ទូរស័ព្ទផ្ទះគ្រូបង្រៀន

| | | | |
|---|---|---|---|
| ភ្នំពេញ | : ០១២ ៥៥៩ ៥៨៦<br>០១២ ៤៨៧ ១៣៥ | កែប | : ០៩៧ ៨ ៧២១៨៨០ |
| | | តាកែវ | : ០៩៧ ៩៧៦១ ៥៨៨ |
| ព្រះសីហនុ | : ០១២ ៦៥៩ ៥៦០ | រតនគិរី | : ០៩៧ ៩០៤២ ៥៨៤ |
| សៀមរាប | : ០១២ ៦៧៥ ៦៤០ | ព្រះវិហារ | : ០១២ ២១៨២៨១ |
| កំពង់ចាម | : ០១១ ៧៤២ ២២៤ | បាត់ដំបង | : ០១២ ៦៧៣ ៦៦២ |
| ស្វាយរៀង | : ០៩៧ ២៦៥៥ ៩៨៧ | ស្ទឹងត្រែង | : ០១២ ៩៦៤ ៤៩៦ |
| ព្រៃវែង | : ០១២ ៦៧១ ៦៤០ | កំពត | : ០១២ ៨៥៦ ៧២២ |
| ប៉ៃលិន | : ០៨១ ២៥០ ៩១៦ | មណ្ឌលគិរី | : ០១១ ៨០៤ ៣៤៧ |

# វិចារណកថា

នាពេលវេលាមួយដែលភាពតានតឹង និងអវិភាពកើនឡើងជាលំដាប់ ពេលនោះសិទ្ធិមនុស្ស សេរីភាព ការសម្ដែងមតិ សន្តិភាពនិងអនាគតភពផែនដីហាក់ចោទជាបញ្ហាសាំញ៉ាំស្មុគស្មាញស្ទើរគ្មានដំណោះស្រាយ។ ចំពោះកាលៈទេសៈនេះ ឥទ្ធិពលកែប្រែរបស់ការអប់រំ មានសារៈសំខាន់មិនអាចខ្វះបាន។

ការអប់រំគឺជា "គំនិតហួសវិស័យតែចាំបាច់" ព្រោះការងារនេះជាមធ្យោបាយគ្រប់គ្រាន់ដើម្បីអនុញ្ញាតឲ្យមនុស្សជាតិវិវត្តឈានឡើងឆ្ពោះទៅកាន់ឧត្តមគតិសន្តិភាពនិងយុត្តិធម៌សង្គម។ នេះបើផ្អែកលើរបាយការណ៍ជាប្រវត្តិសាស្ត្ររបស់ UNESCO ដែលកំណត់ច្បាស់ថា "ការអប់រំជាកំណប់ទ្រព្យ ដែលលាក់ទុកខាងក្នុង"។ ដូចនេះការអប់រំមិនមែនជាអព្ភូតហេតុ និងមិនមែនជាចង្កឹះទិព្វទេ តែការអប់រំជាកម្លាំងចលករដែលសំខាន់ជាងគេ ដើម្បីលើកកម្ពស់ស្ថានភាពជីវភាពរបស់មនុស្សជាតិឲ្យល្អប្រសើរ។

សព្វថ្ងៃនេះ មនុស្សជាតិកំពុងប្រឈមចំពោះបរមតិ(មតិផ្ទុយនិងមតិធម្មតា) យ៉ាងចម្លែកនោះគឺ ប្រជាជនពិភពលោកមួយចំនួនមិនមានចំណេះវិជ្ជានៅឡើយ។ ជាក់ស្ដែងកុមារនិងយុវជន២៦៣លាននាក់មិនទាន់បានចូលសាលារៀន កុមារនិងមនុស្សពេញវ័យ៦១៧លាននាក់មិនចេះអាននិងមិនចេះគិតលេខនិងមនុស្សចាស់យ៉ាងតិច ៧៥០លាននាក់ជាអនក្ខរជន។ (តួលេខរបស់វិទ្យាស្ថានស្ថិតិនៃ UNESCO)។ ឯកុមារីដែលមិនបានចូលរៀនវិញ មានចំនួនច្រើនបើប្រៀបធៀបនឹងកុមារា។ ក្នុងន័យនេះការអប់រំជានិច្ចកាលតែងតែអំពាវនាវឲ្យយើងយកចិត្តទុកដាក់ដោះស្រាយ វិសមភាព ភាពក្រីក្រ ភេរវកម្ម និងជម្លោះ។ យើងចាត់ទុកថា ការអប់រំជាគន្លឹះសារវន្តមួយក្នុងចំណោមគន្លឹះដទៃទៀត នៃលក្ខណៈពលរដ្ឋរបស់ពិភពលោក និងការអភិវឌ្ឍបិតថេរ ព្រមទាំងវិស័យ២ផ្សេងទៀតដែលUNESCOទទួលអាណត្តិត្រូវចាត់ចែងដឹកនាំសកម្មភាព ទាក់ទងនឹងទិនានុលេខន៍នៃការអប់រំឆ្នាំ២០៣០ ដោយតាមដានត្រួតពិនិត្យ ជាពិសេសការបាត់បង់ផលប្រយោជន៍ពីការអប់រំរបស់មនុស្សម្នាក់ៗ និងគោលដៅអភិវឌ្ឍន៍ដោយចីរភាពរបស់ អ.ស.ប.។

ជាសន្និដ្ឋាន ការស្វែងរក "គំនិតហួសវិស័យតែចាំបាច់" UNESCO គប្បីសម្លឹងមើលឲ្យទូលំទូលាយ លើការអប់រំក្នុងពិភពលោក និងពិនិត្យពិច័យឲ្យម៉ត់ចត់ដោយចោទសួរថា "តើការអប់រំត្រូវឆ្លើយតបយ៉ាងដូចម្ដេច ចំពោះបញ្ហាប្រឈមបច្ចុប្បន្ននេះដើម្បីកែប្រែស្ថានភាពជីវភាពរបស់មនុស្សជាតិ?"៕

*គណៈកម្មាធិការកណ្ដាលស.ប.ស.ខ.*




## ប្រភពនៃការអប់រំក្នុងពិភពលោក (ត)

### ៥. មជ្ឈិមសម័យ (៥០០-១៤០០ គ.ស.)

1. **គោលដៅអប់រំ :** អភិវឌ្ឍការតស៊ូប្ដូរផ្ដាច់ចំពោះសាសនា ចំណេះដឹង និងទម្លាប់ត្រៀមរៀបចំមនុស្ស សម្រាប់តួនាទីសមរម្យ តាមឋានានុក្រម។
2. **សិស្ស :** ក្មេងប្រុសវណ្ណៈខ្ពស់ ឬអ្នកទាំងឡាយដែលកំពុងចូលរួមជីវិតសាសនា ក្មេងស្រី និងស្ត្រី ដែលកំពុងចូលរួមសហគមន៍សាសនា ពីអាយុ ៧-២០ឆ្នាំ។
3. **វិធីបង្រៀន :** ហ្វឹកហាត់ ទន្ទេញ សូត្រ ស្មូត្រ នៅសាលាកម្រិតទាប ការវិភាគអត្ថបទ និងការពិភាក្សាជាផ្លូវការនៅសាលាកម្រិតខ្ពស់ និងសាកលវិទ្យាល័យ។
4. **កម្មវិធីសិក្សា :** ការអាន ការសរសេរ នព្វន្តសាស្ត្រ សិល្បៈសេរី ទស្សនវិជ្ជា ការប៉ិនប្រសប់ យុទ្ធសាស្ត្រយោធា និងភាពជាអ្នកក្លាហានប្រកបដោយសីលធម៌។
5. **ភ្នាក់ងារ :** សាលារៀនជើងវត្តច្រៀងចម្រៀងជាពួក និងព្រះវិហារ សាកលវិទ្យាល័យ ភាពជាអ្នកហាត់ការ អស្សឫទ្ធិភាព។
6. **ឥទ្ធិពលទៅលើការអប់រំទំនើប :** រចនាសម្ព័ន្ធដែលបានបង្កើតឡើង ខ្លឹមសារ និងការចាត់តាំងសាកលវិទ្យាល័យ ជាស្ថាប័នចម្បងនៃឧត្តមសិក្សា ស្ថាប័ននីយកម្ម និងការរក្សានូវចំណេះដឹង។

### ឈ. បុនឌុឌ្ឍិសិល្បៈសម័យ (១៣៥០-១៥០០ គ.ស.)

1. **គោលដៅអប់រំ :** បណ្ដុះអ្នកជំនាញការមនុស្សនិយម ក្នុងអក្សរសិល្ប៍ក្រិក និងឡាតាំង ត្រៀមរៀបចំបរិវារស្ដេច សម្រាប់សេវាកម្ម ចំពោះមេដឹកនាំសន្ដតិវង្ស។
2. **សិស្ស :** ក្មេងប្រុសនៃវណ្ណៈអភិជន និងវណ្ណៈខ្ពស់ អាយុ ៧-២០ឆ្នាំ។
3. **វិធីបង្រៀន :** ការទន្ទេញ ការបកប្រែ និងការវិភាគអក្សរសិល្ប៍ក្រិក និងរ៉ូម៉ាំង។
4. **កម្មវិធីសិក្សា :** ភាសាក្រិក ឡាតាំង អក្សរសិល្ប៍ កំណាព្យ សិល្បៈ។

5. **ភ្នាក់ងារ** : អ្នកអប់រំមនុស្សនិយម និងសាលាដូចជា វិទ្យាល័យ គ្រឹះស្ថានហាត់ប្រាណ និងសាលាភាសាឡាតាំង។
6. **ឥទ្ធិពលទៅលើការអប់រំទំនើប** : ការសង្កត់ធ្ងន់ទៅលើចំណេះអក្ខរកម្ម ឧត្តមភាព និងរចនាបថដែលបានបង្ហាញក្នុងអក្សរសិល្ប៍ក្រិក និងឡាតាំង និងប្រព័ន្ធពីរបែបនៃសាលារៀន។

**ញ. សម័យការកែទម្រង់ (១៥០០-១៦០០ គ.ស.)**

1. **គោលដៅអប់រំ** : បំពាក់បំប៉នការតស៊ូ សន្យា ដល់និកាយសាសនា ពិសេសបណ្ដុះអក្ខរកម្មទូទៅ។
2. **សិស្ស** : ក្មេងប្រុស និងស្រី អាយុ ៧-១២ ឆ្នាំ នៃសាលារៀនក្នុងតំបន់ណាមួយ ក្មេងប្រុសអាយុពី ៧-១២ឆ្នាំ ដែលមានប្រវត្តិវណ្ណៈខ្ពស់ ក្នុងសាលាមនុស្សនិយម។
3. **វិធីបង្រៀន** : ការទន្ទេញ ហ្វឹកហាត់ ការបញ្ចុះបញ្ចូលឲ្យធ្វើតាម ការបង្រៀនតាមព្រះវិហារក្នុងសាលារៀន នៅតំបន់ណាមួយ ការបកប្រែ វិភាគអក្សរសិល្ប៍ក្រិក និងឡាតាំង ក្នុងសាលាមនុស្សនិយម។
4. **កម្មវិធីសិក្សា** : ការអាន សរសេរ នព្វន្តសាស្ត្រ ការសង្ខេបគោលការណ៍សាសនា បញ្ញត្តិសាសនា និងទម្លាប់ សាសនវិទ្យាក្រិក និងឡាតាំង។
5. **ភ្នាក់ងារ** : សាលាបឋមសិក្សាក្នុងតំបន់ណាមួយ សម្រាប់ប្រជាករ សាលាបែបបុរាណសម្រាប់ត្រកូលខ្ពស់។
6. **ឥទ្ធិពលទៅលើការអប់រំទំនើប** : ការតស៊ូសន្យាចំពោះការអប់រំសកល ដើម្បីផ្ដល់អក្សរដល់ប្រជាករ ប្រភពនៃប្រព័ន្ធសាលារៀន ជាមួយការត្រួតពិនិត្យ ដើម្បីជានាការអនុលោមទៅតាមលទ្ធិ ប្រព័ន្ធសាលាពីរបែប ដោយផ្អែកទៅលើវណ្ណៈសេដ្ឋកិច្ចសង្គម និងគោលដៅវិជ្ជាជីវៈ។

**១២-ទ្រឹស្ដីវិទូអប់រំចម្បងៗ ដល់ឆ្នាំ ១៦០០ នៃ គ.ស.**

**ក-ខុងជឺ ៥៥១-៤៥៨ មុន គ.ស. (ចិន)**

1. **ការតម្រង់ទិសខាងទស្សនវិជ្ជា**
   - បានអភិវឌ្ឍប្រព័ន្ធសីលវិទ្យា ដោយផ្អែកទៅលើការរៀបចំទៅតាមឋានានុក្រម នៃទំនាក់ទំនងមនុស្ស និងតួនាទី។
   - សង្កត់ធ្ងន់ទៅលើរបៀបរៀបរយ និងស្ថិរភាព តាមរយៈការនៅក្រោមបង្គាប់។
2. **ទស្សនៈធម្មជាតិមនុស្ស**
   មនុស្សជាតិ ត្រូវការសណ្ដាប់ធ្នាប់នៃសង្គមដែលមានស្ថិរភាពកម្រិតខ្ពស់ ក្នុងនោះមនុស្សទទួលយកករណីយកិច្ច ដែលគិតដល់ឋានៈក្នុងជីវិត។
3. **ទស្សនៈទៅលើការអប់រំ និងកម្មវិធីសិក្សា**
   - ការអប់រំត្រៀមរៀបចំមនុស្ស សម្រាប់តួនាទីនយោបាយសង្គម តាមការបណ្ដុះគុការភាព សម្រាប់បុព្វបុរស និងប្រពៃណី។

- កម្មវិធីសិក្សារបស់អ្នកនិពន្ធចិនបុរាណដែលមានគុណសម្បត្តិ និងតម្លៃអមតៈនិង ការប្រមូលផ្តុំនៃអ្នកជំនាញការពីស្នាដៃអក្សរសិល្ប៍ (Analects) របស់ខុងជឺ។
- ការប្រឡងជ្រើសរើសកម្រិតខ្ពស់

**4. ការរួមចំណែក និងឥទ្ធិពល**

ក្រមសីលវិទ្យារបស់ខុងជឺ បានបង្កើតវប្បធម៌ចិនអស់រយៈពេលជាច្រើនសតវត្ស ដោយបានបង្កើតប្រព័ន្ធតម្លៃ ដែលនៅស្ថិតស្ថេរដ៏មានសារៈសំខាន់។ (*នៅមានត*)

*អនុបណ្ឌិត* **សូ សុធីរ**

**<u>ឈើហូបផ្លែ</u>**

វុក្ខធញ្ញជាតិសាច់បន្លែ
គេអាចថ្លៃកែជាចំណី
ព្រមទាំងផ្លែឈើទុំចាស់ខ្ចី
មនុស្សញ៉ាំហូបឆីគ្រប់ៗប្រាណ ។
កន្ទួត ក្រខុប ខ្នុរ ពង្រ
ខ្វិត គុយ ចេក ញ ក៏ញ៉ាំបាន
ត្របែក ផ្ទៀល ទៀប ហូបកម្សាន្ត
កំចាត់រោគឃ្លានបានមួយគ្រា ។
ដង្កៀបក្ដាម ឈូក ព្រីង ដង្កោ
ញ៉ៅ ទឹកដោះគោ ពោន ពុទ្រា
ធ្លក បំពេញរាជ្យ ខ្វាស់ ពន្លា
សាកេ សេដា មៀន ម្នាស់ ស្វាយ ។
មាក់ដោក មាក់ប៉ែន ប៉ោម មាក់សាង
មាក់ប្រេង មាក់ប្រាង ទទឹម ស្ពាយ
អម្ពិលទឹក ស្ពឺ លោះ ដូនកាយ
ដូងតាកែ វាយ ពួច ទំពូង ។
ក្រឡាញ់ លម៉ើ គ សម៉
ព្រហូត សង្ឃ័រ ថ្កូវ ទ្រមូង។
មាក់បាត លាំងសាត ផ្ទៀរ ល្ហុង ដូង
ត្នោត ចេកអំបូង ទ្រយឹង ម្កាក់ ។
ទុរេន គូលែន ស្វាយចន្ទី
សំរង គីវី ចម្ប៉ាដាក់
រំដួល រំដេញ ឪឡឹក ល្ពាក់
ពោត ស្រកានាគ ទម្លាប់ ភ្លូ ។
សាវម៉ាវ សិរមាន់ ច័ន មង្ឃុត
ទ្រលឹងទឹង ល្មុត ល្វា ជម្ពូ
បេះភ្លាមញ៉ាំភ្លែត កុំទុកយូរ
ទំពាំងបាយជូរ ទៀបបារាំង ។
ជើងចាប ដកម៉ៃ អំព្រាំ ព្រូស
ក្របៅ ជន្លួស ប្រដាក ភ្លាំង
ក្រូចថ្លុង ក្រូចឃ្វិច ល្មៀង ក្រសាំង
អារ៉ូកា ទ្រាំង ថ្នឹង ចាមរី។
ផ្លែឈើច្រើនណាស់មិនអាចស្មាន
ខ្ញុំបាទរាប់បានមួយរយបី
លើសលស់ឆ្គងទាស់សូមប្រណី
អត់ទោសអភ័យជួយថ្លៃកែ ៕

**ឧបាសក ហ៊ិម ឆាន់**

កម្រងកំណាព្យ ភាគទី២

# វត្តអារាមជាមជ្ឈមណ្ឌលវប្បធម៌របស់ប្រជារាស្ត្រខ្មែរ(តចប់)

នៅសម័យមហានគរ យើងមានប្រាសាទបុរាណ មានអង្គ មានព្រះធាតុ មានសិលាចារឹក ដែលជាភស្តុតាងបញ្ជាក់ថា ប្រជាជនខ្មែរធ្លាប់បានរស់នៅលើទីណាខ្លះ ក្នុងឧបទ្វីបអាស៊ីអាគ្នេយ៍នេះ។ ចាប់ពីសម័យកណ្ដាល គឺវត្តអារាមដែលអាចបញ្ជាក់បន្ថែមទៀត ទៅលើប្រាសាទបុរាណទាំងនោះ។

វត្តអារាមជារបស់ប្រជារាស្ត្រខ្មែរ កសាងដោយប្រជារាស្ត្រខ្លួនឯង និងដើម្បីបម្រើផលប្រយោជន៍របស់ប្រជារាស្ត្រខ្លួនឯង។ ដូច្នេះមានតែប្រជារាស្ត្រខ្មែរទេ ដែលជាអ្នកកំណត់ជោគវាសនារបស់វត្តអារាម។

ក្នុងរយៈពេលមួយទសវត្សមុនថ្ងៃរំដោះ បុរាណដ្ឋាន ប្រាសាទបុរាណ និងវត្តអារាមស្ទើរតែទាំងអស់ ត្រូវទទួលរងគ្រោះមហន្តរាយដោយសារសង្គ្រាម និងរបបប្រល័យពូជសាសន៍ ធ្វើឲ្យបាត់អស់នូវភស្តុតាង ជាកេរដំណែលដូនតារបស់យើង។ ការបំផ្លិចបំផ្លាញគាស់កកាយ ជីករំលើងបុរាណដ្ឋាន ក៏បានន័យថាជាការសម្លាប់ ព្រលឹងជាតិ។ ការបំផ្លាញវត្តអារាម ការដុតកម្ទេចគម្ពីរក្បួនខ្នាត ការប្រើប្រាស់ពាក្យពេចន៍ខុសក្បួនច្បាប់ ក៏ចាត់ទុកថាជាការសម្លាប់ព្រលឹងជាតិដែរ។

ឥឡូវនេះ ទោះបីសង្គ្រាមនិងរបបប្រល័យពូជសាសន៍បានកន្លងផុតហើយក៏ដោយ តែផលវិបាករបស់វានៅតែមានយ៉ាងធ្ងន់ធ្ងរ មកលើវប្បធម៌ មកលើសតិបញ្ញាស្មារតី ធ្វើឲ្យជនជាតិខ្មែរគ្រប់រូប មានរបួសខាងផ្លូវចិត្តមិនអាចព្យាបាលឲ្យជាសះស្បើយវិញក្នុងរយៈពេលខ្លីបានឡើយ ដែលជាហេតុធ្វើឲ្យខ្មែរមានវិបល្លាសខាងសតិបញ្ញា វង្វេងនៅក្នុងភាពស្មុគស្មាញ ទន់ខ្សោយ, បាត់ជំនឿលើខ្លួនឯង។ ប្រជាជនខ្មែរឥឡូវ មិនទាន់ចាប់យកព្រលឹងរបស់ខ្លួនដែលលស់ទៅនោះបានមកវិញទេ ពោលគឺកំពុងស្ថិតក្នុងភាព «លស់ព្រលឹងនៅឡើយ» ។

គួរឲ្យខ្មាសខ្លួនឯងណាស់ ដែលខ្មែរយើងពីបុរាណ ដូនតាយើងធ្លាប់តែជាគ្រូគេ ធ្លាប់តែដាក់ទានឲ្យគេ ឥឡូវខ្មែរទ្រុឌទ្រោម ត្រូវគេមើលងាយ ព្រោះខ្មែរខ្សោយ ខ្មែរមិនខ្លាំងដូចពីបុរាណ។

## យើងធ្វើឲ្យវត្តអារាមក្លាយជាមជ្ឈមណ្ឌលវប្បធម៌ឡើងវិញ

ហេតុនេះ ដើម្បីឲ្យព្រលឹងខ្មែរ (រស់មកវិញ) ចូលមកសណ្ឋិតក្នុងរូបរាងកាយរបស់ខ្មែរវិញ ប្រជាជាតិខ្មែរ ត្រូវរួមចំណែកស្វែងរកព្រលឹងនោះគ្រប់ៗគ្នា។ ស្របពេលនឹងការកសាងវត្តអារាមខាងសម្ភារៈរបស់ពុទ្ធបរិស័ទ ព្រះសង្ឃក៏មានភារកិច្ចយ៉ាងសំខាន់ដែរ នោះគឺការថែរក្សាវប្បធម៌ខ្មែរ ការបំប៉នពូនជ្រំឲ្យវប្បធម៌រីកចម្រើនលូតលាស់ឡើងវិញ ឲ្យស្មារតីជាតិ ស្មារតីច្នៃប្រឌិតរបស់ខ្មែររស់ឡើងវិញ ទប់ទល់នឹងអប្បិយជំនឿ ទប់ទល់នឹងការឈ្លានពាន និងឥទ្ធិពលនៃវប្បធម៌បរទេសឲ្យបាន។ ត្រូវខិតខំលើកតម្កើងនិងឲ្យតម្លៃ ឲ្យសារៈសំខាន់ដល់វប្បធម៌ខ្មែរ។ ចំពោះមុខ វត្តអារាម

ណាដែលបានស្ដារឡើងវិញរួចគប្បីប្រែក្លាយឲ្យទៅជាមជ្ឈមណ្ឌលវប្បធម៌ជាតិឲ្យបានដូចពីបុរាណកាល។

ក្នុងការអនុវត្តជាក់ស្ដែង ការស្ដារតួនាទីរបស់វត្តឲ្យដូចពីបុរាណ ត្រូវធ្វើតាមលទ្ធភាព និងស្ថានភាពជាក់ស្ដែងរបស់មូលដ្ឋាននីមួយៗ ព្រមទាំងសមស្របទៅនឹងការរីកចម្រើនរបស់សង្គមផង។

**ប៉ុន្តែវត្តអារាមគប្បីចាប់អារម្មណ៍ដល់ការងារសំខាន់ ដូចខាងក្រោម៖**

១- ការសាងសង់សំណង់ថ្មី ត្រូវតែថែរក្សាឲ្យបាននូវលក្ខណៈចរិតវប្បធម៌ខ្មែរ ខាងស្ថាបត្យកម្ម។ ការតុបតែងលម្អ ក៏ត្រូវតែគោរពតាមក្បួនខ្នាតនៃសិល្បៈខ្មែរ។

២- ស្ថាបត្យកម្មសំណង់ចាស់ក្នុងវត្តអារាម ត្រូវតែខំរក្សាទុកឲ្យបានល្អ។ ការជួសជុលត្រូវធ្វើឲ្យប្រយ័ត្នប្រយែង កុំឲ្យប៉ះពាល់ដល់សោភ័ណ សិល្បៈស្ថាបត្យកម្មបុរាណ។ បើចាំបាច់ត្រូវរុះរើនោះ គប្បីរក្សាបំណែកសិល្បៈទាំងឡាយទុកធ្វើជាគំរូ។

៣- ត្រូវខិតខំដាំដើមឈើល្អៗ ឈើកម្រៗ ឈើប្រើជាថ្នាំសង្កូវ ឈើហូបផ្លែ ឈើលម្អសួន ឈើយកស្លឹក(ម្លប់)។

៤- ត្រូវជីកស្រះធំៗយកទឹកប្រើប្រាស់ ស្រោចស្រពដំណាំ យកទឹកជាជម្រកត្រី។ បក្សាបក្សីខ្លះ រស់ដោយសារមច្ឆជាតិ ក៏អាចវិលមកនៅក្នុងវត្តវិញ។

៥- ខិតខំបង្កើតសាលារៀន ឬខិតខំបង្រៀនសង្ឃខ្ញីវស្សាឲ្យចេះធម៌អាថ៌ ចេះភាសាខ្មែរ ភាសាបាលី ចេះសរសេរ ចេះលេខនព្វន្ត។

៦- បង្កើតឲ្យមានទូសៀវភៅ បណ្ណាល័យ សម្រាប់ព្រះសង្ឃផង និងសម្រាប់ប្រជាជនរៀនសូត្រផង។

៧- វត្តនីមួយៗគប្បីបង្រៀនមុខវិជ្ជាជំនាញ ត្រូវមានរោងជាងរបស់វត្តដូចជាជាងឈើ តុកៅអី គ្រែ ឬសិប្បកម្ម ល្អី កញ្ជើ... ខ្សែវល្លិ ឬសិល្បៈសូនរូប មានចម្លាក់ គំនូរបុរាណជាដើម។ វត្តរួមចំណែកអប់រំកូនចៅខ្មែរ ឲ្យមានលក្ខណៈពេញលេញជាពលរដ្ឋដ៏ល្អដែលអាចប្រកបមុខរបរចិញ្ចឹមជីវិតដោយខ្លួនឯងបាន។ វត្តក៏អាចមានលទ្ធភាពធ្វើឲ្យអ្នកដែលរៀននៅសាលាវត្តមានសមត្ថភាពដូចជាសាលារដ្ឋដែរ។ លើសពីនេះទៀត អ្នករៀនសាលាវត្ត អាចមានសមត្ថភាពខ្ពស់ខាងការអប់រំសីលធម៌ និងអក្សរសាស្ត្រ។ដូច្នេះសិស្សសាលាវត្តជាមនុស្សដែលមានគុណភាពខាងសីលធម៌ ខាងវិជ្ជាជីវៈ ខាងវប្បធម៌ និងខាងអក្សរសាស្ត្រ។

បើធ្វើបានយ៉ាងនេះ នោះវត្តអារាមរបស់យើង ប្រាកដជាបំពេញបាននូវភារកិច្ចដែលវត្តធ្លាប់មានពីបុរាណមក៕

*ដកស្រង់ដោយលោក ជន ឈាងលី*

*ពីសៀវភៅអក្សរសាស្ត្រពុទ្ធសាសនា និពន្ធដោយលោក* **ឃី ឆន់**

# សាស្ត្រាកឹងកន្ត្រៃ (តចប់)

តាមការសង្កេតឃើញរបស់លោក ហុក កុសល ឈ្មោះផ្ទះខ្មែរប្រភេទនីមួយៗច្រើនតែកំណត់ដោយដំបូល ដូចជាផ្ទះរោងដោល ផ្ទះប៉ិតជាដើម សុទ្ធសឹងតែមានដំបូលខុសៗគ្នា។ ឆ្លងតាមសេចក្ដីសង្កេតនេះ "ផ្ទះកឹង" ក៏មិនខុសពីផ្ទះខ្មែរផ្សេងទៀតដែរ គឺហេតុដែលនាំឲ្យមានឈ្មោះថា "ផ្ទះកឹង" គឺមកពីដំបូលផ្ទះនេះ មានលក្ខណៈរឹងមាំនៃដំបូលថ្នាក់លើ។ ក្នុងន័យដូចគ្នានេះដែរ "កឹងព្រះបាទ" សំដៅដល់ព្រះពន្លាសម្រាប់តម្កល់ស្នាមព្រះបាទរបស់ព្រះពុទ្ធទាំង ៥អង្គដែលបានត្រាស់រួច ហើយ(២)។

សរុបសេចក្ដីមក ពាក្យ "កឹង" ឬ "កិង" នេះអាចកំណត់ន័យបានថា ជាសភាវៈទ្រទ្រង់ ជាទម្រមូលដ្ឋាន ប្រកបដោយលក្ខណៈរឹងប៉ឹង មាំទាំ ខ្លាំងក្លា នឹងថ្កល់ ឥតងាកបែរ។

តាមប្រពៃណីយុត្តិធម៌ខ្មែរ ក្នុងឋានៈជាចៅក្រមកំពូលដែលទ្រទ្រង់យុត្តិធម៌ដល់អាណាប្រជានុរាស្ត្រ ព្រះមហាក្សត្រ តែងមានព្រះហស្តកាន់ព្រះខ័នជាប់ជានិច្ច នៅរៀងរាល់ពេលដែលព្រះអង្គយាងចេញមកខាងក្រៅព្រះបរមរាជវាំង ដើម្បីធ្វើសឹកសង្គ្រាម ឬ ក្រសាលព្រៃ ឬដើម្បីប្រទានសវនាការដោះស្រាយជំនុំជម្រះសេចក្ដី ប្រទានយុត្តិធម៌ដល់អាណាប្រជានុរាស្ត្រ (៣)។ ម្យ៉ាងទៀតព្រះខ័នគឺជាសិរីរាជសម្បត្តិមួយមុខក្នុងចំណោមគ្រឿងឥស្សរិយយសទាំងប្រាំរបស់ព្រះរាជាម្ចាស់ផែនដី ដែលមានឈ្មោះជា បញ្ចកកុធភណ្ឌ ឬរាជកកុធភណ្ឌ ពោលគឺ ព្រះមកុដ ព្រះវាលវីជនី (ផ្លិតធ្វើដោយរោមសត្វពណ៌ស) ព្រះខ័ន ស្វេតឆត្រ និងព្រះសុវណ្ណបាទុកា (ស្បែកជើងមាស) (៤)។ អាស្រ័យហេតុនេះហើយ ទើបព្រះខ័ន គឺជាគ្រឿងសស្ត្រាវុធនិមិត្តរូបនៃយុត្តិធម៌ឧដុង្គឧត្តម ដែលទ្រទ្រង់ដោយព្រះមហាក្សត្រ។

ចំណែកឯកន្ត្រៃពុំមែនជាឧបករណ៍ពិសិដ្ឋអ្វីរបស់ព្រះរាជា ឬពុំតំណាងឲ្យការកាត់សេចក្ដីផ្ដល់យុត្តិធម៌អ្វីឡើយ។ មូលហេតុនៃការដាក់ឈ្មោះសាស្ត្រាកឹងកន្ត្រៃសម្រាប់សម្គាល់សាស្ត្រាដែលទាក់ទងនឹងតុលាការកាត់ក្ដីនេះ ស្ថិតនៅក្នុងសភាពអាថ៌កំបាំងនៅឡើយ មិនដឹងថាឈ្មោះសាស្ត្រានេះត្រូវបានកំណត់ដោយអ្នកស្រុកនិយាយតៗគ្នា ឬមានឥទ្ធិពលមកពីប្រភពណានោះឡើយ។

តែទោះជាយ៉ាងណាក៏ដោយកន្ត្រៃមានតួនាទីដ៏ចាំបាច់មិនអាចខ្វះបាន នៅក្នុងព្រឹត្តិការណ៍ដ៏សំខាន់ប្រចាំឆាកជីវិតរបស់ខ្មែរប្រុសស្រីគ្រប់រូបពោលគឺអាពាហ៍ពិពាហ៍។ នៅក្នុងពេលរៀបមង្គលការ ពិធីមួយឈ្មោះថា "ពិធីកាត់សក់" ឬ"ពិធីកាត់សក់បង្កក់សិរី"តម្រូវឲ្យសម្ដែង "វគ្គលក់កន្ត្រៃ"

(២)- ស្ត្រី សារឿន: មគ្គុទេសក៍ទេសចរ, កឹងព្រះបាទនេះស្ថិតនៅក្នុងព្រះបរមរាជវាំង ក្រុងភ្នំពេញ។

(៣)- លី ឆាមតេង: កំណត់ហេតុ ជីវ តាក្វាន់ អំពីប្រពៃណីក្នុងស្រុកចេនឡា។

(៤)- ឧកញ៉ា ទេព ពិទូរក្រសេម : ពិធីទ្វាទសមាសភាគទី១។

ឬ"វត្ថុទេវរាជប្រទានកន្រ្តៃទិព្វ" ដើម្បីយកទៅកាត់សក់កូនប្រុសស្រី ឲ្យមានសិរីសួស្តី ជោគជ័យ សុភមង្គល។ តែពិធីនេះពុំមានទំនាក់ទំនងអ្វីជាមួយនឹងរឿងកាត់ក្តីឡើយ។ ហេតុដែលបណ្តាលឲ្យបុរាណាចារ្យកំណត់យកកន្ត្រៃ សម្រាប់ដាក់ឈ្មោះសាស្ត្រាទាក់ទងនឹងតុលាការកាត់ក្តីនេះទំនងជាមកពីកន្ត្រៃគឺជាឧបករណ៍សម្រាប់កាត់វត្ថុផ្សេងៗ ដូចជាសំពត់ ឬសក់ ដោយសមស្របតាមបំណងប្រាថ្នារបស់ប្រជាជនខ្មែរគ្រប់ស្រទាប់វណ្ណៈ ពោលគឺជាឧបករណ៍មួយដ៏សកលទូទាំងដែនទឹកដីខ្មែរសម្រាប់កាត់វត្ថុផ្សេងៗ ដែលត្រូវគ្នានឹងពាក្យថា កាត់សេចក្តី កាត់ក្តី ឬកាត់ទោស។ លើសពីនេះទៀតតាមវចនានុក្រមខ្មែរ ពាក្យថា "កាត់" នេះមានន័យថា "បែក ផ្តាច់ដោយប្រដាប់មានមុខមុតមានកន្ត្រៃ រណារជាដើម"។ ទំនងជាដោយសារមូលហេតុនេះហើយទើបកន្ត្រៃបានក្លាយជានិមិត្តរូបនៃការកាត់ក្តី ឬយុត្តិធម៌ តាមទស្សនៈអក្សរសាស្ត្រខ្មែរ ក្នុងស្រទាប់ប្រជារាស្ត្រសាមញ្ញដែលពុំធ្លាប់បានយល់ ព្រះខ័នជានិមិត្តរូបនៃយុត្តិធម៌របស់ព្រះមហាក្សត្រ។

ឆ្លងតាមការវិភាគ និងបកស្រាយខាងលើនេះ "សាស្ត្រាកឹងកន្ត្រៃ" អាចមានន័យថាជាសៀវភៅ គម្ពីរ ច្បាប់ តម្រា វិជ្ជា ក្បួន ឬការសិក្សា ដែលយើងអធិប្បាយអំពីមូលដ្ឋានដ៏រឹងមាំ តឹងរ៉ឹង និងជាក់លាក់ឥតងាករេ ដែលទ្រទ្រង់ដល់ការកាត់ក្តី ស្វែងរកយុត្តិធម៌ ឬនិយាយដោយខ្លីថា "ការសិក្សាអំពីមូលដ្ឋាននៃយុត្តិធម៌"។

លក្ខណៈរឹងមាំ តឹងរ៉ឹង និងជាក់លាក់ឥតងាករេ នៃដំណើរការកាត់សេចក្តីស្វែងរកយុត្តិធម៌បានចារឹកបង្កប់ក្នុងដំណើររឿងនីមួយៗ ដែលបានតំណាលទុកក្នុងសាស្ត្រាកឹងកន្ត្រៃ និងស្តែងចេញជារបៀនយុត្តិធម៌ ក្រោមបទវិភាគរិះរកគោលការណ៍យុត្តិធម៌ តាមលំអានវណ្ណគតិអក្សរសាស្ត្រជាលំដាប់លំដោយដូចខាងក្រោមនេះ។

(នៅក្នុងបណ្តារឿងព្រេងដ៏ច្រើនសន្ធឹកសន្ធាប់រឿងកឹងកន្ត្រៃ ឬសាស្ត្រាកឹងកន្ត្រៃ គឺជាប្រជុំរឿងព្រេងខ្មែរចំនួន៥៣រឿងដែលបានលើកយកករណីយកិច្ចរបស់អ្នកកាត់ក្តី និងគោលការណ៍ទូទៅនៃយុត្តិធម៌ មកលាតត្រដាងបង្ហាញ។ ក្រៅពីសាស្ត្រានេះ មានរឿងព្រេងដទៃទៀតទាក់ទងនឹងការកាត់ក្តីផងដែរ ដែលបានលើកយកបញ្ហាយុត្តិធម៌តាមទំនៀមខ្មែរមកពិចារណា)៕

ដកស្រង់ពី " មរតកយុត្តិធម៌ខ្មែរ " បណ្ឌិត ហ៊ែល ចំរើន

## សុភាសិតខ្ញុំ

| | | |
|---|---|---|
| ប្រាំបួនទាល់ | ដប់ទាល់ | កុំឲ្យទាល់គំនិត |
| ប្រាំបួនគិត | ដប់គិត | កុំគិតមេឃដី |
| ប្រាំបួនធ្វើ | ដប់ធ្វើ | កុំធ្វើការអប្រិយ |
| ប្រាំបួនស្តី | ដប់ស្តី | កុំស្តីពាក្យអសុរោះ ។ |

កុំធ្វើខ្លួនឲ្យចូលក្នុងសុភាសិតថា៖

ដំបូលផ្ទះ ឆ្ងាយជាងដំបូលផ្សារ (១) គូថភរិយាជិតជាងធាតុម្តាយឪពុក (២) ។

(១) យកផ្សារជាផ្ទះ ។ (២) គិតតែកូនប្រពន្ធ ម្តាយ ឪពុក បំភ្លេច ។

**យូរ អ៊ុន** វិធីប្រែបាលី (១៩៥០)

# ទម្រង់វប្បធម៌អរូបីនៃ «ទេវកថា កូរសមុទ្រទឹកដោះ»

**សេចក្ដីផ្ដើម** : ការណ៍ដែលខ្ញុំលើកយកទម្រង់វប្បធម៌អរូបីនៃ "ទេវកថាកូរសមុទ្រទឹកដោះ" មកបកស្រាយនិងបង្ហាញនៅពេលនេះ គឺខ្ញុំមានបំណងគាស់កកាយនូវចំណងទាក់ទងរវាងវប្បធម៌សំយោគ ខ្មែរ-ឥណ្ឌា ដែលធ្លាប់កកើតចាប់ឫសគល់នៅលើចក្រភពខ្មែរបុរាណតាំងពីសម័យហ្វូ-ណន ឬនគរភ្នំ តាមរយៈសាសនទូតមកពីប្រទេសឥណ្ឌាក្នុងអំឡុងសតវត្សទី១ នៃគ្រិស្តសករាជកន្លងមក ត្រូវកប់បាត់ក្នុងប្រវត្តិសាស្ត្រជាយូរណាស់មកហើយជូនសាធារណជន និងអ្នកស្នេហាការសិក្សាជ្រាប។ ពិសេសអ្នកមានបំណងចង់ចេះចង់ដឹងពីទេវកថាកូរសមុទ្រទឹកដោះនេះថាវាមានអត្ថន័យ និងសេចក្ដីរៀបរាប់ពីដំណើររឿងដូចម្ដេចដែរ ព្រោះកន្លងមកមានអ្នកខ្លះធ្លាប់តែឮត្រឹមតែចំណងជើងមិនដឹងថាម៉េច! ខ្លះទៀតក៏ធ្លាប់ឃើញតាមហោជាងផ្ដែរទ្វារ ឬជញ្ជាំងប្រាសាទមួយចំនួន តែមិនចេះមើល ឬមើលពុំយល់ចេះចាំថាមានអត្ថន័យប្រាកដបែបណាឲ្យច្បាស់។

ម៉្យាងទៀត បើរំឭកពីអតីតកាលរហូតបច្ចុប្បន្នក៏ឃើញថាមានប្រជាជនខ្មែរតិចណាស់ដែលបានដឹង និងចេះចាំទេវកថាកូរសមុទ្រទឹកដោះនេះបានហូរហែក្បោះក្បាយតាមដំណើររឿងឲ្យប្រាកដ។ ផ្ទុយទៅវិញរឿងរាមកេរ្តិ៍ខ្មែរដែលជាទេវកថានៃលទ្ធិព្រាហ្មណ៍ដូចគ្នា តែវានៅមានឥទ្ធិពលព្រមទាំងពេញនិយមក្នុងសង្គមខ្មែររហូតមក ការកត់ត្រាទុកជាឯកសារ (រាមកេរ្តិ៍ខ្មែរខ្សែទី១-១០ និងខ្សែទី៧៥-៨០) ហើយថែមទាំងបានលើកយកមកសំដែងជាសិល្បៈទស្សនីយភាពយ៉ាងល្អប្រណីតទៀតផង។ រីឯស្នាដៃស្រាវជ្រាវផ្សេងៗទាក់ទងនឹងទេវកថាកូរសមុទ្រទឹកដោះវិញឃើញថាមានបោះពុម្ពផ្សព្វផ្សាយហើយសេសសល់ខ្លះមកដល់ពេលនេះ តែភាគច្រើនជាភាសាបរទេស(បារាំង អង់គ្លេស...) ដែលជាឧបសគ្គក្នុងការប្រើប្រាស់ភាសាបរទេស និងការបកប្រែ។ ហេតុនេះហើយទើបនាងខ្ញុំខិតខំស្រាវជ្រាវឯកសារជាច្រើនទាក់ទងនឹងទេវកថាកូរសមុទ្រទឹក-ដោះ។តួយ៉ាងដូចជាឯកសារ "ទេវកថាកូរសមុទ្រទឹកដោះ" របស់លោក សេង សោត បោះពុម្ពឆ្នាំ ២០០៧ ជាសាស្ត្រាចារ្យនៃសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈបានកត់ត្រាដំណើររឿងដែលមានដើមហេតុឫសគល់ច្បាស់លាស់ជាបច្ច័យនាំដល់ពួកអសុរៈ និងពួកទេវៈ ព្រមព្រៀងគ្រវ៉ីរគ្នាកូរសមុទ្រទឹកដោះដើម្បីយកទឹកអម្រឹតផឹកឲ្យមានជីវិតអមតៈ។ នេះគ្រាន់នឹងជ្រាបជាព័ត៌មានទុកជាការសិក្សាស្វែងយល់ពីរឿងរ៉ាវពិត និងជាវិភាគទានក្នុងការសិក្សា ព្រោះកន្លងមកគេពុំដឹងពីហេតុជាដើមចមនៃរឿង។ ដំណើររឿងច្រើនតែផ្ដើមមកដល់ទីបញ្ចប់តែម្ដងដោយឯកសារខ្លះមិនបង្ហាញមូលហេតុដំបូងជាដើមចមថា ហេតុអ្វីបានជាសុខៗក្រុមអសុរៈ និងក្រុមទេវៈ អាចស្រុះស្រួលគ្នាស្វែងរកទឹកអម្រឹត? បើជាតុពិតសភាវៈទាំងពីរពួកនេះតែងតែប្រឆាំងគ្នាជានិច្ចតាំងពីកំណើតមកនោះ?

ដើម្បីបំភ្លឺចម្ងល់ និងតាមដានសេចក្តីពិតនៃទេវកថាកូរសមុទ្រទឹកដោះនេះយ៉ាងណានោះ សូមអញ្ជើញប្រិយមិត្ត និងអ្នកអានទាំងអស់អានដំណើររឿងតាមការដកស្រង់និទានរបស់លោកស្រី Vasundhara Filliozat ក្នុងឱកាសដែលលោកស្រីមកធ្វើបាឋកថានៅមហាវិទ្យាល័យបុរាណវិទ្យានៃសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈកាលពីឆ្នាំ២០០២ ដោយមានការកែសម្រួល និងដំណើរសង្ខេបដូចតទៅនេះ ៖

## I. សង្ខេបរឿង

តាំងពីដើមរៀងមក ពួកទេវៈ និងអសុរៈតែងតែមិនចុះសម្រុងគ្នាប៉ុន្តែពួកគេមានអានុភាពខ្លាំងពូកែដូចគ្នា។ ជានិច្ចកាលពួកគេតែងតែឈ្លោះទាស់ទែងគ្នាមិនចេះចប់មិនចេះហើយក្នុងបំណងដណ្តើមអំណាចគ្នាគ្រប់គ្រង។

ហេតុនេះនៅវេលាមួយ គូបដិបក្ខទាំងពីរក៏បានបើកការប្រយុទ្ធគ្នាយ៉ាងធំមួយក្នុងគោលបំណងដណ្តើមកាន់កាប់ និងគ្រប់គ្រងលើភពទាំងឡាយ។ នៅក្នុងសមរភូមិប្រយុទ្ធនាពេលនោះពោរពេញដោយសំឡេងកងរំពង កងទ័ពទេវៈបានសម្លាប់ពួកពលអសុរៈអស់ជាច្រើនពាន់នាក់ដោយអាវុធជាវ លំពែង និងព្រួញ...ប៉ុន្តែទ័ពអសុរៈទាំងនោះនៅតែអាចរស់រានមានជីវិតឡើងវិញព្រមទាំងអាចបន្តការប្រយុទ្ធ ហើយថែមទាំងបានសម្លាប់កងទ័ពទេវៈវិញអស់ជាច្រើនពាន់នាក់ទៀតផង។ ការណ៍នេះធ្វើឲ្យភាគីទេវៈឆ្ងល់យ៉ាងខ្លាំង ដោយរកមូលហេតុពិតពុំឃើញសោះ។ តាមពិតពលអសុរៈទាំងឡាយដែលស្លាប់ហើយអាចរស់ឡើងវិញបាន គឺដោយសារមានយក្សមួយឈ្មោះ សុក្រាចារ្យ ដែលជាគ្រូនៃពួកអសុរៈទាំងឡាយបានប្រើមន្តអាគមពិសេសជួយធ្វើឲ្យពលអសុរៈទាំងនោះរស់ឡើងវិញ។ “សុក្រាចារ្យ” ចេះវិជ្ជាមួយអស្ចារ្យលើសគេ សូម្បីតែពួកទេវៈក៏ពុំអាចប្រៀបផ្ទឹមបានដែរ។ វិជ្ជានោះគឺមន្តអាគមស័ក្តិសិទ្ធិប្រោះអ្នកស្លាប់ឲ្យរស់ឡើងវិញ។

នៅក្នុងសមរភូមិប្រយុទ្ធ “សុក្រាចារ្យ” ពុំដែលបានបង្ហាញខ្លួននៅចំពោះមុខជាសាធារណៈទេ។ ប៉ុន្តែគេតែងតែបានប្រារព្ធពិធីប្រោះពលអសុរៈទាំងឡាយដែលត្រូវកងទ័ពទេវៈសម្លាប់ឲ្យរស់ឡើងវិញភ្លាមៗក្នុងសមរភូមិ។ ផ្ទុយទៅវិញកងទ័ពទេវៈ ពុំមានសំណាងដូចពលអសុរៈសោះឡើយ។

ពលទេវៈទាំងនោះត្រូវសម្លាប់ជាបន្តបន្ទាប់ដោយទ័ពអសុរៈ រហូតធ្វើឲ្យចំនួនកងទ័ពនៃក្រុមទេវៈនេះកាន់តែខ្សត់ខ្សោយទៅៗ។ ដោយឃើញសភាពការណ៍មិនស្រួលបែបនេះ ក្រុមទេវៈបានប្រញាប់ប្រញាល់សុំពួកអសុរៈផ្អាកធ្វើសង្គ្រាមមួយរយៈសិន។

ក្រោយពីសង្គ្រាមត្រូវផ្អាក ក្រុមទេវៈបាននាំគ្នាប្រជុំពិភាក្សាក្នុងបំណងរិះរកមធ្យោបាយបែបណា ដែលអាចយកឈ្នះពួកអសុរៈបាន។ ក្រុមទេវៈបានគិតឃើញថាមានតែ “ទឹកអម្រឹត” មួយគត់ដែលអាចជួយឲ្យពួកទេវៈទាំងអស់មានជីវិតអមតៈ និងអាចយកជ័យជំនះ លើពួកអសុរៈបាន។ ប៉ុន្តែក្រុមទេវៈមិនអាចសម្រេចគោលបំណងដ៏ធំនេះតែគ្នាឯងបានទេ ប្រសិនបើគ្មានការចូលរួមពីពួកអសុរៈនោះ។ ហេតុនេះក្រុមទេវៈ បានសម្រេចចិត្តទៅបញ្ចុះបញ្ចូលក្រុមអសុរៈ ដើម្បីបើកការកូរសមុទ្រទឹកដោះរួមគ្នា ដើម្បីស្វែងរកទឹកអម្រឹត ហើយបានសន្យាថានឹងធ្វើការចែកទឹកអម្រឹតដែលទទួលបាននោះដល់អ្នកកូរទឹកសមុទ្រទាំងអស់គ្នា។ ដោយមានការលោភលន់ និងចង់បាន

ជីវិតអមតៈផងនោះ ពួកអសុរៈទាំងអស់ក៏សម្រេចចិត្ត យល់ព្រមសហការជាមួយក្រុមទេវៈ។ បន្ទាប់មកពួកគេក៏ចាប់ផ្ដើមបើកកិច្ចប្រតិបត្តិការកូរទឹកសមុទ្រដើម្បីស្វែងរកទឹកអម្រឹត។

ពេលនេះពួកគេទាំងពីរក្រុមបានចាប់ផ្ដើមធ្វើការជាមួយគ្នាយ៉ាងជិតស្និទ្ធដោយខិតខំរិះរកមធ្យោបាយបែបណា ដើម្បីធ្វើឲ្យប្រតិបត្តិការនៃការកូរទឹកសមុទ្រអាចដំណើរការទៅបាន និងទទួលបានជោគជ័យ។នៅទីបញ្ចប់ពួកគេទាំងពីរក៏បានមូលមតិគ្នា និងសម្រេចយកភ្នំមន្ទរៈមកធ្វើជាស្នូល ដើម្បីកូរទឹកសមុទ្រ និងបានយកពស់វាសុគី ដែលជាស្ដេចពស់រស់នៅបាតសមុទ្រមកធ្វើជាខ្សែពួរដើម្បីទាញបង្វិលស្នូល។ ការកូរសមុទ្រទឹកដោះនេះបានប្រព្រឹត្តទៅច្រើនដំណាក់កាល និងអស់រយៈកាលរាប់ពាន់ឆ្នាំ។ ជាដំបូងក្រុមទេវៈបានសម្រេចចិត្តនៅខាងក្បាលសត្វពស់ (ពាក់កណ្ដាលខ្លួនមកខាងក្បាល)។ ចំណែកឯពួកអសុរៈកាន់ពាក់កណ្ដាលខ្លួន មកខាងកន្ទុយ។ លុះស្រុះស្រួលគ្នារួចហើយពួកគេទាំងពីរក្រុមបាននាំគ្នាចាប់ផ្ដើមកូរទឹកសមុទ្រ។ ប៉ុន្តែនៅពេលការងារកូរទឹកសមុទ្រប្រព្រឹត្តទៅពាក់កណ្ដាលទី ស្រាប់តែភ្នំ មន្ទរៈផ្អៀងធ្វើឲ្យដំណើរការកូរទឹកសមុទ្រត្រូវផ្អាកជាបណ្ដោះអាសន្ន។ ពេលនោះពួកគេទាំងពីរក្រុមបានគិតថា មានតែព្រះវិស្ណុមួយអង្គគត់ដែលអាចជួយធ្វើឲ្យភ្នំមន្ទរៈឈរត្រង់ដូចដើមឡើងវិញ។ ដូចនេះពួកគេក៏សម្រេចចិត្តនាំគ្នាទៅពឹងព្រះវិស្ណុដែលជាអាទិទេពធំមួយអង្គក្នុងចំណោមអាទិទេពធំទាំង៣នៃលទ្ធិព្រហ្មញ្ញសាសនា (ព្រះសិវៈ ព្រះវិស្ណុ និងព្រះព្រហ្ម) ឲ្យមកជួយធ្វើអន្តរាគមន៍ ដើម្បីសម្រួលឲ្យការកូរសមុទ្រទឹកដោះនេះអាចប្រព្រឹត្តទៅបន្តទៀត។ ព្រះវិស្ណុទ្រង់បានបែងភាគជាសត្វអណ្ដើកធំមួយឈ្មោះ “កុម៌ៈ” មុជចុះទៅទ្រភ្នំមន្ទរៈពីក្រោម រហូតធ្វើឲ្យភ្នំអាចឈរត្រង់ដូចដើមឡើងវិញ។

ក្រោយពីភ្នំមន្ទរៈត្រូវបានបញ្ឈរត្រង់វិញហើយ ក្រុមទាំងពីរក៏ចាប់ផ្ដើមកូរទឹកសមុទ្របន្តទៀត។ នៅវគ្គទី២នេះក្រុមទេវៈបានសុំយកផ្នែកពាក់កណ្ដាលខ្លួនមកកន្ទុយវិញម្ដង ហើយឲ្យក្រុមអសុរៈកាន់ផ្នែកពាក់កណ្ដាលខ្លួនមកក្បាលសត្វពស់វិញ។ លើកនេះសកម្មភាពនៃការទាញបង្វិលស្នូលកូរមានសភាពងាយស្រួល និងមានសន្ទុះខ្លាំងជាងមុនដោយសារតែមានជំនួយពីសត្វអណ្ដើក “កុម៌ៈ” ដែលកំពុងទ្រពីក្រោមភ្នំ។ ការទាញបង្វិលភ្នំមន្ទរៈមានសន្ទុះកាន់តែខ្លាំងទៅៗបានធ្វើឲ្យសត្វទឹកទាំងឡាយ ដែលកំពុងស្ថិតនៅស្នូលកូរ ត្រូវដាច់ខ្លួនជាពីរ ឬបីកំណាត់បណ្ដាលមកពីកម្លាំងកួចខ្លាំងនៃទឹកដែល មានទាំងត្រីគ្រប់ប្រភេទ ដាច់ខ្លួនហើយវិលវល់ពេញផ្ទៃទឹក។

(នៅមានត) *លោកស្រី ម៉ៅ តាន់ណារី*

*អនុប្រធានការិ.នៃនាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សា*

| | |
|---|---|
| ទុកចិត្តខ្ញុំមើលដាក់ | ស្មើភ្នែកខ្វាក់ទាំងសងខាង |
| ឲ្យកូនគន់មើលតាង | ស្មើភ្នែកម្ខាងពុំពេញពីរ។ |

ច្បាប់កេរ្តិ៍កាល

# រឿងទាក់ដំរី

ឯកសាររបស់ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

ជាដំបូងសូមជំរាបថា ដំរីមានពីរបែប គឺដំរីភ្នំ និងដំរីរនាម ឬដំរីត្រែង។ ឯការទាក់ដំរីក៏មានពីរបែបដែរ។

ដំរីភ្នំមានរាងធំជាង ក្បាលខ្ពស់ជាងខ្លួន ដែលគេតែងជួបប្រទះនៅក្នុងខេត្តដែលមានភ្នំច្រើន ដូចជា **កំពត កំពង់ស្ពឺ ពោធិ៍សាត់**។ល។ ពួកដំរីម្យ៉ាងទៀតដែលមានរូបរាងតូចល្មមហើយក្បាល និងដងខ្លួនមានកម្ពស់ស្មើគ្នា ហៅថាដំរីរនាម ឬដំរីត្រែង។ គេច្រើនប្រទះឃើញនៅក្នុងខេត្ត**កំពង់ឆ្នាំង កំពង់ធំ សៀមរាប** និងក៏នៅតាមមាត់**ទន្លេសាប**ផងដែរ។

តាមធម្មតា គេមិនសូវទាក់ដំរីធំទេ គេច្រើនទាក់ដំរីតូចៗល្មមងាយនឹងផ្សាំងប្រើបាន។ ឯដំរីដែលគេត្រូវទាក់ហៅថា **បារាស**។ ពួកហ្មដំរីដែលត្រូវការចេញទៅទាក់ដំរី ត្រូវធ្វើពាក្យសុំអនុញ្ញាតពីចៅហ្វាយខេត្តដោយមានបង់ពន្ធផង។ សំបុត្រអនុញ្ញាតដែលរាជការមានសមត្ថកិច្ចចេញឲ្យនោះ មានដាក់ឈ្មោះអ្នកសុំទាក់ ចំនួនដំរីសុំទាក់និងកំណត់ពេលវេលា៣ខែគិតពីថ្ងៃចេញច្បាប់អនុញ្ញាតនោះថែមទាំងមានបម្រាមមិនឲ្យសម្លាប់ដំរីផង លើកលែងតែដំរីណារំលោភលើអ្នកទាក់ហួសកម្លាំងនិងការពារពុំឈ្នះ។ ប្រសិនបើមានការសម្លាប់ដំរី ត្រូវនាំយកភ្លុកនិងប្រអប់ជើងទៅប្ដឹងដល់រាជការដែលនៅជិតខាងគេ។

ពេលត្រឡប់មកពីទាក់វិញ ហ្មត្រូវនាំយកដំរីដែលទាក់បានទៅជូនរាជការឲ្យកាត់តម្លៃលក់ ហើយរាជការត្រូវហូតភាគខ្លះ ជាប្រយោជន៍ថវិកាជាតិ ទើបចេញសំបុត្រសម្គាល់ភិនភាគដំរីឲ្យម្ចាស់កាន់។

## របៀបទាក់ដំរី

ចំពោះរបៀបនេះ ហ្មនិយមចេញទៅទាក់នៅរដូវប្រាំង គឺគិតពីខែមាឃទៅខែពិសាខ។ មុននឹងចេញទៅទាក់ ពួកហ្មបបួលគ្នាទៅឲ្យបានច្រើនគឺពី១០នាក់ឡើងទៅ។លុះបានសំបុត្រអនុញ្ញាតរួចស្រេច គេត្រូវរៀបចំស្បៀងអាហារ មានអង្ករ ត្រីងៀត ត្រីឆ្អើរ ប្រហុក អំបិល ចាន ឆ្នាំង (ឆ្នាំងដីមិនយកទេខ្លាចបែក) ហើយដាក់គ្រណមឲ្យប្រពន្ធកាន់រៀងៗខ្លួន។ ប្រពន្ធហ្មទាំងឡាយដែលប្ដីចេញទៅទាក់ដំរី ត្រូវតមមិនឲ្យមានសហាយ មិនឲ្យលូកកកាយបាយនឹងដៃចេញពីឆ្នាំង មិនឲ្យគងវែកលើមាត់ឆ្នាំង សិតសក់ កាត់សក់យប់ គោះចាក់កំទេចហិបស្លាចោល លេងចាក់ចង្កេះគ្នា ឬគក់គ្នាក៏មិនបាន។ បើមិនកាន់គ្រណមទាំងនេះ មុខជាប្ដីនឹងមានគ្រោះថ្នាក់ដល់ស្លាប់ផងក៏មាន។

រួចហើយ ទើបហ្មរៀបចំគ្រឿងទាក់-ចាប់ ដូចជាព្រ័ត្រ[១] ប្រកាំ កង្វេរ ពូថៅ ក្រវិលសម្រាប់វាយជែង ស្នែងជើងរង ដងអញ្ចាម[២] ។ល។ ផ្ទុកលើខ្នងធ្លាក់ជាមួយនឹងគ្រឿងបរិភោគ។

---

[១] ធ្វើអំពីស្បែកគោ ឬក្របីចាស់ ដើម្បីឲ្យជាប់ប្រើបានដល់កូនដល់ចៅក៏មាន។

[២] ដងឫស្សីអមព្រ័ត្រសម្រាប់លូកទាក់ជើងដំរីព្រៃ។ ដងអញ្ចាមនេះ គេច្រើនប្រើតែនៅទីវាល តែដំរីរត់ចូលព្រៃ គេមិនប្រើទេព្រោះនាំទទើសទទែងណាស់។

ប៉ុន្តែរបស់ទាំងនេះ ផ្ទុកលើខ្នងធ្នាក់តែពីកាលធ្វើដំណើរទៅទេ តែដល់ព្រៃ គេទម្លាក់មកព្រយុងពីក្រោមពោះធ្នាក់វិញ ដើម្បីកុំឲ្យទទើសទទែងនៅពេលចូលព្រៃ និងនៅពេលជួបហ្វូងដំរីព្រៃ។ ហ្មនិងគង្វាលរើសយកថ្ងៃល្អឈ្នះសត្រូវ ខ្មោចបិសាចទើបហ៊ានចេញទៅ។ នៅតំបន់ខ្លះ អ្នកទាក់ដំរីធ្វើពិធីសែនព្រេនដល់ម្រេញគង្វាលនិងអ្នកតាបង់បត់សុំបើកព្រៃនិងសុំចេញទៅឲ្យមានជ័យជំនះផង។ របៀបសែនម្រេញគង្វាលមានប្រទាស១ បំពង់ទឹក១គូ កន្ទោង១ ស្នែងផ្លុំ១ កង្វេរ១ ពាន៣ថ្នាក់ ច្រមុ៨ រាជវតិជុំវិញពាន ម្លូ៥ ស្លា៥ បារី៥ បង្អែមឆ្វេង-ស្ដាំ និងសំពត់ស-ក្រហម។ លុះរៀបចំសព្វគ្រប់ហើយ ទើបគេនាំគ្នាចេញដំណើរទៅ។ ដំរីធ្នាក់ខ្លះមានស្នាមហើម ២-៣អន្លើ ដែលពួកហ្មវាយបោកនឹងកង្វេរឲ្យហើមសាច់ទុកជាមុន សម្រាប់ដល់ពេលដេញប្រយុទ្ធនឹងដំរីព្រៃ វាយលើស្នាមហើមស្រាប់នេះទើបធ្នាក់ឈឺរត់លឿនទាន់សភាពការណ៍ នៅលើខ្នងធ្នាក់នីមួយៗមានហ្មម្នាក់ទាមក្បាល កាន់ប្រកាំចាំតែទាក់ កិច្ចការអ្វីដទៃស្រេចលើគង្វាលដែលជិះនៅចង្កេះទាំងអស់។

កាលណាឈប់ទាក់ គង្វាលត្រូវមើលរៀបចំព្រ័ត្រប្រកាំនិងគ្រឿងទាក់ចាប់ទាំងឡាយធ្វើធ្នះឬតូបកម្ពស់ប្រមាណជា ៣ ឬ៤ម៉ែត្រពីដីដើម្បីដាក់គ្រឿងទាំងនេះ ខ្លាចក្រែងឆ្កែស៊ីត្រឡែង។ តូបនោះត្រូវធ្វើនៅក្រៅភូមិចម្ងាយប្រហែលជា ១០០ ឬ ១៥០ម៉ែត្រ។ តូបនេះបើស្រីមានផ្ទៃពោះដើរកាត់មុខនឹងមានអន្តរាយដល់ទារកក្នុងផ្ទៃ។

អំពីការទាក់ដំរីនេះ មិនមែនចូលព្រៃភ្លាមទាក់បានភ្លាមទេ ជួនកាលដើរដប់ម្ភៃថ្ងៃ មិនទាន់ប្រទះហ្វូងដំរីមួយផង។

នៅពេលចូលព្រៃ ហ្មមានអំណាចធំជាងគង្វាល។ គង្វាលត្រូវរៀបចំដំណេកហ្ម ការុងអង្ករទុកនៅចុងជើង ហើយខ្លួនឯងត្រូវដេកនៅចុងជើងហ្មផង។ គង្វាលត្រូវគោរពហ្មយ៉ាងក្រៃលែង សូម្បីតែចាប់បានសត្វដូចជាអណ្ដើក ទន្សង គង្វាលមិនហ៊ានអាស្រ័យពងទេ ត្រូវជូនទៅហ្មទាំងអស់ ខ្លួនអាស្រ័យបានតែសាច់។ នៅពេលដេកលក់ បើមានការណ៍អ្វី ហ្មមិនយកដៃកេះហៅគង្វាលទេ ក្រែងដំរីស្ដព្រៃតដៃនឹងធ្នាក់ ត្រូវយកជើងឈូសដាស់។ ឯដំរីធ្នាក់ ទោះជាឈ្មោលមានភ្លុកក្ដី ស្ដក្ដី មេក្ដី ក៏អាចធ្វើជាធ្នាក់ទាំងអស់បានឥតមានទាស់ទេ។ ពេលងូតទឹកក្នុងព្រៃ ហ្មមិនហ៊ានដុសក្អែលនឹងដៃ ឬ ដុសក្អែលពួតនឹងក្រមាទេ ខ្លាចក្រែងដំរីព្រៃបោកគង្វាលទម្លាក់ពីលើខ្នងធ្នាក់។

ពួកហ្មនាំគ្នារំពៃស្ដាប់សម្រែកដំរីតាមមាត់អូរ និងច្រកភ្នំដែលមានទឹក ក្រែងមានហ្វូងដំរីចុះផឹកទឹក។ នៅពេលដឹងថា មានដំរីនៅទីណាហើយ គេក៏ប្រញាប់ដណ្ដាំបាយបរិភោគឲ្យហើយស្រេច រួចសម្រួតអីវ៉ាន់មកដាក់ក្រោមពោះធ្នាក់វិញ ទើបបរសំដៅទៅរកហ្វូងដំរីព្រៃ។ (នៅមានត)

**លោក ចែម ផាន អធិការបឋមសិក្សា**
**(ចូលនិវត្តន៍)**



# ចិត្តវិទ្យាអប់រំ

## មាតាបិតាពុំមែនជាតុលាការ ពុំមែនជាឆ្មាំគុក តែជាអ្នកនាំផ្លូវសម្រាប់បុត្រធីតា (តចប់)

### ៥-<u>មាតាបិតា និងកិច្ចការអប់រំសង្គមសាធារណៈ</u>

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (១៩៩៣) ជំពូកទី៣ មាត្រា ៤៧ ចែងថា៖

*មាតាបិតាមានកាតព្វកិច្ចចិញ្ចឹមថែរក្សា និងអប់រំកូនឲ្យទៅជាពលរដ្ឋល្អ។*

*តាមទំនៀមទម្លាប់ខ្មែរកូនមានករណីយកិច្ចចិញ្ចឹមនិងបីបាច់ថែរក្សាមាតាបិតាដែលចាស់ជរា ។*

ចំពោះច្បាប់អប់រំនោះគឺកាន់តែជាក់ច្បាស់ ក្នុងជំពូកទី៧ មាត្រា ៣៦៖ សិទ្ធិ និងករណីយកិច្ចមាតាបិតា ឬអ្នកអាណាព្យាបាល *(ចម្លងយកតែវាក្យខណ្ឌពាក់ព័ន្ធ)*

................................................................................................................

*-សិទ្ធិចូលរួមយ៉ាងសកម្ម និងពេញលេញ នៅក្នុងការអភិវឌ្ឍស្តង់ដារអប់រំថ្នាក់ សាលារៀន និងថ្នាក់ជាតិ ដោយផ្ទាល់តាមរយៈតំណាងរបស់ខ្លួន។*

................................................................................................................

*-យកចិត្តទុកដាក់ផ្សារភ្ជាប់ សាលា គ្រួសារ និងសហគមន៍ ដើម្បីចូលរួមជួយបណ្តុះបណ្តាល និងកែលម្អបរិស្ថានសិក្សា។ (សៀវភៅស្តីពីច្បាប់អប់រំបោះពុម្ព ខែធ្នូ ឆ្នាំ២០០៧)*

យើងក៏នឹងបានដឹងថា មជ្ឈមណ្ឌលអប់រំ មានគ្រួសារ សាលារៀន និងសង្គម។ មាតាបិតាមិនត្រឹមតែជាម្ចាស់គ្រួសារ គឺជាម្ចាស់សង្គម និងជាម្ចាស់សាលារៀន ពីព្រោះថា «**ការអប់រំសម្រាប់ ទាំងអស់គ្នា ទាំងអស់គ្នាសម្រាប់ការអប់រំ**» *នេះជា គោលការណ៍សកល និងជាគោលនយោបាយ របស់រាជរដ្ឋាភិបាល* ។ សាលារៀនយើងបច្ចុប្បន្នមានសហគមន៍ចូលរួមនៅក្នុង

រចនាសម្ព័ន្ធគ្រប់គ្រង ដែលតម្រូវឲ្យមានសកម្មភាពរស់រវើកគ្រប់ពេលវេលា ដើម្បីកុលបុត្រកុលធីតារបស់យើងបានជាកូនល្អ សិស្សល្អ មិត្តល្អ និងសម្រាប់អនាគតជាពលរដ្ឋល្អ ។*«គ្មានសហគមន៍ចូលរួម ការអប់រំនឹងពិការ»* ។ ដូចនេះកំហុសរបស់សាលារៀន កំហុសរបស់សង្គម ក៏ជាកំហុសរបស់យើងជាមាតាបិតាផងដែរ។ អំពើផ្ដាំផ្ដងរបស់កូន ពុំមែនជាកំហុសដែលបង្កឡើងដោយមជ្ឈដ្ឋានដទៃទាំងស្រុងនោះឡើយ តែវាក៏ជាកំហុសរបស់យើងជាមាតាបិតាដែរ។ ចំពោះលទ្ធផលដែលកូនលោកអ្នកទទួលជោគជ័យ ជាសិស្សពូកែ ឬជាពលរដ្ឋថ្លៃថ្នូរ វាគឺជាស្នាដៃនៃការប្រឹងប្រែងអប់រំរបស់យើងទាំងអស់គ្នា។ សូមមេត្តាបោះបង់នូវទស្សនៈដែលថា កូនល្អដោយសារពូជអម្បូរគ្រួសារ(ពូជអញ) លុះកូនខូចគឺមកពីសាលារៀន មកពីសង្គម។ នេះជាការយល់ច្រឡំធំបំផុតដែលទទួលយកតែសេចក្ដីត្រូវមួយមុខ និងគេចវេះពីកំហុស។ បើយល់ដូច្នេះ លោកអ្នកជាមាតាបិតាច្បាស់លាស់ណាស់ថា ពិតជាមិនបានចូលរួមកិច្ចការអភិវឌ្ឍសហគមន៍ និងពុំមែនជាពលរដ្ឋរបស់សង្គម។ សូមកុំធ្វើអំពើប្រានខ្លួនចេញពីសង្គមដោយខ្លួនឯងបែបនេះ។

**សេចក្ដីបញ្ចប់**

សេចក្ដីវិភាគទាំងអម្បាលម៉ានខាងដើម ឆ្លុះបញ្ចាំងឲ្យឃើញនូវលទ្ធភាពគួរប្រព្រឹត្ត និងគួរចៀសវាងសម្រាប់មាតាបិតាចំពោះបុត្រធីតាតែប៉ុណ្ណោះ។ ប្រសិនបើយើងមានបំណងប្រាថ្នាថា៖ មួយជីវិតត្រូវតែមានគុណតម្លៃសម្រាប់ក្នុងគ្រួសារផ្ទាល់ គប្បីធ្វើខ្លួនជាផ្លូវថ្នល់សម្រាប់បុត្រធីតាជាទីស្រឡាញ់។ នោះការបារម្ភ ឬការលំបាកសម្រាប់ផ្ដល់ជាមរតកអស់កង្វល់ ហើយក៏ជាវិធី ឬជាដំណោះស្រាយយ៉ាងស័ក្ដិសិទ្ធិបំផុត។

ដូច្នេះ ទស្សនៈ **មាតាបិតា ពុំមែនជាតុលាការ ពុំមែនជាឆ្មាំគុក គឺជាផ្លូវថ្នល់សម្រាប់បុត្រធីតា** និងជាការតម្រង់ទិសឆ្ពោះទៅរកការលើកកម្ពស់ប្រសិទ្ធភាព នៃការប្រព្រឹត្តនូវព្រហ្មវិហារធម៌ទាំង៤នេះហើយ។ បានសេចក្ដីថាព្រហ្មវិហារធម៌ទាំង៤ (មេត្តា ករុណា មុទិតា និងឧបេក្ខា) នេះនៅតែជាមូលដ្ឋានគ្រឹះ សម្រាប់គ្រប់គ្រងបីបាច់រក្សាបុត្រភ្ញា គ្មានអ្វីជំនួសបានឡើយ និងទទួលបាននូវគ្រួសារគ្មានអំពើហិង្សា កូនមានភាពកក់ក្ដៅ គ្រួសារថ្លៃថ្នូរ សង្គមជាតិសុខដុម និងមាតុភូមិជាអាប្យប្រទេស៕

*លោក* **ផេង កែន**

*ប្រធានការិ.រដ្ឋបាលមន្ទីរអ.យ.ក.ខេត្តកំពង់ឆ្នាំង*

**ទស្សនវិជ្ជាអហិង្សា**

"នៅក្នុងជីវិត ខ្ញុំរៀនសូត្រពីអ្នកដែលរិះគន់ ច្រើនជាងពីអ្នកដែលសរសើរខ្ញុំ។"

**មហាត្មៈ គន្ធី**

# ចង្កុបំណងរបស់សិស្ស គឺចង់រៀនពូកែ

នៅក្នុងថ្នាក់រៀន នីមួយៗគេតែងដឹងនូវតម្រូវការរបស់សិស្ស ដែលបិតក្នុងបំណងប្រាថ្នាគ្រប់គ្នានោះ គឺចង់រៀនពូកែ។ ប៉ុន្តែ បំណងប្រាថ្នានេះឃើញថា មិនបានទៅដល់គោលដៅគ្រប់គ្នានោះទេ ព្រោះគេតែង ឃើញលទ្ធផលសិស្សទាំងអស់នោះដែលស្តែងចេញពី ពិន្ទុបានឲ្យដឹងថាមានសិស្សពូកែ, សិស្សរៀនមធ្យម និងក៏មានសិស្សរៀនយឺតផងដែរ។ ដោយឡែកចំពោះគោលបំណងរបស់គ្រូបង្រៀនតែងចង់ឲ្យសិស្សទាំងអស់ ឬហៅថាសិស្សមួយរយភាគរយ បានក្លាយទៅជាសិស្សពូកែ។ តើគ្រូបង្រៀនមានវិធីយ៉ាងណាក្នុងការដឹកនាំ ការបង្រៀនសិស្សឲ្យបានសម្រេចគោលបំណងនេះ?

ជាទូទៅ គ្រូបង្រៀននិងសិស្សតែងមានគោលបំណងដូចគ្នាបេះបិទតែម្តង គឺសិស្សម្នាក់ៗចង់រៀនពូកែ ហើយលោកគ្រូបង្រៀនក៏ចង់ឲ្យសិស្សទាំងអស់គ្នា បានរៀនពូកែដែរ។ ការចេញដំណើរពីដើមឆ្នាំសិក្សានេះក្នុងទីតាំងនិងពេលវេលាជាមួយគ្នា ឬដំណាលគ្នា អ៊ីចឹង តែក្នុងដំណើរប្រព្រឹត្តទៅវាចេះតែមានការ ឃ្លាតគ្នា រវាងសិស្សនិងគ្រូ ប្រៀបដូចជាក្រុមអត្តពលិករត់ប្រណាំងគ្នាដែលកាន់តែមានការឃ្លាតឆ្ងាយពីគ្នាយ៉ាងនោះដែរ ពោលគឺ វាមិនបានទៅទាន់គ្នា ដូចកាលពីការចេញដំណើរនោះទេ។

ផ្តើមចេញពីការបង្រៀន និងរៀនប្រកបដោយប្រសិទ្ធភាពចេញពីប្រភព នៃសតិអារម្មណ៍នោះបើតាម អ្នកចិត្តវិទ្យាខាងគរុកោសល្យ បានឲ្យដឹងថា៖ អ្នកបង្រៀនក៏មានចិត្តចង់បង្រៀន រីឯអ្នករៀនក៏មានចិត្តចង់រៀន។ ប៉ុន្តែចំពោះគ្រូបង្រៀនគេតែងបានដឹងថា គាត់មានចិត្តចង់បង្រៀនសិស្ស ព្រោះការបង្រៀនជាអាជីពរបស់គាត់ ហើយដែលមានកិច្ចសន្យាចំពោះក្រសួងផង។ ដោយឡែក សម្រាប់សិស្សតើត្រូវធ្វើយ៉ាងណាឲ្យខ្លួនឯងចង់រៀន? តើខ្លួនឯងចង់រៀនគ្រប់មុខវិជ្ជាដែរឬទេ? សំណួរដ៏ល្អនេះគឺនៅលើគ្រូបង្រៀនជាអ្នកឆ្លើយ ថាតើគាត់ត្រូវធ្វើយ៉ាងណាឲ្យសិស្សចង់រៀន មុខវិជ្ជាដែលគាត់បង្រៀននោះ?។

ទម្លាប់កន្លងមក តាមរយៈគម្រោងកែលម្អគុណភាពអប់រំពីឆ្នាំ១៩៩៩ ដល់ឆ្នាំ២០០៣គេឃើញមេរៀនមួយដែលគ្រូបង្រៀនទទួលយកទៅអនុវត្តប្រកបដោយប្រសិទ្ធភាពក្នុងការបង្រៀននោះគឺ ”ធ្វើឲ្យសិស្សរៀនបានប្រកបដោយជោគជ័យ”។ គេតែងយល់ច្បាស់ថា កាលណាសិស្សរៀនបានទទួលជោគជ័យវាកាន់តែធ្វើឲ្យសិស្សនោះកាន់តែ ខំប្រឹងប្រែងរៀនថែមទៀត គឺរៀនដោយសប្បាយចិត្តនិងពេញចិត្ត ព្រមទាំងមានចិត្តចង់រៀនបន្តទៀត ប្រកបដោយការស្មោះស្ម័គ្រ ការឧស្សាហ៍ព្យាយាមស្រាវជ្រាវយ៉ាងស្វិតស្វាញបំផុត។ នៅពេលដែលសិស្សនោះខិតខំប្រឹងប្រែងរៀនសូត្រដោយការផ្ចិតផ្ចង់ និងយកចិត្តទុកដាក់ខ្ពស់នោះ ភាពឆ្លាតវាងវៃ និងភាពពូកែកាន់តែ

កើតមានឡើងយ៉ាងពិតប្រាកដ។ ជាពិសេសសិស្សចង់ទទួលបានជោគជ័យថែមទៀត និងចង់បានកិត្តិយសដែលចេញពីការសរសើរពីគ្រូបង្រៀនផងដែរ។ប៉ុន្តែត្រង់ចំណុចមេរៀនឬខ្លឹមសារនៃកិច្ចការឬសំណួរសម្រាប់ធ្វើឲ្យសិស្សទទួលបានជោគជ័យនោះដោយការច្នៃយ៉ាងណាៗនោះវាបិតនៅលើគ្រូតែម្ដង។

បន្ទាប់ពីនេះយើង នឹងបង្ហាញនូវការធុញថប់ តាមរយៈអារម្មណ៍ មិនចង់រៀនរបស់សិស្សម្ដងវិញ គឺវាបណ្ដាលមកពីការរៀន មិនបានជោគជ័យ។ បានសេចក្ដីថា សិស្សធ្វើកិច្ចការ ឬលំហាត់អនុវត្តមិនត្រូវ ឬហៅថាខុសជាញឹកញាប់ ដោយបានទទួលពិន្ទុទាប។ ភាពបរាជ័យនេះហើយដែលធ្វើឲ្យកើតមានការស្ដីបន្ទោស ឬការបង្អាប់បន្ដុះបន្ដាបបន្ថោកធ្វើឲ្យអាប់មុខ អាប់មាត់ បណ្ដាលឲ្យបាត់បង់សេចក្ដីក្លាហាន បាត់ទំនុកចិត្តនិងកើតមានការធុញទ្រាន់ក្នុងការសិក្សា រហូតដល់ការលែងចង់រៀនទៀតផង។ ទន្ទឹមនេះដែរសិស្សប្រភេទនេះតែងមាន អវត្តមានជាច្រើនដងក្នុងមួយខែៗដែលរឹតតែបណ្ដាលឲ្យ សមត្ថភាពរបស់ខ្លួនធ្លាក់ទៅក្នុងសភាពងងឹត និងរៀនមិនទាន់គេ រហូតដល់បោះបង់ការសិក្សាទាំងកណ្ដាលឆ្នាំក៏ថាបាន។

ករណីនេះហើយទើបគម្រោងកែលម្អគុណភាពអប់រំកន្លងមកបានពិភាក្សាជាមួយគ្រូបង្រៀនក្នុងការដាក់កិច្ចការឲ្យសិស្សទៅតាមក្រុមនីមួយៗត្រូវឲ្យបានសមស្របនឹងសមត្ថភាពរបស់ពួកគេ។ ពេលពួកគេបានបំពេញការងារដោយត្រឹមត្រូវតាមគោលបំណងនៃប្រធានបទដែលគ្រូដាក់នោះហើយ ដែលបញ្ជាក់ថាពួកគេបានទទួលជោគជ័យជាបណ្ដើរៗជាជំហានឆ្ពោះទៅកាន់ភាពជាសិស្សពូកែនិងជាធនធានមនុស្សដ៏ឧត្ដមសម្រាប់អនាគតមាតុភូមិយើង៕

*លោក* **លី ហាក់សេង** *អតីតអធិការបឋមសិក្សា*

*(មន្ត្រីចូលនិវត្តន៍)*

ឆ្នាំខ្មែរមាន ១២គឺៈ ជូត(កណ្ដុរ) ឆ្លូវ(គោ) ខាល(ខ្លា) ថោះ(ទន្សាយ) រោង(ពស់វែក) ម្សាញ់(ពស់ក្រាយ) មមី(សេះ) មមែ(ពពែ) វក(ស្វា) រកា(មាន់) ច(ឆ្កែ) កុរ(ជ្រូក) ។

ខ្មែរបុរាណបានតែងកាព្យ សម្រាប់រាប់ឆ្នាំដូចមានតទៅៈ

-កណ្ដុរ បងគោ ខ្លាធំជ្រងោ លោតចាប់ទន្សាយ ពស់វែកច្រឡំពស់ក្រាយ សេះលោតបំផាយ បោលមុនពពែ ស្វាឪលោតចាប់មាន់ថៃ ប្រទះលើឆ្កែ ឆ្កែបោលមុនជ្រូក ។

**សមាជិកិន គ្លួខន្ធន**

**ទស្សនាវដ្ដី ពន្លឺពុទ្ធចក្រ លេខ២៦**

**(១៩៦៧)**

# បំណងរបស់គ្រូបង្រៀន គឺសិស្សឡើងថ្នាក់ ប្រកបដោយគុណភាព

ការងាររបស់គ្រូបង្រៀន គឺជាការងារសតិអារម្មណ៍ដែលមនុស្សម្នាក់ៗ តែងមានចិត្តគំនិត និងសកម្មភាពប្លែកៗគ្នា។ ពីមួយឆ្នាំទៅមួយឆ្នាំគ្រូបង្រៀនបានទទួលសិស្សថ្មីជាបន្តទៅតាមជំនាន់នីមួយៗក្នុងកម្រិតថ្នាក់ដដែលនោះក៏គ្រូបង្រៀនបានយល់ថា សិស្សមានលក្ខណៈប្លែកៗគ្នាដែរ។ ទន្ទឹមនេះដែរ ចំពោះវត្ថុបំណងរបស់គ្រូបង្រៀនតែងចង់បាន លទ្ធផលល្អនៃការរៀនរបស់សិស្សគឺនៅចុងឆ្នាំសិក្សា សិស្សបានឡើងថ្នាក់ ឬបានប្រឡងជាប់ច្រើននិងប្រកបដោយគុណភាពផង។

គ្រូបង្រៀនតែងមានការសប្បាយរីករាយចិត្តយ៉ាងខ្លាំងចំពោះស្នាដៃ របស់គាត់ ដែលស្ដែងចេញពីការងារបង្រៀនសិស្ស ដោយសិស្សរបស់គាត់បានឡើងថ្នាក់ច្រើន ឬប្រឡងជាប់ច្រើន ហើយដែលមជ្ឈដ្ឋានទូទៅបានពោលពាក្យកោតសរសើរ ថាសិស្សគាត់រៀនពូកែ។ ចំពោះសិស្សរៀនពូកែនេះ គឺជាកិត្តិយស មុខមាត់គ្រូបង្រៀនដែលបង្ហាញថា ការបង្រៀនរបស់គាត់បានល្អ។ នេះជាកិត្តិយស និងកេរ្តិ៍ឈ្មោះរបស់គ្រូបង្រៀនទាំងនៅក្នុងសាលារៀន និងទាំងនៅតាមសហគមន៍នៃមជ្ឈដ្ឋានមាតាបិតាសិស្សផងដែរ។

ផ្ទុយទៅវិញ ប្រសិនបើគ្រូបង្រៀនណាម្នាក់ ដែលមានសិស្សភាគច្រើន មិនចេះហើយមានការត្រួតថ្នាក់ច្រើន ឬប្រឡងមិនសូវជាប់ ដូចថ្នាក់គេឯទៀតនោះ គឺជាក្ដីកង្វល់របស់គ្រូបង្រៀននោះពិតប្រាកដ។ ព្រោះគេយល់ថា ការបង្រៀនរបស់គ្រូនិងការរៀនរបស់សិស្សវាមានការទាក់ទងគ្នា ដែលគេតែងនិយាយថា គ្រូយ៉ាងណាសិស្សក៏យ៉ាងនោះដែរ។ ឬគេនិយាយថា គ្រូល្អ សិស្សពូកែ គ្រូអន់សិស្សខ្សោយ....។

ឋិតក្នុងអារម្មណ៍ដែលផ្សារភ្ជាប់នឹងកិត្តិយសផ្ទាល់ខ្លួនរបស់គ្រូបង្រៀនយ៉ាងនេះហើយទើបគេដឹងថា គ្រូបង្រៀនណាក៏ដូចជាគ្រូបង្រៀនណាដែរ តែងមានបំណងចង់ឲ្យសិស្សរបស់ខ្លួនរៀនពូកែ បានឡើងថ្នាក់ និងប្រឡងជាប់បានច្រើនជារៀងរាល់ឆ្នាំហើយប្រកបដោយគុណភាពផង។ ដើម្បីបានសម្រេចនូវបំណងនេះគ្រូបង្រៀនបានបំពេញកិច្ចការដែលជាតួនាទីស្នូលរបស់គាត់ដូចតទៅ៖

១. **ស្រឡាញ់មុខរបរបង្រៀនសិស្ស** : គ្រូបង្រៀនមានចំណង់ចំណូលចិត្តក្នុងការបង្រៀនសិស្ស ម្ល៉ោះហើយគាត់ជាមនុស្សឧស្សាហ៍ ឬស៊ីសរហែង គោរពពេលវេលានិងភារកិច្ចរបស់គាត់បានខ្ជាប់ខ្ជួន ព្រមទាំងមានការច្នៃប្រឌិត ផលិតឯកសារនិងសម្ភារៈសម្រាប់បង្រៀនសិស្ស។ ជាមួយនេះដែរ គាត់បានរៀបចំបន្ទប់រៀនបានល្អ និងគ្រប់គ្រងសិស្សប្រកបដោយវិន័យល្អទៀតផង។

២. **ស្រាវជ្រាវឯកសារ** : គ្រូបង្រៀនជាអ្នក ស្វ័យសិក្សាគឺរៀនផ្ទាល់ខ្លួនជារៀងរហូត ដូចគេតែងនិយាយថា " បើនៅតែបង្រៀនសិស្ស គឺត្រូវនៅតែបន្តស្រាវជ្រាវ និងរៀនខ្លួនឯងជានិច្ច "។ គ្រូបង្រៀនជាអ្នកឧស្សាហ៍ និងព្យាយាមអានសៀវភៅច្រើនផង, ការប្រជុំបច្ចេកទេសដកស្រង់បទពិសោធន៍ផង និងជាអ្នកសន្សំនូវសម្ភារៈនានា សម្រាប់ទ្រទ្រង់ការបង្រៀននិងរៀនទៅតាមខ្លឹមសារនៃមេរៀន ស្របទៅតាមកម្មវិធីសិក្សា នៃកម្រិតថ្នាក់របស់គាត់។

៣. **ធ្វើកិច្ចតែងការបង្រៀន** : កិច្ចតែងការបង្រៀនគឺជាផែនការរបស់គ្រូ សម្រាប់បំពេញទៅតាមខ្លឹមសារមេរៀននីមួយៗ។ ជាពិសេសកិច្ចតែងការបង្រៀនត្រូវធ្វើរាល់ថ្ងៃ និងគ្រប់មុខវិជ្ជាដែលត្រូវបង្រៀន។ ព្រោះកិច្ចតែងការបង្រៀននីមួយៗតែងមានជំហានទាំង៥នៃការបង្រៀនដែលផ្ទុកទៅដោយខ្លឹមសារ សកម្មភាពគ្រូ និងសកម្មភាពសិស្ស ព្រមទាំងមានការវាស់វែងនូវពេលវេលាទៀតផងដែរ។

៤. **ដាក់កិច្ចការឲ្យសិស្សធ្វើ** : គឺជាការងារត្រួតពិនិត្យទៅតាមដំណាក់កាលនៃការបង្រៀន ព្រោះគ្រូបង្រៀនចង់ដឹងពីសមត្ថភាពសិស្សដែលទទួលបានពុទ្ធិទាំងឡាយ ដែលគាត់បានបង្រៀន។

៥. **ការរៀបចំបញ្ជីនានា** : បញ្ជីហៅឈ្មោះសិស្ស និងបញ្ជីស្រង់ពិន្ទុគឺជារឿងសំខាន់សម្រាប់ការបង្រៀនសិស្ស។ ជាពិសេសគ្រូបានបូកសរុបពិន្ទុប្រចាំខែ និងប្រចាំឆមាសព្រមទាំងពិន្ទុដំណាច់ឆ្នាំ ជាចាំបាច់បំផុត។

៦. **ជួយសិស្សរៀនយឺត** : ក្នុងថ្នាក់រៀននីមួយៗតែងមានសិស្សរៀនយឺត។ ដូច្នេះគ្រូបង្រៀនតែងគិតពីសិស្សដែលរៀនយឺត ដើម្បីរកវិធានការជួយសិស្សរៀនយឺតឲ្យរៀនបានទាន់គេ និងរៀនបានពូកែ។

សរុបមកសកម្មភាពដោយសង្ខេបរបស់គ្រូបង្រៀនទាំង៦យ៉ាងនេះហើយដែលជាគន្លឹះធ្វើឲ្យសិស្សរបស់គាត់ក្នុងថ្នាក់ទាំងមូលរៀនបានពូកែ បានឡើងថ្នាក់ ឬបានប្រឡងជាប់នៅចុងឆ្នាំសិក្សាប្រកបដោយគុណភាពនិងប្រសិទ្ធភាព៕

*លោក* **លី ហាក់សេង**

*អតីតអធិការបឋមសិក្សា (មន្ត្រីចូលនិវត្តន៍)*

| | |
|---|---|
| វិជ្ជាទុកជាមិត្តក្នុងខ្លួន | តាមថែធូនយើងរាល់វេលា |
| មិនមែនដូចមិត្តផងនានា | ជួយបានតាមគ្រាម្ដងម្កាលឡើយ ។ |
| វិជ្ជាឲ្យគុណសំខាន់ណាស់ | គួរតែក្មេងចាស់កុំតោះតើយ |
| បើរៀនចេះដឹងគ្រប់គ្នាហើយ | កុំភ័យព្រួយឡើយពីទ្រព្យធន។ |

**ព្រះសាសនមុនី កិម ត្រូវ**




## តើសាលារៀនរៀបចំឲ្យសិស្សឡើងថ្នាក់ និងត្រួតថ្នាក់តាមរបៀបយ៉ាងណា?

គ្រូបង្រៀនផ្ទាល់ជាអ្នកទទួលបន្ទុកថ្នាក់ ហើយក៏ជាអ្នកសម្រេច នូវលទ្ធផលនៃការរៀនរបស់សិស្ស ដើម្បីឆ្លើយតបនិងបញ្ហា២យ៉ាងគឺ : ឲ្យសិស្សឡើងថ្នាក់ និងឲ្យសិស្សត្រួតថ្នាក់ ។ តើការវាស់វែង អំពីសមត្ថភាពសិស្សនោះគ្រូបង្រៀនត្រូវធ្វើដូចម្តេច?

ជាធម្មតា គ្រូបង្រៀនសិស្សក្នុងកម្រិតបឋមសិក្សាប្រចាំថ្នាក់នីមួយៗ តែងស្គាល់សិស្ស ដូចឃើញច្បាស់នូវក្រឡាបាតដៃរបស់ខ្លួនដែរ។ ជាពិសេសគ្រូបានដឹងថា សិស្សណារៀនពូកែ សិស្សណារៀនមធ្យម និងសិស្សណារៀនខ្សោយ យ៉ាងជាក់លាក់បំផុត។ ព្រោះគ្រូបានដាក់កិច្ចការឲ្យសិស្សធ្វើរាល់ថ្ងៃផង និងតាមរយៈសំណួរទាក់ទងនឹងមេរៀនផង។

ទន្ទឹមនឹងការស្គាល់សិស្សនេះ វាក៏ស្តែងឡើងតាមរយៈពិន្ទុលើសំណួរត្រួតពិនិត្យ និងការប្រឡងផងដែរ។ ដូចនេះដើម្បីទទួលបានពិន្ទុដែលតំណាងឲ្យសមត្ថភាពសិស្សក្នុងការកំណត់ឲ្យសិស្សបានឡើងថ្នាក់ ឬក៏ឲ្យសិស្សត្រួតថ្នាក់នោះ កន្លងមកនៅតាមសាលារៀនគេដឹងថាគ្រូបង្រៀនរៀបចំកិច្ចការឲ្យសិស្សធ្វើដូចជា៖

**១. សំណួរផ្ទាល់មាត់** : ក្នុងដើមម៉ោងសិក្សាគ្រូឆ្លៀតហៅសិស្សឲ្យទៅឈរជិតតុរបស់គាត់ ហើយគាត់សួរអំពីខ្លឹមសារមេរៀន មួយសំណួរ ឬពីរសំណួររួចគ្រូដាក់ពិន្ទុក្នុងបញ្ជីពិន្ទុប្រចាំខែ។ គ្រូសួរសិស្សប្រហែលជា ៣ឬ៤នាក់ប៉ុណ្ណោះមុននឹងបង្រៀនមេរៀនថ្មី។

**២. សំណួរត្រួតពិនិត្យ** : ជាប្រភេទសំណួរសរសេរដែលគ្រូបង្រៀនរៀបចំតាមមុខវិជ្ជានីមួយៗ សម្រាប់ដាក់ពិន្ទុប្រចាំខែឲ្យសិស្ស។ គ្រូយកទៅធ្វើកំណែ និងដាក់ពិន្ទុរួចទើបយកមកចែកសិស្សវិញ រួចហៅឈ្មោះសិស្សឲ្យឆ្លើយប្រាប់ពិន្ទុដើម្បីបានដាក់ក្នុងបញ្ជីជារៀងរាល់ខែ។

**៣. ការប្រឡងឆមាស** : ក្នុងមួយឆ្នាំសិក្សាតែងមានការប្រឡងឆមាស២ដង គឺឆមាសទី១ និងឆមាសទី២។ គ្រូបង្រៀនបានប្រកាសប្រាប់សិស្សឲ្យដឹងអំពីការកំណត់កាលបរិច្ឆេទនៃការប្រឡងឆមាសបានជាក់លាក់ដើម្បីឲ្យសិស្សបានដឹង ហើយមានការត្រៀមរៀនសូត្រនិងមិនអវត្តមាន។ ការប្រឡងឆមាសនេះក៏បានប្រព្រឹត្តទៅលើគ្រប់មុខវិជ្ជាដែរ។

**៤. លទ្ធផលដំណាច់ឆ្នាំសិក្សា** : ចំពោះលទ្ធផលនៅដំណាច់ឆ្នាំសិក្សា គឺមានការបូកសរុបមធ្យមភាគនៃពិន្ទុគ្រប់ខែទាំងអស់រួចចែកនឹងចំនួនខែ ទើបរកឃើញពិន្ទុខែប្រចាំឆ្នាំ។ រីឯពិន្ទុនៃការប្រឡងឆមាសទី១ បូកនិងឆមាសទី២រួចចែកនឹង២ វាជាមធ្យមភាគផ្នែកខាងឆមាសរបស់ឆ្នាំសិក្សា។ បន្ទាប់មកក៏យកពិន្ទុជាមធ្យមភាគខែបូកនឹងពិន្ទុមធ្យមភាគឆមាស រួចចែកនឹង២ទើបរកឃើញលទ្ធផលចុងឆ្នាំ ថាតើមានសិស្សប៉ុន្មាននាក់បានជាប់មធ្យមភាគ និងសិស្សប៉ុន្មាននាក់ធ្លាក់មធ្យមភាគ។ ចំពោះសិស្សដែលជាប់មធ្យមភាគនោះហើយដែលត្រូវឡើងថ្នាក់ជាស្វ័យប្រវត្តិ។ ចំណែកឯសិស្សដែលបិតក្រោមមធ្យមភាគនោះ គឺជាសិស្សត្រូវត្រួតរៀនថ្នាក់។ ប៉ុន្តចំពោះសាលារៀនជាទូទៅតែងមានការសន្តោសប្រោសប្រណីដល់សិស្សដែលបិតក្រោមមធ្យមភាគ គឺចង់ឲ្យសិស្សទាំងនោះបានឡើងថ្នាក់នឹងគេដែរ ព្រោះគ្រូមានមនោសញ្ចេតនាអាណិតនិងស្រឡាញ់សិស្ស។ ដូច្នេះនៅជិតដល់ពេល បើកបវេសនកាលចូលរៀនឆ្នាំសិក្សាថ្មី សាលារៀនបានរៀបចំការប្រឡងសិស្សដែលបិតក្រោមមធ្យមភាគនោះឲ្យមានជម្រើសសាជាថ្មីទៀត ដើម្បីឲ្យសិស្សទាំងនោះបានឡើងថ្នាក់នឹងគេដែរ។ ប៉ុន្តែគ្រូបង្រៀនបានស្គាល់ពីសមត្ថភាពសិស្សដែលរៀនអន់ពេក គឺត្រូវរៀនត្រួតថ្នាក់ជាស្វ័យប្រវត្តិ។

ទាំងអស់នេះគឺជាក្ដីមេត្តារបស់គ្រូចំពោះសិស្ស ព្រោះគ្រូបង្រៀនចង់ឲ្យសិស្សឡើងថ្នាក់ឲ្យបានច្រើននេះក៏ជាកិត្តិយសមុខមាត់របស់គ្រូបង្រៀនដែរ។ ជួនកាលព្រោះតែចង់ឲ្យសិស្សជាប់ច្រើនគ្រូក៏ចេះតែបង្កើនពិន្ទុសេះហោះដល់សិស្ស រហូតដល់មានមតិរិះគន់ថា សិស្សឡើងថ្នាក់ដោយខ្វះគុណភាពទៀតផង។ សកម្មភាពទាំងអស់នេះហើយដែលគេដឹងថាកន្លងមក គឺជាចំណាត់ការសម្រាប់ឲ្យសិស្សឡើងថ្នាក់ និងត្រួតថ្នាក់នោះ។

*លោក* **លី ហាក់សេខ**

*អធិការបឋមសិក្សា (មន្ត្រីចូលនិវត្តន៍)*

| | | |
|---|---|---|
| ▪ កុំធ្វើចេះ | ចេះធ្វើល្ងង់ | ល្ងង់បានល្អ |
| បបរភរ | ភរក៏ដោយ | ឲ្យពេញពោះ |
| | របបខ្មៅ | ខ្មៅធ្វើចេះ ឆ្លេះកេរ្តិ៍ឈ្មោះ |
| | នៅមាត់ជ្រោះ | រស់ប្រយ័ត្ន សត្វបិសាច ។ |
| ▪ សកអណ្ដាត | ឆ្លាតទ្រឹស្តី | អ្វីបដិវត្តន៍? |
| ច្បាប់នៅមាត់ | មាត់ដាក់ទិស | ម្ចឹសភ័យខ្លាច |
| | មហាលោតផ្លោះ | អស្ចារ្យណាស់ ច្បាស់អំណាច |
| | ច្បាប់គេកាច | អាចសម្លាប់ ស្លាប់តែហោង។ |

សំឡេងសាដៀវ **ម៉ៅ អាយុទ្ធ**

# អំពីសិលាចារឹកនៃប្រទេសកម្ពុជា

តាមចំនួន និងបរិមាណ សិលាចារឹកប្រទេសកម្ពុជា ជាមរតកនៃសិលាចារឹកសំខាន់ និងប្រកបដោយសំបូរភាពជាងគេមួយនៅលើពិភពលោក ប្រសិនបើធៀបសិលាចារឹកកម្ពុជា ទៅនឹងបណ្ដាឯកសារសិលាចារឹកនៃប្រទេសដទៃទៀត។

នៅក្នុងបញ្ជីដ៏ធំមួយ រៀបចំដោយសាស្ត្រាចារ្យ ហ្ស៊ក សឺដេស (Georges Coedès. Inscription du Cambodge. Vol.XVIII. Paris 1966, Pages 73-255) គេប្រទះឃើញមានសិលាចារឹកកម្ពុជាទាំងអស់ ចំនួន ១.០០៥។ នៅឆ្នាំ១៩៧១ លោកសាស្ត្រាចារ្យ ក្លូដ ហ្សាក់ (បន្តពីលោក ហ្ស៊កសឺ-ដេស) ដែលជាអ្នកស្រាវជ្រាវសិលាចារឹកកម្ពុជាមួយរូបបានចុះផ្សាយក្នុងអត្ថបទរបស់លោកថា គេបានរកឃើញសិលារឹកចំនួន៩៥ទៀត (Claudes Jacques, supplement au tome VII des Inscriptions. Cambodge BEFEO.t.L VIII.1971) ហើយនៅឆ្នាំ១៩៨៨ លោកបានបញ្ជាក់បន្ថែមក្នុងអត្ថបទថ្មីមួយទៀតថា សិលាចារឹកប្រទេសកម្ពុជា មានចំនួនទាំងអស់ ១១៥០ (Claudes Jacques, revue "Dossier. Histoire et Archéologie". No.125. Paris 1988)។ ជាលើកទីមួយ អ្នកប្រាជ្ញជនជាតិ ហូឡង់មួយរូបនាម ហេនរិច គែន (Heinrich Kern) បានបោះពុម្ពផ្សាយអំពីអត្ថបទសិលាចារឹកខ្លះ ស្ដីពីកម្ពុជា នៅឆ្នាំ១៨៧៣។ បន្ទាប់ពីការបោះពុម្ពផ្សាយសិលាចារឹកកម្ពុជា ដោយអ្នកប្រាជ្ញបារាំងខាងភាសាសំស្ក្រឹតនាម អូហ្គូស្ដ បាថ (Auguste Bath) និងអាបែល ប៊ែរហ្គែញ (Abel Bergaigne) និងដោយលោក អែម៉ូនីញេរ (M. Aymonier) ដោយលោក លុយណេ ដឺឡាហ្សុង គីយែរ ( Lunet de la jonquière. Inventaire descriptive des monuments du cambodge. (3Vol, Paris 1902-1911) ព្រមទាំងដោយសារការប្រឹងប្រែងឥតសំចៃកម្លាំងពីសំណាក់សាលាបារាំងចុងបូព៌ា (Ecole Française d'Extrême-Orient) ចំនួនសិលាចារឹក ប្រទេសកម្ពុជា ដែលគេបានរកឃើញ និងបោះពុម្ពផ្សាយ ក៏កាន់តែលូតលាស់ជាអចិន្ត្រៃយ៍ រហូតមកដល់សព្វថ្ងៃ។ នាសម័យបច្ចុប្បន្ន ការងារស្រាវជ្រាវ និងបោះពុម្ពផ្សាយសិលាចារឹកដែលគេបានរកឃើញថ្មីៗ កំពុងប្រព្រឹត្តទៅនៅប្រទេសកម្ពុជា ប្រទេសបារាំង ប្រទេសថៃឡង់។ សម័យកាលនៃបុរាណសិលាចារឹកកម្ពុជាគឺលាតសន្ធឹងតាំងពីសតវត្សទី៦ ដល់ទី១៤ នៃ គ.ស. បានសេចក្ដីថា ចាប់ផ្ដើមតាំងពីសម័យកាលនៃរាជាណាចក្រនគរភ្នំ ឬហ្វូណន (គឺជាឈ្មោះដើមនៃប្រទេសកម្ពុជា) រហូតដល់សម័យកាលខាងចុងនៃចក្រភព "កម្ពុជទេស" (Kambujadeça)។

សិលាចារឹកចាស់ជាងគេ សរសេរជាភាសាខ្មែរ គឺសិលាចារឹកអង្គរបូរី (K.600) ដែលមានដាក់កាលបរិច្ឆេទឆ្នាំ៥៣៣ មហាសករាជ ត្រូវគ្នានឹង ៦១១ គ.ស.។ ក្រៅពីសិលាចារឹកមួយចំនួននៅអង្គរបូរី ដូចជាសិលាចារឹកវត្តថ្លែង (កូសាំងស៊ីន) k.1, សិលាចារឹកវត្តពោធិវង្សលើ (កូសាំងស៊ីន) k.11, សិលាចារឹកអង្គរបូរី k25, សិលាចារឹកព្រះវិហារធំ (កំពង់ចាម) k.520. សិលាចារឹកទួលវត្ត

គំនូរ (តាកែវ) K.557. សិលាចារឹកទួលអង្គ (តាកែវ) K.559, ដែលបានបាត់កាលបរិច្ឆេទ មានអក្ខរាវិរុទ្ធចាស់បុរាណជាងសិលាចារឹក K.600 ទៅទៀត។ គឺនៅលើមូលដ្ឋាននៃអក្ខរាវិរុទ្ធនេះហើយ ដែលគេសន្និដ្ឋានបានថា សិលាចារឹកជាភាសាខ្មែរ បានត្រូវចារឡើងនៅសតវត្សទី៦។

តាមគំនូសផែនទីផ្សេងៗ រៀបចំឡើងដោយលោក ហង់រី ប៉ារម៉ង់ទីយេរ (Henri Parmentier.- Cartes de l'Empire Khmer d'après des inscriptions datées "BEFEO. t. XVI. 3. 1916) ដែលមានឈ្មោះថា "ផែនដីនៃចក្រភពខ្មែរ រៀបចំឡើងតាមទីកន្លែង នៃសិលាចារឹកមានកាលបរិច្ឆេទ"។ គេបានឃើញថា ទឹកដីគ្របដណ្តប់ដោយសិលាចារឹកសរសេរជាភាសាខ្មែរ និងសំស្ក្រឹតមានទំហំធំធេង។ ទឹកដីនេះលាតសន្ធឹងលើប្រទេសកម្ពុជា បច្ចុប្បន្នលើកូសាំងស៊ីន លើប្រទេសសៀមប៉ែកបូព៌ា លើប្រទេសឡាវប៉ែកខាងទក្សិណ គឺជាទឹកដីដែលបានឯកភាពខាងនយោបាយ និងវប្បធម៌។ គ្រាន់តែនៅ សម័យសតវត្សទី ៧ គឺសម័យកាលខាងក្រោយនៃនគរភ្នំ សិលាចារឹកចំនួន២៣០ បានត្រូវគេរកឃើញនៅ ប្រទេសកម្ពុជា ហើយសិលាចារឹកចំនួន ៥៥ បានត្រូវគេរកឃើញនៅប្រទេសជិតខាងទាំងបី។ គ្រាន់តែនៅ ប្រទេសសៀម សិលាចារឹកកម្ពុជា នាសតវត្សទី ៧ បានត្រូវគេរកឃើញនៅទីក្រុង និងខេត្តឆ្ងាយៗ ដូចជា ខេត្តពិស្ណុលោក ស៊ុខោទ អាយុធ្យា ជាដើម។ តាមភស្តុតាងនៃសិលាចារឹកនាសតវត្សទី ៧ ដែលគេបានរកឃើញទាំងនៅប្រទេសកម្ពុជា ទាំងនៅប្រទេសថៃ ដូចជានៅ ខេត្តប្រាជិនបុរីនៅប្រទេសថៃឡង់ (K.506 ) នៅខេត្តសាដែក ក្នុងដែនកូសាំងស៊ីន (k.9) គេអាចយល់ថា នៅសតវត្សទី ៧ ភាសាខ្មែរ ត្រូវបានប្រើប្រាស់ក្នុងលក្ខណៈនៃភាសាសរសេរនៅលើទឹកដីដ៏ធំទូលាយ ដោយអ្នកស្រុកផង ដោយមជ្ឈដ្ឋានរាជការផង។

សិលាចារឹកទាំងឡាយ គឺជាអត្ថបទមានលក្ខណៈប្រវត្តិកថា (historiographiques) ឧទ្ទិសកថា (commémoratifs) ពណ៌នាកថា (narratifs) ឬមានលក្ខណៈជា អត្ថបទរដ្ឋការ (administratifs) ជាអត្ថបទ បញ្ជិកា ស្តីអំពីនរនាម និងស្ថាននាម (repertoires des anthroponymes et toponymes). គឺជាអត្ថបទ ដែលគេចារនៅតាមសសរស្តម្ភដាក់នៅចំពីមុខព្រះវិហារ ឬប្រាសាទ លើទ្វារចូល លើជញ្ជាំងថ្ម លើសិលាស្តម្ភ។គឺជាសិលាចារឹកសរសេរជាភាសាខ្មែរ ឬជាភាសាសំស្ក្រឹត ឬមួយសរសេរជាភាសាទាំងពីរតែម្តង។ ប៉ុន្តែ ទោះបីដូចនេះក្តី មិនមែនមានន័យថា ជាសិលាចារឹកទ្វេភាសាទេ ព្រោះថា អត្ថបទជាភាសាសំស្ក្រឹត និងភាសាខ្មែររៀបរាប់អំពីបញ្ហាខុសៗគ្នា ឬក៏បំពេញន័យដែលមានការខ្វះខាតនៅក្នុងអត្ថបទមួយទៀត។ អក្ខរវិធីដែលគេប្រើប្រាស់សំរាប់សរសេរអត្ថបទសិលាចារឹកជាភាសាខ្មែរ គ្មានលក្ខណៈខុសគ្នាអ្វីពីសិលាចារឹកជា ភាសាសំស្ក្រឹតឡើយ។ គឺជាអក្ខរវិធី មានកំណើតពីប្រព័ន្ធអក្សរព្រាហ្មី (brahmi) ដែលមានន័យថា "អក្សរបង្កើតដោយព្រះព្រហ្ម" ។មានសិលាចារឹកខ្លះ ជាពិសេស នាសម័យអង្គរ ត្រូវបានគេចារតាមអក្ខរវិធីពីរបែប (digraphiques) គឺអត្ថបទមួយប្រើអក្សរព្រាហ្មី តាមបែបខ្មែរ និងអត្ថបទដដែលមួយទៀតប្រើអក្សរទេវនាគរី (devanagari)។

ជាងមួយសតវត្សមកហើយ សិលាចារឹកកម្ពុជាមួយចំនួនធំ សរសេរជាភាសាសំស្ក្រឹត និងជាភាសា ខ្មែរ បានត្រូវបកប្រែជាភាសាបារាំង ហើយបោះពុម្ពផ្សាយដោយលោក ល្វីស ហ្វីណូត៍ (Louis Finot) នៅក្នុងទស្សនាវដ្តីនានា មានទស្សនាវដ្តីអាស៊ីយ៉ាទិក (Journal Asiatique) នៅក្នុង

ព្រឹត្តិបត្រនៃសាលាបារាំងចុងបូព៌ា (Bulletins de l'Ecole Française D'Extrème-Orient) នៅក្នុង សៀវភៅកម្រងអត្ថបទសិលាចារឹកប្រទេសសៀម (Recueil des Inscriptions du Siam) ។ល។ នៅសម័យបច្ចុប្បន្ន សិលាចារឹកកម្ពុជា ដែលគេមិនបានបោះពុម្ពនៅពេលមុន ឬ ដែលគេទើបនឹងរកឃើញនៅពេលថ្មីៗ បានត្រូវបោះពុម្ពផ្សាយដោយ លោកស្រីសាស្ត្រាចារ្យ ពៅ សាវរស លោកសាស្ត្រាចារ្យ ឡុង សៀម លោក ក្លូដ ហ្សាក់ ព្រមទាំង ក្រុមអ្នកសិក្សាសិលាចារឹកនៃប្រទេសថៃឡង់៕

*លោក បណ្ឌិត ឡុង សៀម*

*"វចនានុក្រមខ្មែរបុរាណ" តាមសិលាចារឹកបុរេអង្គរ សតវត្សទី ៦-៨*

## បរមគារមាតាបិតា

ព្រះនៅក្នុងលោករាប់មិនអស់ រាប់ទាំងព្រះរស់នៅក្នុងផ្ទះ
គួរក្មួនប្រុសស្រីស្ដាប់ឲ្យច្បាស់ វន្ទាសំពះព្រះមានគុណ។
ព្រះពុទ្ធជាម្ចាស់ត្រាស់ទេសនា ជូនបរមងារចែកជាបួន
ដល់បុព្វការីអ្នកមានគុណ វិសេសលើសលន់ពន់ពេកក្រៃ។
ទីមួយលោកថា ជា**ព្រះព្រហ្ម** ព្រោះមានគុណធំប្រសើរថ្លៃ
មេត្តាករុណាជាប្រពៃ មុទិតាបី - បួនឧបេក្ខា ។
ទីពីរលោកជា**ទេវតាដើម** អ្នកផ្ដល់ដង្ហើមគ្រប់វេលា
តាមថែរក្សាឥតរួញរា ទោះជាយ៉ាងណាមិនបោះបង់ ។
ទីបីលោកថា ជា**គ្រូដើម** គឺជាគ្រូផ្ដើមដើមបង្អស់
បង្ហាត់បង្រៀនគ្មានចន្លោះ បង្ហាញសព្វអស់ឥតលៀមលាក់ ។
ទីបួនលោកថា **អាហុនេយ្យ** គុណគាប់ច្រើនក្រៃថ្លៃអនគ្ឃ
គួរក្មួនបូជាកុំស្ទើរស្ទាក់ ចូលចិត្តស្មោះស្ម័គ្រជាក់សុខសាន្ត ។

**ព្រះបវរសត្ថា នៅ ពុទ្ធា**

**វត្តគិរីសោភា (ភ្នំសន្ធុក)២០០៨**

# អត្ថប្រយោជន៍នៃនិទានអំណានកម្ពុជា

## I. សេចក្ដីផ្ដើម :

អំណានត្រូវបានចាប់កំណើតឡើងតាំងពីមនុស្សមានជីវិតមកម្ល៉េះ។ ជាដំបូងមនុស្សអានតាមរយៈកាយវិការ សំឡេង សញ្ញានិងរូបភាពផ្សេងៗដូចជា កាយវិការដេក ដើរ ឈរ អង្គុយ សកម្មភាព ប្រចាំថ្ងៃ សញ្ញាបាតុភូតធម្មជាតិ និងសត្វជាដើម។ បន្ទាប់មកទៀត មនុស្សបានអានតាមរយៈតួអក្សរ ដែលបានដាប់សម្គាល់នៅលើថ្ម (សិលាចារឹក) ចារនៅលើស្លឹករឹត និងស្បែកសត្វ ការសរសេរដោយដៃលើសន្លឹកសៀវភៅ ការបោះពុម្ពនៅលើសន្លឹកសៀវភៅ ដោយម៉ាស៊ីនអង្គុលីលេខ ការបោះពុម្ពនៅលើសន្លឹកសៀវភៅដោយគ្រឿងម៉ាស៊ីនទំនើប ការវាយបញ្ចូលក្នុងម៉ាស៊ីនកុំព្យូទ័រ ឬទូរស័ព្ទជាដើម។ អំណានខ្លះទៀត ត្រូវបានគេធ្វើតាមរយៈវិទ្យុទាក់ទងនឹងសំឡេង គំនូរលើក្រដាស ម៉ាស៊ីនថតសំឡេង ឧបករណ៍ទាយពីចិត្តសាស្ត្រមនុស្សប្រភពដ៏ជាក់លាក់នៃអំណានត្រូវបានលេចរូបរាងយ៉ាងច្បាស់លាស់នៅតំបន់សាក់សុន Saxon នៃប្រទេសអាឡឺម៉ង់។ អំណានដើមឡើយត្រូវបានគេហៅថា រេដា (Reada) ដែលមានន័យថា មនុស្សរបស់ក្រុមReada។ Reada គឺជាមេដឹកនាំម្នាក់នៅតំបន់សាក់សុន ដែលបានបោះទីតាំងនៅតំបន់នោះជាមួយក្រុមកុលសម្ព័ន្ធរបស់គាត់តាំងពីសតវត្សរ៍ទី៦នៃគ.ស។ ជំនាញអាន (Reading Skills) រួមមានជំនាញនានាដែលទទួលបានតាមរយៈការអានដូចជា ការយល់ដឹងភាពស្ទាត់ជំនាញ និងភាពឯកពជ្យ។ ជាទូទៅជំនាញទាំងអស់នេះបានផ្តល់ដល់សិស្សនូវសមត្ថភាពក្នុងការបង្វែរពាក្យ បង្រួមពាក្យ ឬកាត់យល់ន័យ ដែលបានសរសេរលើទំព័រនានាឲ្យក្លាយទៅជាអត្ថន័យមួយច្បាស់លាស់។

## II. និយមន័យ

អ្នកអប់រំភាគច្រើននឹងយល់ស្របថា គោលបំណងសំខាន់នៃការអាន គឺជាការស្ថាបនាអត្ថន័យ ការយល់ដឹង និងសកម្មភាពឆ្លើយតបយ៉ាងសកម្មចំពោះអ្វីដែលអាន។ ការកំណត់និយមន័យអំណានបានផ្តល់នូវទស្សនវិស័យជាច្រើន ហើយនិយមន័យចំនួន០២ ដែលត្រូវលើកមកបង្ហាញដូចខាងក្រោម៖

១.អំណាន គឺជាដំណើរការនៃស្ថាបនាអត្ថន័យតាមរយៈអត្ថបទសំណេរ។ វាជាជំនាញដ៏ស្មុគស្មាញមួយ ដែលតម្រូវឲ្យមានការសម្របសម្រួលជាមួយប្រភពព័ត៌មានជាច្រើន(Anderson et Al,១៩៨៥)។

២.អំណានគឺជាដំណើរការនៃការបង្កើតអត្ថន័យតាមរយៈអន្តរកម្មជាច្រើនក្នុងចំណោម (១) ចំណេះដឹងដែលមានស្រាប់របស់អ្នកអាន (២)ព័ត៌មានដែលបានសន្មតដោយអត្ថបទដែលកំពុងអាន និង(៣)បរិបទនៃស្ថានភាពអាន (Wixson, Peters, Weber, & Roeber,១៩៨៧)។

**ក.និយមន័យបែបបុរាណ :**

អំណាន គឺជាការបកស្រាយនិមិត្តសញ្ញានូវអត្ថបទ ដែលបានបោះពុម្ពរួចហើយតាមរយៈភាសានិយាយ ដែលមានហេតុផលអាស្រ័យលើសមត្ថភាពនៃអ្នកអាន។ កិច្ចព្រមព្រៀងទូលំទូលាយមួយបានបញ្ជាក់ថា គ្មានសកម្មភាពនៃចំណេះដឹងណាមួយអាចកើតបានមុនក្នុងខណៈពេលមនុស្សមិនទាន់បានចាប់ផ្ដើមធ្វើសកម្មភាពអានអត្ថបទនោះនៅឡើយ។

**ខ.តាមនិយមន័យផ្សេងៗ**

១.តាមវចនានុក្រមសម្ដេចព្រះសង្ឃរាជ **ជួន ណាត** លោកបានពន្យល់ថា អំណាន ឬការអានមានន័យថា ការមើលថាតាមអក្សរ។

២.តាមសៀវភៅភាសាអង់គ្លេស (Arab Ideal) លោកបានពន្យល់ថា អំណាន ឬការអានគឺសំដៅដល់ការសម្លឹងមើល និងយល់ដឹងពីន័យសេចក្ដីនៃពាក្យពេចន៍ ដែលបានសរសេរ ឬបោះពុម្ព។ ការអាន គឺជាការនិយាយឮៗនូវពាក្យ ដែលបានសរសេរឬបោះពុម្ពផ្សាយ។

៣.ការអាន ឬអំណានមានន័យថា ការស្វែងយល់ពីអត្ថន័យពាក្យពេចន៍ដែលបានបង្កប់ តែមិនបានបង្ហាញឲ្យឃើញភ្លាមៗ។ អំណានមានន័យថា ជាសកម្មភាពនៃការស្វែងយល់ពីអត្ថន័យនៃពាក្យពេចន៍ ដែលបានសរសេរ ឬបោះពុម្ពផ្សាយ។

**III. ទម្រង់នៃការអាន**

ជាទូទៅកុមារដែលមានអាយុ៤ទៅ៥ឆ្នាំដែលអាចទាក់ទងប្រាស្រ័យជាមួយគ្នាបានតាមរយៈភាសានិយាយ គឺពួកគេអាចអានបានតិចតួចណាស់ដោយខ្វះសមត្ថភាពក្នុងការកំណត់ន័យពាក្យ។ ការអានរបស់កុមារតូចៗ គឺជាវិធីដែលតម្រូវឲ្យមានការណែនាំបន្ថែមពីអ្នកដទៃជាពិសេសឪពុកម្ដាយ និងគ្រូបង្រៀន ដើម្បីបញ្ចូលភាសា និងការបញ្ចេញមតិឈានដល់ការយល់ដឹងនៃខ្លឹមសារអត្ថបទ។ សៀវភៅផ្ទាល់ខ្លួនរបស់កុមារគឺគ្រូបង្រៀន បណ្ណារក្ស មាតាបិតាត្រូវណែនាំបន្ថែមឲ្យចេះកែលម្អដោយខ្លួនឯងក្នុងការកត់ត្រាតាមរយៈការចូលរួមអាន។

អំណាន គឺជាដំណើរការនៃការយល់ដឹងដ៏ស្មុគស្មាញនៃនិមិត្តសញ្ញា ដើម្បីបង្កើតឬទាញអត្ថន័យ(អានយល់ដឹង)។ អំណាន គឺជាមធ្យោបាយនៃការទទួលយកភាសាទំនាក់ទំនង និងការចែករំលែកព័ត៌មាននានាជាមួយគំនិត។ ភាសាទាំងអស់គឺជាអន្តរកម្មដ៏ស្មុគស្មាញមួយរវាងអត្ថបទ និងអ្នកអាន ដែលត្រូវបានបង្កើតឡើងតាមរយៈចំណេះដឹងមានស្រាប់បទពិសោធន៍សង្គម អាកប្បកិរិយា និងភាសាដែលអ្នកអានមានសមត្ថភាពទទួលបាន។ ដំណើរការអានតម្រូវឲ្យអ្នកអានអនុវត្ត និងអភិវឌ្ឍជាបន្ត។ លើសពីនេះទៅទៀត អំណានតម្រូវឲ្យអ្នកអានមានគំនិតច្នៃប្រឌិត និងចេះវិភាគស៊ីជម្រៅ។ ដោយសារតែការអានគឺជាដំណើរការស្មុគស្មាញមួយ ដែលតម្រូវឲ្យអ្នកអានត្រូវប្រើនូវយុទ្ធវិធីអានជាច្រើន ដើម្បីជួយយល់ពីនិមិត្តសញ្ញាឲ្យប្រែក្លាយទៅជាសំឡេង ឬភាសានិយាយ។ អ្នកអានប្រើគន្លឹះបរិបទ ដើម្បីកំណត់អត្ថន័យនៃពាក្យ ដែលមិនស្គាល់។អ្នកនិពន្ធអក្សរ

សិល្បិ៍បានប្រើប្រាស់នូវពាក្យពេចន៍ពោហារសព្ទដើម្បីបង្កើតបាននូវរូបារម្មណ៍សម្រាប់អ្នកអាន ហើយកំណត់បាននូវអត្ថន័យក្រោយពីបានអានចប់។
ប្រភេទផ្សេងៗនៃអំណានមិនមែនជាប្រព័ន្ធសំណេរ ដែលមានមូលដ្ឋានលើការនិយាយដូចជាការសរសេរតន្ត្រី ឬរូបសញ្ញានោះទេ។ ជាទូទៅ ការបកស្រាយនិមិត្តសញ្ញា គឺជាការទាញយកអត្ថន័យពីកន្សោមពាក្យដែលអាចមើលឃើញ។ បច្ចុប្បន្ននេះភាគច្រើនត្រូវបានគេបោះពុម្ពពាក្យដោយទឹកខ្មៅ ឬពណ៌ខ្មៅនៅលើក្រដាសដូចជា សៀវភៅអាន ទស្សនាវដ្តី ខិត្តប័ណ្ណឬកុំព្យូទ័រយួរដៃ ឬការបង្ហាញតាមអេឡិចត្រូនិក ទូរទស្សន៍ ទូរសព្ទដៃចល័ត។ អត្ថបទសរសេរដោយដៃតាមរយៈប៊ិកខ្មៅដៃ។ ការអាន គឺជាសកម្មភាពបុគ្គល ឬមនុស្សម្នាក់ ដែលអាចអានខ្លាំង អានខ្សឹប។ ជាទូទៅការអានត្រូវបានបែងចែកជាច្រើនទម្រង់ដូចជា (១)អំណានឮ គឺមានគោលដៅឲ្យឮដល់អ្នកដទៃ។ ការអានឮ គឺជាការប្រើប្រាស់សកម្មភាពយល់ដឹងពីពាក្យពេចន៍ឃ្លាប្រយោគ ល្បះ អត្ថបទ កាយវិការ រូបភាព សូរសំឡេង ឬរលកគំនិតទាំងឡាយដោយប្រើប្រាស់សំឡេងខ្លាំងៗចេញមកក្រៅ។ (២)អំណានចូលរួម គឺមានគោលដៅឲ្យអ្នកអានបានចូលរួមទាំងអស់គ្នា (៣)អំណានដៃគូ គឺគោលបំណងឲ្យសិស្សជួយអានគ្នាទៅវិញទៅមកក្នុងការអានពាក្យថ្មី ឬពាក្យពិបាក (៤)អំណានបុគ្គល គឺមានគោលដៅឲ្យសិស្សអាចអានសៀវភៅតាមកម្រិតអាន និងជ្រើសរើសសៀវភៅដែលអាចអានបាន (៥)អំណានខ្សឹប គឺជាការអាន ដែលប្រើប្រាស់សកម្មភាពយល់ដឹងពីពាក្យពេចន៍ឃ្លាប្រយោគ ល្បះ អត្ថបទ កាយវិការ រូបភាព សូរសំឡេង ឬរលកគំនិតទាំងឡាយដោយប្រើប្រាស់សំឡេងតិចៗឬខ្សឹបៗចេញមកក្រៅ (៦)អំណានក្នុងចិត្ត ឬអំណានស្ងាត់ គឺជាការអានដែលប្រើប្រាស់សកម្មភាពយល់ដឹងពីពាក្យពេចន៍ ឃ្លាប្រយោគ ល្បះ អត្ថបទ កាយវិការ រូបភាព សូរសំឡេង ឬរលកគំនិតទាំងឡាយតែក្នុងចិត្តពោលគឺមិនប្រើប្រាស់សំឡេងខ្លួនឯងចេញមកក្រៅអ្វីឡើយ និង (៧)អំណានស្ទាបគឺជាអំណាន ដែលភាគច្រើនត្រូវបានប្រើប្រាស់ដោយជនពិការភ្នែក។ ពួកគេអានសៀវភៅតាមរយៈសញ្ញា អក្សរស្ទាប។ អំណានប្រភេទនេះ គឺអ្នកអានអាចធ្វើតាមរយៈ អំណានស្ងាត់ អំណានខ្សឹប ឬ អំណានឮក៏បាន។

(នៅមានត)

*លោក គួយ សុគាន*

## "សង្កេត "ឬ" អង្កេត"?

វចនានុក្រមខ្មែរ របស់សម្តេចព្រះសង្ឃរាជជួន ណាត បានបញ្ជាក់ពីអត្ថន័យដូចគ្នាថា ការត្រួតពិនិត្យដើម្បីឲ្យឃើញភាពច្បាស់លាស់នោះ ជាពាក្យខ្មែរ "**សង្កេត**" ចំណែកពាក្យ "**អង្កេត**" ជាពាក្យកម្ចីពីបារាំងសរសេរថា Enquête ។

# អំពីនិបាតសព្ទ និង អាយតនិបាត (ត)

+ **ទាំង** (និ.ពាក្យសម្រាប់និយាយគូបនិយាយប្រមូលចំនួន ឬបែបយ៉ាងអ្វី) :
+ <u>ទាំងអស់</u>, <u>ទាំងគ្រប់</u>, <u>ទាំងស្រុង</u>, <u>ទាំងនេះ</u>, <u>ទាំងនោះ</u>, <u>ទាំងអស់គ្នា</u>, <u>ទាំងប្រុស</u> <u>ទាំងស្រី</u> ជាដើម។
+ **ទាំងឡាយ** (និ. អស់ទាំង, ទាំងអស់, រាល់, ពាក្យប្រាប់ចំនួនច្រើនសម្រាប់ប្រើភ្ជាប់នឹងចុងនាមសព្ទជាពហុវចនៈ) :
+ អ្នក <u>ទាំងឡាយ</u> គឺអស់ទាំងអ្នក ឬពួកអ្នក, អ្នករាល់គ្នា,
+ <u>មនុស្សទាំងឡាយ, សត្វទាំងឡាយ</u> គឺអស់ទាំងមនុស្ស អស់ទាំងសត្វ។
+ **ទោះ** (និ. ទុកជា, បើជា, បើទុកជា) :
+ <u>ទោះ</u> ល្អក្ដី អាក្រក់ក្ដី។
+ <u>ទោះ</u> ខ្ញុំបានមកក្ដី មិនបានមកក្ដី ត្រូវតែអ្នកចាត់ការនោះទៅចុះ។
+ ជាតិជាខ្លឹមចន្ទ <u>ទោះក្រៀមស្វិត</u>ក្រញង់ ក៏មិនលះបង់ក្លិនក្រអូបរបស់វាដែរ។
+ **ទោះជា, ទោះណាជា** (និ.ពាក្យសម្រាប់ប្រើភ្ជាប់ទៅរកអ្វីមួយជាវិកតិកត្ថា (<u>ដែលបានសម្រេច</u>) :
+ ក្រៅពីប្រាក់ <u>ទោះជារបស់អ្វីក៏ដោយ</u> ខ្ញុំចេះតែយក។
+ នៅសម័យបុរាណកូនខ្មែរ <u>ទោះជាព្រះរាជបុត្រក្ដី</u> កូនមន្ត្រីក្ដី កូនចៅប្រជារាស្ត្រក្ដី ទាំងអស់ទៅរៀននៅវត្តយកវត្តជាសាលារៀន។
+ នៅក្នុងរឿងព្រេងនិទានខ្មែរយើងឃើញតួអង្គនីមួយៗ<u>ទោះជាសត្វក្ដីឬជាមនុស្សក្ដី</u>សុទ្ធតែប្រើប្រាស់បញ្ញាស្មារតីដែលខ្លួនមានសម្រាប់ជាមធ្យោបាយក្នុងការរំដោះខ្លួននិងជួយអ្នកដទៃឲ្យរួចផុតពីគ្រោះថ្នាក់តួយ៉ាងដូចជាសត្វទន្សាយក្នុងរឿងសុភាទន្សាយជាដើម។
+ <u>ទោះជា</u> ការសម្រេចចិត្តដោយមានបំណងឬគ្មានបំណង<u>ក៏ដោយ</u> គឺត្រូវផ្អែកលើអ្វីដែលយើងចាត់ទុកជា ការសំខាន់និងប្រកបដោយគុណធម៌ផងដែរ។
+ គេបានពោលថា <u>ទោះជាយ៉ាងណាក៏ដោយ</u> ក៏យើងត្រូវតែផ្ដល់ភាពយុត្តិធម៌ទៅឲ្យមនុស្សណា ដែលគិតប្រយោជន៍ជាតិជាធំជាងប្រយោជន៍ផ្ទាល់ខ្លួន។
+ គេបាននិយាយថា <u>ទោះជាយ៉ាងណាក៏ដោយ</u> បើយើងមិនបានជួបប្រទះឬឆ្លងកាត់ភាពទន់-ខ្សោយ នោះក៏យើងមិនអាចរំដោះខ្លួនយើងឲ្យចេញផុតពីឧបសគ្គទាំងឡាយបានដែរ។

+ ប្រធានធនាគារឯកជនមួយបាននិយាយថា ទោះជាយ៉ាងណាក៏ដោយ វិស័យអចលនវត្ថុជាពិសេសការផ្តល់ប្រាក់កម្ចីសម្រាប់យកទៅទិញផ្ទះមិនអាចកើនឡើងតាមវិស័យធនាគារបានឡើយ។
+ នៅក្នុងការផ្លាស់ប្តូរទម្រង់រូបភាព និងខ្លឹមសារពីរូបភាពដើមឲ្យមកជាខ្មែរ ទោះជាក្នុងភាសាក្តីក្នុងសិល្បៈក្តី ឬអក្សរសាស្ត្រក្តីខ្មែរតែងរក្សាគោលគំនិតពីរសំខាន់គឺប្រាកដនិយម និងសមហេតុសមផលនិយម។

សង្កេត-ពាក្យ "ទោះ,ទោះជា,ទោះណាជាឬទោះជាយ៉ាងណាក៏ដោយ" សម្រាប់ធ្វើឲ្យឃ្លាបន្ទាប់មានន័យជាវិជ្ជមាន។

+ **ទោះបី** (និ.ទុកណាជា,បើទុកណាជា,ក្រែងលោ):
+ ពាក្យដែលខ្ញុំបានថ្លែងមកទាំងប៉ុន្មាននោះ ទោះបីមានលើសលស់ផ្តាំឆ្គង សូមអ្នកទាំងឡាយអត់ទោសខ្ញុំ!
+ ព្រះពុទ្ធសាសនាជាអណ្តូងសម្រាប់កើតនៃការសិក្សាទោះបីការសិក្សានោះ ពុំបានធំទូលំទូលាយ យ៉ាងណាក៏ដោយ។
+ ទោះបី យើងបើកបរស្ថិតនៅក្នុងសភាពត្រូវច្បាប់ក៏ដោយក៏យើងត្រូវមានការយោគយល់ ឬ អនុគ្រោះចំពោះអ្នកបើកបរដែលបំពានច្បាប់ដោយសារយានយន្តរបស់គេមានលក្ខណៈមិនប្រក្រតី។
+ ទោះបី ស្រឡាញ់កូនត្រឹមប៉ុន្មានក៏ដោយ ម្តាយឪពុកក៏ត្រូវសម្តែងឲ្យកូនដឹងថាគ្រប់យ៉ាងត្រូវតែមានដែនកំណត់ និងក្រឹត្យក្រមត្រឹមត្រូវមិនអាចធ្វើអ្វីៗតាមអំពើចិត្តបានទេ។
+ ទោះបី គេមើលមិនឃើញ ភាពសម្បើមដូចជាប្រាសាទអង្គរវត្តក៏ដោយ ក៏អត្ថបទនិងខ្លឹមសារនៃអក្សរសិល្ប៍ខ្មែរមានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់អប់រំកូនខ្មែរជំនាន់ក្រោយ។

(នៅមានត)

*និពន្ធដោយលោក **ទិត សៀង** អតីតសាស្ត្រាចារ្យទុតិយភូមិ១៩៧២*

ត្បាល់បក់បង្ហើរយកចេញនូវធូលី សំរាម ឬដៅ ប៉ុន្តែរក្សាទុកគ្រាប់ធញ្ញជាតិ, ផ្ទុយទៅវិញ តម្រងច្រោះរក្សាទុកកាកសំណល់ ប៉ុន្តែបង្ហូរចេញទឹកដមផ្អែម។ជនមានវប្បធម៌បណ្តុះបណ្តាលហើយរមែងគ្រេបយករសជាតិដ៏ឈ្ងុយឆ្ងាញ់ ហើយខ្ចាក់ចោលកាកសំណល់ ជនគ្មានវប្បធម៌រក្សាទុក កាកសំណល់ ប៉ុន្តែបោះបង់ចោលរសជាតិដ៏ឈ្ងុយឆ្ងាញ់ ។

រឿងពិតនៃជីវិត ដោយ Narada Mahathero

បកប្រែដោយ **ឈន អៀម**




## " គុណភាពគ្រូបង្រៀនបង្កើតធនធានអភិវឌ្ឍន៍ "

ជ័យលាភីលេខ២ (ពានរង្វាន់សម្ដេចសង្ឃរាជ **ជួន ណាត**)

**(បទពាក្យ៧)**

១. ចាប់ដងប៉ាកកាចារពាក្យពេចន៍ រៀបរាប់រំលេចពីអប់រំ
ឧត្ដមប្រយោជន៍នៃសង្គម ជាវិស័យធំអាទិភាព។
២. ព្រោះតែគុណភាពគ្រូបង្រៀន កត្ដាឲ្យមានយសស័ក្ដិលាភ
កសាងប្រទេសពីតូចទាប កើតមានរបៀបរៀបរយល្អ។
៣. សង្គមខ្ពង់ខ្ពស់ព្រោះមានគ្រូ ធ្វើជាគំរូស្មោះស្មោះសរ
សិស្សក្លាយជាពលរដ្ឋបវរ រៀនសូត្របន្ដកសាងជាតិ។
៤. គ្រូសតវត្សរ៍ ទីម្ភៃមួយ ប្រឹងប្រែងលើកស្ទួយជួយខ្មីឃ្មាត
បង្កើនគុណវុឌ្ឍិ ថែមទៀត ចិត្តឥតរវាតឃ្លាតកិច្ចការ។
៥. ប្រើប្រាស់វិធីសាស្ត្របង្រៀន ពុទ្ធិដែលមានញាណបញ្ញា
ខំអប់រំសិស្សឲ្យភ្លឺថ្លា ជួយកសាងស្ថាបអភិវឌ្ឍន៍។
៦. អ្នកបានចំណេះចេះពីរៀន ក្លាយជាអ្នកមានខ្ពស់មុខមាត់
ឧកញ៉ា សេដ្ឋី មន្ត្រីរដ្ឋ សក្ដិយសធំធាត់ពិតប្រពៃ។
៧. គុណភាពគ្រូល្អបវរឆើត ធនធានមនុស្សកើតកើនវាងវៃ
សង្គមអភិវឌ្ឍន៍ជោគជ័យ ដោយភ្ញវន័យគ្រប់គ្រងល្អ។
៨. មានផ្លូវទឹកភ្លើងយើងប្រើប្រាស់ សាលាស្អេកស្កះសង់បន្ត

មន្ទីរពេទ្យផ្សារសំណង់ថ្មី ប្រជាគ្រេកអរសាទរក្រៃ។
៩. សរុបសេចក្ដីនៃខ្លឹមសារ បញ្ជាក់ប្រាប់ថាយើងសព្វថ្ងៃ
បានរីកចម្រើនគ្រប់វិស័យ ដោយសារស្នាដៃគុណភាពគ្រូ។
១០. ដូច្នេះយើងត្រូវខំប្រឹងទៀត ជួយកសាងជាតិរួមគិតគូរ
សង្គមអភិវឌ្ឍន៍យឺនយូរ ល្បីល្បាញគំរូរុងរឿងអើយ៕

លោក **ប៉ាល់ សុខុម**
មន្ត្រីការិយាល័យ អ.យ.ក ស្រុកបាកាន ខេត្ត ពោធិ៍សាត់

**" គុណភាពគ្រូបង្រៀន ជាគុណភាពមូលធនមនុស្សសម្រាប់ការអភិវឌ្ឍដោយចីរភាព "**
ជ័យលាភីលេខ៣ (ពានរង្វាន់សម្ដេចសង្ឃរាជ **ជួនណាត**)

**(បទពាក្យ៧)**

១. ប្រទេសប្រទីបទ្វីបលោកា អភិវឌ្ឍស្ការស្ដែងស្កុកស្កម្ភ
មានមូលធនមនុស្សឧត្ដម គ្រប់គ្រូសក្ដិសមសូមសរសើរ។
២. អំណះអំណាងតាងបញ្ជាក់ អនេកអនគ្ឃគ្រូគ្រាន់បើ
សម្បូរសម្បត្តិសម្បើមប្រើ តំណាលដំណើរយ៉ាងដំណំ។
៣. សម្បត្តិកាយកបស្របសមសួន មានមាឌមាំមួនខ្លួនខ្លឹមក្លំ
កម្ពស់កម្ពឈរសក្ដិសម រូបរាងហាក់ហំហៅហានក្លា។
៤. វិញ្ញាណទាំងប្រាំចាំចាត់ចែង សំឡេងតាក់តែងថ្លែងវាចា
តបតទៅតាមកាយវិការ សបញ្ជាក់ថាសុខភាពល្អ។
៥. សម្បត្តិចរិយាថ្លាថ្លើមថ្លៃ ដូចពេជ្រចរណៃច្នៃបវរ
ទឹកចិត្តផ្ចិតផ្ចង់ត្រង់ស្មោះសរ សម្ដីស្អិតក៏ពីរោះ។
៦. ឱបតវិយាបទប្រពៃ ទង្វើមានន័យល្បីល្បាញឈ្មោះ
សាមគ្គីសាមគ្គារៀរជម្លោះ ភក្ដីចំពោះមនុស្សជាតិ។
៧. សច្ចា សច្ចៈ យុត្តិធម៌ ដូចពន្លឺពណ៌ភ្លឺព្រោងព្រាត
ព្រហ្មវិហារធម៌ឥតរវាត កាត់ខ្ចាត់បាត់ឃ្លាតនូវហិង្សា។
៨. មានក្រមសីលធម៌ប្រាកដជាក់ វិជ្ជាជីវៈមនសិការ

នេះហើយសម្បត្តិចរិយា គ្រូគ្រប់អាត្មាតែងតែមាន។
៩. សម្បត្តិបញ្ញាថ្លាវាងវៃ វិជ្ជាប្រពៃបីដូចស្ពាន
ចម្លងថ្ងៃយប់គ្រប់ជំហាន ជីវិតមេរៀនមានខ្លឹមសារ។
១០. ជំនាញចំណេះចេះទូលាយ ទើបទស្សន៍ទាយងាយយល់ហេតុការណ៍
គរុកោសល្យចិត្តសាស្ត្រា ដោះស្រាយបញ្ហាបានប្រសើរ។
១១. កម្រិតវប្បធម៌ខ្ពង់ខ្ពស់ ជ្រោងយោងយកយសឈ្មោះគ្រាន់បើ
បូកបទពិសោធន៍ផ្តោតបណ្តើរ ជឿជាក់អ្នកស្មើគ្រូមិនបាន។
១២. សិក្សាស្រាវជ្រាវរាវបន្ត គំនិតថ្មីល្អគ្រប់លំអាន
បំពាក់បំប៉នកុំបីខាន ចំណេះចំណានបានចំណាប់។
១៣. ភាសាការទូតលូតលាស់ច្រើន ត្រូវតែបង្កើនជាលំដាប់
សង្គមទំនើបទើបប្រញាប់ រួសរាន់រៀនឆាប់ទាន់សម័យ។
១៤. ទាញយកវិធីសាស្ត្រល្អៗ សិក្សាបន្តរៀងរាល់ថ្ងៃ
ក្នុង អ៊ីនធើណែត បណ្ណាល័យ យកមកកែខៃច្នៃបង្រៀន។
១៥. រៀនហើយរៀនទៀតរៀនរហូត ប្រឹងប្រែងរៀនសូត្រគ្រប់របៀន
សតវត្សរ៍ ម្ភៃមួយ ជាជំហាន គ្រូរៀនទើបមានធនធានល្អ។
១៦. សម្បត្តិទាំងបីប្រពៃពិត គ្រប់គ្រូមូលមិត្តសិទ្ធិបវរ
ជាមូលដ្ឋានគ្រឹះគ្រោងសសរ រឹងមាំបន្តល្អពេកពន់។
១៧. បណ្តុះបណ្តាលថ្នាលធនធាន អប់រំបង្រៀនបង្កើតទុន
សិស្សានុសិស្សជាមូលធន មនុស្សក្រោយនិងមុនមិនខុសគ្នា។
១៨. ប្រសិទ្ធភាពនិងគុណភាព ស្ថិតស្ថេររៀងរៀបប្រែក្លាយជា
កម្លាំងចលករមហិមា រុញកម្ពុជាឲ្យរុងរឿង៕

លោក **សែម ពណ្ណារាយ**
គ្រូបង្រៀនវិទ្យាល័យ ព្រែកលួង
ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល

# កំហុស អ្នកណា? (តពីលេខ៥៤)
## (បទភាកគត)

| | | | |
|---|---|---|---|
| ១៨. | បពិត្រទេវា | មិនរៀងស្នេហា | ដូចទ្រង់ភ្ញាក់ផង |
| | តែតាមការពិត | ទេវៈជាច្បង | រឿងខុសកន្លង |
| | | ពីព្រះធរណី ។ | |
| ១៩. | ត្បិតកន្លងទៅ | រូបខ្ញុំជាស្រូវ | លូតលាស់ប្រពៃ |
| | ផ្លែផ្កាសម្បូណ៌ | ហូរហៀរគ្រប់ទី | ដោយសារធរណី |
| | | អ្នកផ្ដល់ជីឲ្យ ។ | |
| ២០. | ប៉ុន្តែឥឡូវ | ចិត្តសែនអាស្រូវ | មិនដូចមុនឡើយ |
| | ពីមុនធ្លាប់ថ្នម | ផ្ដល់ជីឥតស្បើយ | ឥឡូវព្រះអើយ |
| | | ខុសពីធម្មតា ។ | |
| ២១. | ដីបានចាប់ផ្ដើម | រូតរឹតឫសដើម | ខ្ញុំស្ទើរមរណា |
| | បង្ខះសព្វជី | ចំណីអាហារ | តើឲ្យខ្ញុំណា |
| | | ផ្លែផ្កាម្ដេចបាន ។ | |
| ២២. | ថ្នោះសូមទ្រង់ជ្រាប | ដូចបានជម្រាប | តាំងពីដើមដាន |
| | រឿងហ្នឹងរឿងខុស | កំហុសប៉ុន្មាន | ប្រាកដកើតមាន |
| | | ពីព្រោះតែដី ។ | |
| ២៣. | ទេវៈស្ដាប់ហើយ | មិននៅកន្ដើយ | ស្រែកថាអើវ៉ី |
| | នៃវ៉ីយអមាត្យ | ចូរឯងចេញខ្មី | ចុះទៅហៅដី |
| | | ឲ្យមកប្រញាប់ ។ | |
| ២៤. | អមាត្យឮជាក់ | ស្ទុះដូចកន្ទ្រាក់ | ចេញទៅយ៉ាងឆាប់ |
| | នាំដីមកដល់ | យល់ភក្ត្រប្រញាប់ | លំទោនឱនក្រាប |
| | | ទាបកម្រាលព្រំ ។ | |
| ២៥. | ដីតាំងទូលថា | ឱអង្គទេវា | កំពូលនៃខ្ញុំ |
| | តើមានរឿងអ្វី | តើតូចឬធំ | ទើបហៅបង្គំ |
| | | ប្រញាប់យ៉ាងហ្នឹង ។ | |
| ២៦. | ទេវៈត្រាស់ថា | អើនៃដីណា | អញហៅឯងហ្នឹង |
| | ដ្បិតតែខាងស្រូវ | នេះឯងគេខឹង | គេថាឯងហ្នឹង |
| | | មានចិត្តអប្រិយ ។ | |

២៧. ដ្បិតឯងនេះណា មានចិត្តឫស្យា មិនព្រមប្រណី
មិនព្រមផ្ដល់ដី ជាតិឲ្យគ្នាធី ថែមមិនគប្បី
រួបរឹតគ្នាទៀត ។

២៨. បពិត្រទេវៈ ខ្ញុំនេះទៀងជាក់ មិនមែនចោលម្សៀត
គិតចង់បង្អាក់ បង្អត់ជីជាតិ គិតចង់ពិឃាត
អង្គស្រូវនោះឡើយ ។

២៩. រឿងខុសនេះណា ពីព្រះគង្គា មួយអង្គឯងហើយ
ត្បិតពេលនេះម្ដង តែងតែព្រងើយ មិនធ្វើការឡើយ
គិតតែសប្បាយ ។

៣០. គិតតែពីហោះ ហើរលេងផ្លេកផ្លោះ បណ្ដែតរូបកាយ
ចោលខ្ញុំធរណី ឲ្យនៅពោះម៉ាយ កំសត់ឯកកាយ
ឯកាតែឯង ។

៣១. កាលកន្លងទៅ គង្គាតែងនៅ នឹងខ្ញុំនេះឯង
រួមដៃធ្វើការ គ្រប់ការបំប្លែង សព្វសារធាតុឯង
ឲ្យកើតជាជី ។

៣២. តែពេលនេះណា គង្គាសាវា ចោលខ្ញុំធរណី
ឲ្យនៅកណ្ដោង កណ្ដោចអង្គី តើខ្ញុំធរណី
ប្លែងជីម្ដេចបាន ។

៣៣. ដូច្នោះរឿងខុស កើតពីកំហុស គង្គាមួយប្រាណ
ភ្លើតភ្លើនសប្បាយ ហិចហើរចោលឋាន ចោលកិច្ចលោកបាន
ប្រគល់ឲ្យធ្វើ ។

៣៤. ឥឡូវបានស្ដាប់ គ្រប់សព្វសាស័ព្ទ ដីរ៉ាប់ខាងលើ
ថាអើពិតឬ គង្គានាងធ្វើ នូវគ្រប់អំពើ
ដូចឯងរ៉ាប់រ៉ាយ ។

៣៥. ធរណីទូលថា ពិតណាស់ករុណា ពិតដូចអធិប្បាយ
ទេវៈថាអើ ចាំអញដោះស្រាយ ហៅមកនិយាយ
មកសួរការពិត ។

៣៦. ទេវៈងាករឹង អមាត្យហាក់ដឹង ស្ទុះចូលមកជិត
ទេវៈអាអើ អមាត្យជំនិត ឯងលែលកគិត
ហៅទឹកមកឆាប់ ។

(នៅមានត)

លោក **ភិន វ៉ាន់ណា**
មន្ត្រី អធិការកិច្ចខេត្តកំពង់ចាម



## របបប្រជាធិបតេយ្យ (តចប់)

### IV. ព្រះពុទ្ធសាសនា និងដំណើរការប្រជាធិបតេយ្យ

សាសនាគឺជាផ្នែកមួយដ៏សំខាន់នៃជីវិតរស់នៅរបស់មនុស្ស ហើយវាបានដើរតួនាទីក្នុងវិស័យនយោបាយ និងជីវិតប្រចាំថ្ងៃ។ យ៉ាងណាមិញ ទ្រឹស្តីជាច្រើនក្នុងព្រះពុទ្ធសាសនាត្រូវបានគេចាត់ទុកថាមានលក្ខណៈវិទ្យាសាស្ត្រ ហើយមានទំនាក់ទំនងនឹងការគ្រប់គ្រងរដ្ឋទៀតផង។ ខាងក្រោមនេះជាការប្រៀបធៀបលទ្ធិប្រជាធិបតេយ្យ និងព្រះពុទ្ធសាសនាៈ

- **អត្តាហិ (អាត្មា ឬខ្លួន)**: មនុស្សត្រូវស្វែងរកសច្ចធម៌សម្រាប់ខ្លួនផ្ទាល់ គឺត្រូវស្វែងយល់ដឹង និងចេះរកវិធីសង្គ្រោះខ្លួនដោយខ្លួនឯង បានន័យថា មនុស្សម្នាក់ត្រូវតែចូលរួមក្នុងការកសាងលទ្ធិប្រជាធិបតេយ្យដើម្បីឲ្យសិទ្ធិមនុស្ស និងលទ្ធិប្រជាធិប-តេយ្យមានដំណើរការ។ ដូចនេះ អ្នកត្រូវជ្រើសរើសអ្នកដឹកនាំរបស់អ្នកតាមរយៈការបោះឆ្នោត ហើយក៏ត្រូវតែដឹងផងដែរនូវ អំពើដែលរដ្ឋាភិបាលបានធ្វើ និងកំពុងធ្វើ។
- **សង្គហៈ (យោគយល់ អត់ឱន)**: មនុស្សម្នាក់ៗតែងតែមានការសម្រេចចិត្តផ្សេងៗពីគ្នា ក្នុងការស្វែងរកសច្ចធម៌របស់ខ្លួន។ ក្នុងន័យនេះ ទើបព្រះពុទ្ធទ្រង់បានសម្តែងថា យើងត្រូវតែចេះអត់ឱនចំពោះការសម្រេចចិត្តរបស់អ្នកដទៃ ហើយក៏ត្រូវទទួលស្គាល់ថា ពល់ជំនឿរបស់អ្នកដទៃក៏អាចមានខុសប្លែកពីជំនឿរបស់យើងដែរ។ នេះមានន័យថា លទ្ធិប្រជាធិបតេយ្យលើកទឹកចិត្តប្រជាជនឲ្យចេះគិតដោយខ្លួនឯង ហើយចេះបញ្ចេញមតិ និងទស្សនៈរបស់ខ្លួន។ ក្នុងលទ្ធិប្រជាធិបតេយ្យ បានអប់រំប្រជាពលរដ្ឋឲ្យចេះ អត់ឱនគ្នា និងមានគំនិតចេះអនុគ្រោះចំពោះបដិមតិនានា។ ទំនាស់នយោបាយ អាចដោះស្រាយបានដោយសន្តិវិធី គឺដោះស្រាយដោយសន្លឹកឆ្នោត មិនមែនដោយប្រើកម្លាំងបាយ ឬអំពើហិង្សាទេ។
- **វន្ទាគារវៈ (ការគោរព ប្រតិបត្តិ)**: ជាការគោរពចំពោះអាយុជីវិត ច្បាប់ និងវិន័យដែលជាគន្លឹះដ៏សំខាន់សម្រាប់យល់ ឬត្រាស់ដឹង។ នេះមានន័យថា ក្នុងលទ្ធិប្រជាធិប-តេយ្យ ប្រជាពលរដ្ឋត្រូវគោរពលក្ខខណ្ឌមួយចំនួនដូចគ្នា និងអ្នកកាន់ពុទ្ធសាសនាដែរ ដូចជា ការគោរពចំពោះ

អាយុជីវិតជាដើម។ ការគោរពច្បាប់ និងការប្រតិបត្តិតាមរដ្ឋធម្មនុញ្ញរបស់ប្រទេស ជាបញ្ហាដ៏សំខាន់បំផុតក្នុងសិទ្ធិមនុស្ស និងលទ្ធិប្រជា-ធិបតេយ្យ។

- **កម្មន្តៈ (អំពើ)**: រាល់អ្វី ដែលអ្នកធ្វើ ត្រូវតែឆ្លុះបញ្ចាំងនូវ សម្មាទិដ្ឋិ គឺការយល់ដឹងដោយត្រឹមត្រូវ សម្មាសង្កប្បៈ គឺការត្រិះរិះដោយត្រឹមត្រូវ និងសម្មាវាចា គឺជាការនិយាយត្រឹមត្រូវ។ នេះមានន័យថា រាល់អ្នកនយោបាយទាំងឡាយតែងតែព្យាយាមជួយប្រទេសរបស់ខ្លួនឲ្យមានការអភិវឌ្ឍតាមការសន្យាចំពោះមុខប្រជាជនតាមវិធីផ្សេងៗដែលខ្លួនបានឃោសនា។ ប្រជាជនខំប្រឹងស្តាប់អ្វីដែលអ្នកនយោបាយទាំងនោះបាននិយាយ ប៉ុន្តែចូរអ្នកកុំភ្លេចពិនិត្យមើលអ្វីៗដែលពួកគេធ្វើផងដែរ។ និយាយរួម អ្នកនយោបាយត្រូវតែធ្វើឲ្យបានច្រើនជាងការនិយាយតែមាត់ទទេ។
- **បុច្ឆនៈ (សំនួរ)**: ព្រះពុទ្ធទ្រង់សម្តែងថា មនុស្សគ្រប់រូប ត្រូវតែមានចំណោទសួរអំពីការបង្រៀន របស់ព្រះអង្គដើម្បីឲ្យមនុស្សទាំងអស់នោះបានយល់ដឹងកាន់តែច្បាស់ អំពីអ្វីដែលហៅថា សច្ចធម៌។ ការសួរខ្លួនឯង ជាវិធីឆ្ពោះទៅកាន់ការស្វែងយល់ ឬការត្រាស់ដឹង។ ក្នុងព្រះពុទ្ធសាសនាដំណើរការប្រជាធិបតេយ្យបានអប់រំមនុស្សឲ្យចេះសង្គ្រោះខ្លួនឯង ចេះអត់ឱនដល់អ្នកដទៃ ចេះគោរពជីវិតអ្នកដទៃ ចេះគោរពច្បាប់ប្រទេស ប្រកាន់ខ្ជាប់នូវអំពើត្រឹមត្រូវជានិច្ច ព្រមទាំងស្វែងយល់ឲ្យបានច្បាស់អំពីអ្វីដែលជាសច្ចធម៌។ ការចេះសួរដើម្បីស្វែងរកការពិតវាជាមធ្យោបាយមួយ ដើម្បីកុំឲ្យធ្លាក់ខ្លួនជាឧបករណ៍របស់អ្នកនយោបាយ៕

រៀបរៀងដោយលោកគ្រូ **បាន ភក្តដា** សាស្ត្រាចារ្យ NIE
០១២ ២៧៨ ៧៩៣

## រួមគ្នាស្អាត

(បទ ផ្កាឈូករីក)

រួមគ្នាស្អាត ខាតប៉ុន្មាន បានយើងសោះ
រួមគ្នាស្អាត លែងលើកបោះ ចោលសំរាម
រួមគ្នាស្អាត ពីខ្លួនយើង គ្មានគេហាម
រួមគ្នាស្អាត ក្មេងធ្វើតាម ស្អាតតគ្នា ។
ធ្វើគំរូ គ្រូមុនសិន ឆ្លុះបំផុស
ធ្វើគំរូ កូនស្រីប្រុស កុំរួញរា
ធ្វើគំរូ សម្អាតផ្ទះ ជម្រះធ្លា
ធ្វើគំរូ បង្រៀនគ្នា ឲ្យរស់ស្អាត ។
ស្អាតគ្រប់គ្នា ជាវិន័យ នៃខ្លួនឯង
ស្អាតគ្រប់គ្នា ត្រូវធ្វើស្តែង កុំប្រមាថ
ស្អាតគ្រប់គ្នា កុំធ្វើពើ ដើរនាំខាត
ស្អាតគ្រប់គ្នាផ្ទះ យើងស្អាត ស្អាតទាំងស្រុក ៕
ថ្មីៗ ២៥/១១/១៨

# អត្ថន័យនៃការសិក្សា

ការសិក្សាជាគ្រឿងអលង្ការមួយបែប សម្រាប់តាក់តែងមនុស្សឲ្យបានជាមនុស្សពេញលក្ខណៈ មានសមត្ថភាពបរិបូណ៌គួរដល់ការងារ នឹងសម្រាប់ធ្វើមនុស្ស ឲ្យមានគុណធម៌ដ៏ល្អ ឲ្យចេះគ្រប់គ្រងជីវិត ទាំងជាមធ្យោបាយសម្រាប់សាងខ្លួន ឲ្យបានជាពលរដ្ឋដ៏ល្អ។

ហេតុនេះទើបបណ្ឌិតទាំងឡាយ បានពន្យល់អត្ថន័យរបស់ការសិក្សាទុកច្រើនយ៉ាង ដូចតទៅនេះ :

ក- ដើម្បីអប់រំចិត្តរបស់ក្មេងឲ្យចេះដឹង ជ្រើសរើសយកសេចក្ដីល្អទាំងពួង។

ខ- ដើម្បីជាមធ្យោបាយសម្រាប់សាងខ្លួន ទប់ទល់ជីវិតគ្រប់យ៉ាង ឲ្យសមដល់អត្តភាព។

គ- ដើម្បីចែកចំណេះដឹងដល់មនុស្ស ឲ្យយកចំណេះដឹងនោះ ទៅប្រកបកិច្ចការផ្សេងៗ ឲ្យត្រូវតាមគោលវិទ្យាសាស្ត្រ។

ឃ-ដើម្បីឲ្យមនុស្សមានសេចក្ដីល្អវិសេស ប្រាសចាកសេចក្ដីអាក្រក់ ដោយប្រកបកិច្ចការទាំងពួងត្រឹមត្រូវតាមលក្ខណៈគ្រប់យ៉ាង។

អ្នកប្រាជ្ញទាំងឡាយបានពន្យល់អត្ថន័យរបស់ការសិក្សាទុកច្រើនពេក ហួសវិស័យនឹងដកស្រង់យកមកពោលឲ្យសព្វគ្រប់ ជូនលោកអ្នកនាងស្ដាប់ក្នុងឱកាសនេះ។ សរុបសេចក្ដីមក ការសិក្សាជាកិច្ចមួយប្រចាំជីវិតរបស់មនុស្សគ្រប់រូប មិនថាប្រុស ឬ ស្រីឡើយ នឹងខានពុំបាន ដើម្បីធ្វើសេចក្ដីអង់អាចដែលមាននៅប្រចាំកាយស្រាប់ឲ្យចម្រើនឡើង ដើម្បីញ៉ាំងប្រយោជន៍ខ្លួន និងប្រយោជន៍ជាតិឲ្យបានសម្រេចដោយល្អ បានសេចក្ដីសុខ ព្រមទាំងរក្សាសេចក្ដីសុខរបស់សង្គមឲ្យប្រព្រឹត្តទៅបានស្រួល។

ឯការសិក្សាត្រូវ ប្រកបដោយអង្គផ្សេងៗច្រើនប្រការ តែក្នុងទីនេះសូមរៀបរាប់ដោយសង្ខេប គឺត្រូវប្រកបដោយអង្គ ៤គឺ:

១- វិជ្ជាសិក្សា : បានខាងការសិក្សាផ្លូវវិជ្ជា គឺចំណេះគ្រប់យ៉ាងដើម្បីឲ្យកើតចំណេះដឹងឈ្លាស-វៃក្នុងការប្រកបអាជីវកម្មឲ្យសម្រេចផលល្អ។ ឧទាហរណ៍: ដូចការរៀនវិជ្ជាផ្សេងៗតាមគោលសូត្រ អក្សរសាស្ត្រ សព្ទសាស្ត្រ ភាសាសាស្ត្រ ប្រវត្តិសាស្ត្រ រហូតដល់វិទ្យាសាស្ត្រជាដើម។

២- កម្មន្តសិក្សា: បានខាងការចុះពិសោធធ្វើការងារគ្រប់បែប តាមចំណេះវិជ្ជាដែលបានសិក្សាមកហើយនោះ ឲ្យស្ទាត់ជំនាញផ្ទាល់ខ្លួន។ ឧទាហរណ៍ ដូចរៀនវិជ្ជាកសិកម្មក្តី ឧស្សាហកម្មក្តី ជាដើម បានចេះដឹងហើយបានធ្វើការនោះដោយខ្លួនឯង ឲ្យបានថ្នឹកតាមចំណេះដែលបានរៀនមកនោះឯង។

៣- ពលសិក្សា : បានខាងការសិក្សាផ្លូវកាយបរិហារ ឬ អត្តពលកម្ម ឲ្យមានរាងកាយមាំទាំ ការពារមិនឲ្យមានរោគ ភ័យ ឈឺចាប់ ឲ្យបានសុខកាយសប្បាយចិត្ត ចម្រើនកម្លាំងពលំ និងសាច់ដុំ។ ឧទាហរណ៍ ដូចការហាត់ប្រាណ រត់ លោត ហែលទឹក លេងយោលទៅយោលមក.....រហូត

ដល់កីឡាផ្សេងៗដែលជាការហ្វឹកហាត់រាងកាយឲ្យមាំមួន។

៤- ចរិយាសិក្សា: បានខាងការសិក្សាអប់រំផ្លូវកាយ វាចា ចិត្ត ឲ្យបានទៅជាអ្នកដឹងខុសត្រូវ តាំងនៅក្នុងសីលធម៌ ដើម្បីជាឧបករណ៍ គ្រឿងដឹកនាំឲ្យកើតសេចក្ដីសុខ សេចក្ដីចម្រើនដល់ខ្លួន ដល់ក្រុមគ្រួសារ ឬដល់សង្គមនិងប្រទេសជាតិ។

និយាយដោយខ្លី គឺការសិក្សាឲ្យបានជាមនុស្ស មានចំណេះដឹង ធ្វើការងារតាមជំនាញសេចក្ដីប្រព្រឹត្តត្រឹមត្រូវល្អ និងជាមនុស្សមានរាងកាយមាំទាំរឹងប៉ឹង។

អង្គ៤របស់ការសិក្សានេះត្រូវអាស្រ័យគ្នានឹងគ្នាជានិច្ច ខ្វះពុំបាន បើខ្វះអង្គណា មិនរាប់ថាជាការសិក្សាពេញអង្គបានឡើយ ព្រោះថាបើខ្វះអង្គណាមួយ រមែងជាឧបសគ្គដល់ការចិញ្ចឹមជីវិត។ សូមលើកឧទាហរណ៍មកប្រៀបឲ្យងាយយល់ ដូចជាអ្នកមានវិជ្ជាចេះដឹងខ្ពស់ មានសេចក្ដីប្រព្រឹត្តល្អ ថែមទាំងចេះអនុវត្តធ្វើការងារដោយល្អទៀតផង តែជាមនុស្សមានរោគប្រចាំកាយ ឈឺជានិច្ច ឬ ទុព្វលភាព ក៏មិនអាចមានកម្លាំងល្មមនឹងប្រកបអាជីវកម្មបំពេញមុខងារក្រសួងបាន ឬមួយមានចំណេះដឹង មានកម្លាំងពលំមាំមួនទាំងព្យាយាមធ្វើការហើយតែសេចក្ដីប្រព្រឹត្តមិនល្អមិនមានអ្នកណាសេពគប់ជឿស្ដាប់តាម ក៏រមែងប្រកបអាជីវកម្មមិនស្រួល បំពេញការងារជូនក្រសួងមិនបានល្អ និងមិនបានចម្រើនឡើយ។

ហេតុដូចបរិយាយមកនេះ លោកទាំងមូលទើបកំណត់ឲ្យយុវជន យុវនារីរាល់រូប ទទួលការសិក្សាទាំង៤ចំណែកដូចពោលមកហើយនោះដោយសេចក្ដីប្រឹងប្រែង ដើម្បីឲ្យមានវិជ្ជាល្អ ចរិយាល្អ មានការងារល្អ មានកម្លាំងកាយល្អ ព្រមទាំងឲ្យមានទឹកចិត្តជាអ្នកកីឡាតាមសមគួរ ដល់អាជីពរបស់ខ្លួន។

ប្រទេសណាមួយបរិបូណ៌ដោយការសិក្សាពេញអង្គទាំង៤ ទូទៅគ្រប់ទីតំបន់ និគមជនបទ ប្រទេសនោះជា "**អារ្យប្រទេស**" បានចម្រើនរុងរឿងដោយអារ្យធម៌ វប្បធម៌ និងសម្បត្តិគ្រប់យ៉ាងពិតៗ។ ប្រទេសណាប្រាសចាកការសិក្សាទាំង៤ផ្នែកនេះ ប្រទេសនោះជា "**អនារ្យប្រទេស**" ព្រោះខ្សត់ខ្សោយអារ្យធម៌ វប្បធម៌និងសម្បត្តិគ្រប់យ៉ាង ប្រជាជាតិក្នុងប្រទេសទាំងមូលជាអនារ្យជន។

ប្រទេសនីមួយៗ ទោះធំក្ដីតូចក្ដី លុះតែបរិបូណ៌ដោយពលរដ្ឋមានវិជ្ជាល្អ ការងារល្អ សុខភាពល្អ ចរិយាល្អផង បរិបូណ៌ដោយគ្រឹះស្ថាន ផ្លូវថ្នល់ ទឹក ភ្លើងភ្លឺច្រាលទ្រាលឆ្អិនឆ្អៅគ្រប់ទីកន្លែងផង ទើបឈ្មោះថាជាអារ្យប្រទេសពេញលក្ខណៈបាន។

ព្រោះហេតុនេះបានជាប្រមុខរាជរដ្ឋាភិបាល ខិតខំដោយផ្ទាល់ផង ណែនាំប្រជាពលរដ្ឋគ្រប់ប្រភេទ គ្រប់ឋានៈផង ស្ថាបនានូវស្ថាបនកម្មទាំងឡាយច្រើនជាអនេកប្រការ មានការសិក្សាវិជ្ជាផ្សេងៗ ទាំងខាងអាណាចក្រ ទាំងខាងពុទ្ធចក្រ គ្រឹះស្ថានសិក្សា មន្ទីរពេទ្យការសាធារណៈ ផ្លូវថ្នល់ ។ល។ ព្រមទាំងស្ថាបនាខាងផ្នែកសេដ្ឋកិច្ច កសិកម្ម មានទំនប់ទឹក សម្រាប់ប្រជាពលរដ្ឋធ្វើស្រែចម្ការច្បារដំណាំជាដើម ដើម្បីកសាងប្រទេសកម្ពុជាឲ្យបានជាអារ្យប្រទេសជឿនលឿនអស់កាលយូរអង្វែងទៅ៕

កំពង់ចាម ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០៨

**ថែម ផាន** (មន្ត្រីចូលនិវត្តន៍)




## ប្រវត្តិសាស្ត្រ និងរឿងព្រេងនិទានអំពី ប្រាសាទភ្នំជីសូរ

ប្រាសាទភ្នំសំខាន់ៗមាន បីនៅក្នុងប្រទេសកម្ពុជា គឺប្រាសាទភ្នំបាខែង,ប្រាសាទភ្នំព្រះវិហារ និងប្រាសាទភ្នំជីសូរ។ បន្ទាប់ពីនេះយើងលើកបង្ហាញអំពីប្រវត្តិសាស្ត្រជាក់ស្ដែងនៃប្រាសាទភ្នំជីសូរផង និងតាមរយៈរឿងព្រេងនិទានផងដែរ។

បច្ចុប្បន្ននេះភ្នំជីសូរឋិតនៅក្នុងឃុំរវៀង ស្រុកសំរោង ខេត្តតាកែវ។ ការឆ្លងកាត់លើកំណាត់ផ្លូវជាតិលេខ២ ពីភ្នំពេញមានចម្ងាយ ៤៧គ.ម ទើបទៅដល់ភ្នំជីសូរដោយរាប់ទាំងចម្ងាយផ្លូវចុះពីផ្លូវជាតិលេខ២ ប្រវែង ៥គ.មផង។

នៅលើខ្នងភ្នំជីសូរឃើញប្រាសាទបុរាណមានចំណាស់ជាង ១ពាន់ឆ្នាំមកហើយ បើរាប់ពីចាប់ផ្ដើមកសាងដំបូងប្រាសាទភ្នំជីសូរ គឺជាការឧទ្ទិសដល់សាសនាព្រាហ្មណ៍ និកាយព្រះឥសូរ និងក៏ជាការយកតាមព្រះនាមព្រះមហាក្សត្រជាអ្នកកសាងប្រាសាទដែរ គឺព្រះបាទសុរ្យវរ្ម័នទី១ និងទី២។ នៅខាងមុខភ្នំជីសូរចម្ងាយប្រហែល ៥០០ម៉ែត្រ គេឃើញមានសំណង់ប្រាសាទបាក់-បែក ដែលសង់អំពីថ្ម ដែលអ្នកស្រុកហៅឈ្មោះថា សែនភូវាំង គឺជាព្រះរាជនិវេសនដ្ឋាននៃព្រះមហាក្សត្រនាសម័យបុរាណ។ រឿងរ៉ាវទាក់ទងនឹងប្រាសាទភ្នំជីសូរគេរកឃើញតាមរយៈឯកសារប្រវត្តិសាស្ត្រ និងរឿងព្រេងនិទានតៗគ្នារបស់ប្រជាពលរដ្ឋនៅតំបន់ភ្នំជីសូរ។ ដូចនេះយើងនឹងបង្ហាញប្រវត្តិនៃព័ត៌មានប្រាសាទភ្នំជីសូរដូចតទៅ៖

១.តាមរយៈប្រវត្តិកត់ត្រា តាមសិលាចារឹកនៃព្រះនាមព្រះមហាក្សត្រកសាងប្រាសាទភ្នំជីសូរចំនួន ៣អង្គទើបកសាងហើយស្រេចជាស្ថាពរគឺ ព្រះបាទសុរ្យវរ្ម័នទី១ (គ.ស.១០០២-១០៥០) ព្រះបាទធរណិន្ទ្រវរ្ម័នទី១ (គ.ស.១១០៧-១១១៣) និងព្រះមហាក្សត្រចុងក្រោយបានកសាងបង្ហើយឲ្យបានសម្រេចជាស្ថាពរនោះគឺ ព្រះបាទសុរ្យវរ្ម័នទី២ ឋិតក្នុងគ.ស.១១១៣ ដល់គ.ស. ១១៥០។ ជាពិសេសក្នុងឯកសារប្រវត្តិសាស្ត្របានបញ្ជាក់ថា ព្រះបាទសុរ្យវរ្ម័នទី២ ព្រះអង្គបាន

រៀបចំពិធីសម្ពោធសំណង់ប្រាសាទភ្នំជីសូរដែលឋិតក្រោមរាជាធិបតេយ្យនៃព្រះអង្គផ្ទាល់តែម្តង។ កាលនោះគេដឹងថា ទីសក្ការបូជាទ្រង់ប្រោសប្រទាននាមថា "សូរ្យប័វិត" ដែលមានន័យថា ភ្នំព្រះបាទសូរ្យ ហើយក៏បានហៅក្លាយមកដល់សព្វថ្ងៃនេះថា ភ្នំជីសូរ តមក ព្រោះគេបានកត់សំគាល់ថាប្រាសាទនោះឧទ្ទិសដល់ព្រះឥសូរដោយមានចម្លាក់តាមផ្តែរប្រាសាទគឺព្រះឥសូរអង្គុយនិងមានរូបឈរលើកាលៈ ឬរាហូ...។

២.ចំណែកឯរឿងព្រេងនិទានទាក់ទងនឹងប្រាសាទភ្នំជីសូរ អ្នកស្រុក ចាស់ទុំនៅម្តុំតំបន់ភ្នំជីសូរនៅបន្តចេះចាំ ហើយបាននិទានតៗគ្នាពីមាត់មួយទៅមាត់មួយថា តាំងពីយូរលង់ណាស់មកហើយមានព្រះមហាក្សត្រព្រះនាមសុរិយាទេវេសគង់នៅព្រះរាជនិវេសន៍ "សែនតូរាំង" នៅខាងកើតភ្នំជីសូរជិតទន្លេអុំ។ កាលនោះព្រះអង្គបានរៀបចំពិធីចម្រើនព្រះកេស ព្រះរាជឱរស ដែលមានព្រាហ្មណ៍ព្រឹទ្ធាចារ្យចូលម្តងម្នាក់ក្នុងការថ្វាយព្រះពរស័ព្ទសាធុការ។ ប៉ុន្តែជាកិច្ចចុងក្រោយមានព្រាហ្មណ៍ព្រឹទ្ធាចារ្យម្នាក់បានថ្វាយព្រះពរដោយប្លែកពីគេថា ៖

- សូមឲ្យមានកម្លាំងដូចស្រមោច
- សូមឲ្យមានឫទ្ធិដូចខ្មោច
- សូមឲ្យមានចិត្តមុតដូចស្រី

ព្រះរាជាជាព្រះវរបិតារបស់ព្រះឱរសគ្រាន់តែបានឮការថ្វាយពរពីព្រាហ្មណ៍នោះភ្លាមក៏មានការក្រោធប្រកបដោយការអាក់អន់ព្រះទ័យយ៉ាងខ្លាំង។ ប៉ុន្តែព្រាហ្មណ៍នោះបានទូលព្រះមហាក្សត្រថា សូមព្រះអង្គទ្រង់ព្រះសណ្តាប់ក្នុងការបកស្រាយនូវពរនេះ។ ទី១ ឲ្យមនុស្សលើកដែកទំហំប៉ុនខ្លួនដោយម្នាក់ឯងមិនរួច។ ប៉ុន្តែស្រមោចពាំម្ហូលលាបទឹកឃ្មុំទំហំប៉ុនខ្លួនវារួច។ នេះជាជោគជ័យដែលស្តេចទទួលព្រម។ ទី២ សាកល្បងកប់ខ្មោចតែហោងទាំង៧ ហើយឲ្យយករបស់មានតម្លៃកប់នៅទីនោះពេលយប់ឲ្យមនុស្សទៅយក គឺពុំមាននរណាហ៊ានទៅកកាយយកទ្រព្យដ៏មានតម្លៃនោះទេ។ នេះហើយដែលហៅថា មានឫទ្ធិដូចខ្មោច។ ព្រះរាជាទ្រង់យល់ព្រមតាមពរទី២នេះ។ ឯការបង្ហាញពរទី៣ គឺធ្វើពិសោធន៍ ប្តីនិងប្រពន្ធដែលបញ្ជាក់ថាតើប្តីហ៊ានសម្លាប់ប្រពន្ធ ឬប្រពន្ធហ៊ានសម្លាប់ប្តី ដើម្បីយកសក្តិ និងទ្រព្យសម្បត្តិ។ ពេលនោះគឺខាងស្ត្រីយល់ព្រមសម្លាប់ប្តី។ ត្រង់នេះហើយដែលព្រះរាជាបានយល់ច្បាស់អំពីពរទី៣។

នៅពេលដែលព្រះរាជាទ្រង់យល់ច្បាស់តាមពរទាំងបីរបស់ព្រាហ្មណ៍ព្រឹទ្ធាចារ្យនោះហើយទើបព្រះអង្គទ្រង់ព្រះរាជទានយសសក្តិជាអ្នកប្រាជ្ញដ៏ធំ និងទុកព្រាហ្មណ៍នោះជាគ្រូរបស់ព្រះរាជបុត្ររបស់ព្រះអង្គ ដោយព្រះអង្គព្រមកសាងទីអាស្រមដ៏ស្អុកស្អម្ភសម្រាប់ពួកព្រាហ្មណ៍ នៅលើកំពូលភ្នំជីសូរ ផង។

ដូចនេះប្រាសាទភ្នំជីសូរមានប្រវត្តិរឿងទាំងពីរយ៉ាងនេះគឺរឿងព្រេងនិទាន និងរឿងពិតជាប្រវត្តិសាស្ត្រដូចបានបង្ហាញដោយសង្ខេបខាងលើនេះដែលមានលក្ខណៈខុសគ្នាបង្កើតបានជាមរតកវប្បធម៌តែមួយពិតប្រាកដ៕

**លោក លី ហាក់សេង**

អតីតអធិការបឋមសិក្សា (មន្ត្រីចូលនិវត្តន៍)

# យោបល់នឹងការពន្យល់ខ្លះៗ អំពីការកំណត់កាលបរិច្ឆេទ កាលនៃអក្សរសាស្ត្រខ្មែរ

ការស្រាវជ្រាវរកដើមកំណើតរឿង នាមអ្នកនិពន្ធរឿង ឬប្រភពរឿង ព្រមទាំងកាលបរិច្ឆេទនៃរឿងរ៉ាវផ្សេងៗ ខាងផ្នែកអក្សរសាស្ត្រខ្មែរយើង ក្នុងអតីតកាលនោះមិនមែនជាការងាយស្រួលឡើយ ទោះបីជារឿងដែលគេចារដាក់ស្លឹករឹតក្ដី ទោះបីគេកត់ត្រាទុកក្នុងក្រាំងឬសៀវភៅក្ដី យើងមិនសូវប្រទះឃើញឈ្មោះអ្នកនិពន្ធរឿង កាលបរិច្ឆេទនិងប្រវត្តិប្រាកដទេ គេច្រើនតែប្រទះឃើញឈ្មោះអ្នកកត់ត្រាចម្លង ឬអ្នកចារចម្លងទៅវិញ។

អ្នកកវីនិពន្ធក្ដី អ្នកនិពន្ធរឿងល្បែង (សាស្ត្រាល្បែងផ្សេងៗ) ក្ដី អ្នកនិពន្ធច្បាប់សីលធម៌ក្ដី អ្នកនិពន្ធរឿងផ្សេងៗទៀតក្ដី ក្នុងសម័យបុរាណតាមដោយស្មានមិនមែនជាអ្នកឥតគំនិតដល់ទៅភ្លេចដាក់ឈ្មោះខ្លួន ឬកាលបរិច្ឆេទភ្ជាប់ជាមួយនឹងរឿងនោះទេ។ ប្រសិនបើជូនជាភ្លេច ឬមិនចង់ដាក់ឈ្មោះខ្លួន កាលបរិច្ឆេទ ក្នុងរឿងនោះៗក៏គង់មានខ្លះដែរ ប៉ុន្តែប្រហែលជាមានភាគតិចទេ។

យើងយល់ថា អ្នកនិពន្ធជាន់ដើមមិនមែនជាអ្នកកំណាញ់ឈ្មោះ សករាជ ឬកាលបរិច្ឆេទទេ ប៉ុន្តែឈ្មោះសករាជ ឬកាលបរិច្ឆេទ រលាយបាត់សាបសូន្យទៅអំពីរឿងនោះៗ ដោយអ្នកចារចម្លងតៗគ្នាមក គឺ មានអ្នកចារចម្លងខ្លះ បានលុបឈ្មោះនិងកាលបរិច្ឆេទរបស់អ្នកនិពន្ធចេញទៅ ហើយដាក់ឈ្មោះខ្លួននិងសករាជនៅពេលចារចម្លងជំនួសវិញ។ អ្នកចារចម្លងលើកទីពីរតមកទៀតក៏ធ្វើតាមទំនងអ្នកមុនដែរ ហើយអ្នកចម្លង ឬសរសេរចម្លងតៗមកទៀត ក៏ប្រើវិធានការដូចគ្នាទៀត។ ម្ល៉ោះហើយរឿងចាស់ ទាំងអម្បាលម៉ាន ក៏ប្រែក្លាយទៅជារឿងទើបកើតជាន់ក្រោយអស់ទៅ។ បើជូនជាមានកែពាក្យពេចន៍ សំនួនវោហារ ឬអត្ថបទខ្លះផង នឹងធ្វើឲ្យរឿងនោះឃ្លាតឆ្ងាយអំពីច្បាប់ដើម កាន់តែច្រើនណាស់ទៅទៀត (ត្រង់នេះយើងសូមអភ័យទោសចំពោះអ្នកចារចម្លងដោយសុទ្ធចិត្តឥតចេតនាក្លែងបំបាត់នាមអ្នកនិពន្ធនិងកាលបរិច្ឆេទរបស់គេ)។

មានកវីនិពន្ធខ្លះនៅចុងសតវត្សរ៍ទី ១៩នៃគ្រិស្តសករាជលោកអស់នោះមានមធ្យោបាយការពារទុក នូវកេរ្តិ៍ឈ្មោះ កាលបរិច្ឆេទ ជីវប្រវត្តិរបស់លោកក្នុងអត្ថបទផ្ដើមរឿង ឬអត្ថបទបញ្ចប់រឿង។

រឿងណាមួយដែលអ្នកកវីនិពន្ធបានធ្វើទុកដូច្នេះ ទើបមាននាមអ្នកកវីនិពន្ធ និងកាលបរិច្ឆេទជាប់នៅក្នុងរឿងនោះ រហូតមកដល់សព្វថ្ងៃនេះ។

ឧទាហរណ៍៖ រឿងភោគកុលកុមាររបស់ឧកញ៉ាព្រះឃ្លាំង (**នង**), លោកន័យជាតករបស់ឧកញ៉ាវង្សាក្សត្រី (**នង**), ក្រុងសុភមិត្ររបស់ឧកញ៉ាកោសាធិបតី (**កៅ**),វរនុជវរនេត្រ របស់ឧកញ៉ាថៅហ្វាយឃ្លាំង (**មៀច**), រឿងកាកីព្រះរាជនិពន្ធព្រះបាទ **អង្គ ឌួង** ។ល។

ចំពោះរឿង **កាកី** សម្ដេចព្រះហរិរក្សរាមាឥស្សរាធិបតីព្រះបាទ **អង្គ ឌួង** ទ្រង់បាននិពន្ធព្រះរាជារម្ភកថារបស់ព្រះអង្គទុកក្នុងអត្ថបទផ្ដើមរឿងកាកី ដោយទ្រង់បានបញ្ជាក់សករាជទុកដល់

៣យ៉ាង គឺពុទ្ធសករាជ មហាសករាជនិងចុល្លសករាជទាំងថ្ងៃខែ ឆ្នាំពេលម៉ោងដែលទ្រង់បានចាប់ផ្ដើមនិពន្ធរឿងនេះ។ ក្រៅអំពីនេះទ្រង់បានបញ្ជាក់ទីកន្លែង និងប្រភពនៃរឿងនេះផង។

អ្នកកវីនិពន្ធខ្លះ ប្រើវិធីបញ្ជាក់កាលបរិច្ឆេទជាពាក្យបាលី-សំស្ក្រឹត-ខ្មែរលាយចម្រុះគ្នាក៏មាន ដូចអត្ថបទផ្ដើមរឿងក្នុងលោកន័យជាតកថាៈ សករាជចូលមក ឯកស័ប្តឯកឆ ស័កខាលចំហុត ប្រាំដណ្ដប់រោច រនោចពារពុធ ខែភទ្របទ(១) ស័កសម្រឹទ្ធី។ ត្រង់ពាក្យ "សករាជ" គឺមហាសករាជ។ "ឯកស័ប្តឯកឆ" គឺឯកៈ ១ ស័ប្តៈ ៧ ឯកៈ ១ ឆៈ ៦=១៧១៦។ "ស័កខាលចំហុត ប្រាំដណ្ដប់រោច រនោចពារពុធ ខែភទ្របទ ស័កសម្រឹទ្ធី"។ (គឺថ្ងៃពុធ ១៥រោច ខែភទ្របទ ឆ្នាំខាល សម្រឹទ្ធិស័ក)។

អ្នកកវីនិពន្ធខ្លះប្រើវិធីបញ្ជាក់កាលបរិច្ឆេទជាពាក្យបាលីសំស្ក្រឹតស្ទើរតែទាំងអស់ក៏មាន ដូចក្នុងអត្ថបទផ្ដើមរឿងនៃរឿងភោគកុលកុមារថា="មហាសករាជរាប់ ចូលជាឯកស័ប្ត-ទោឆសកា ជូតចូលវស្សន្ត សាវណែមាសា ភុម្មពារា បុណ្ណមិយំ។ នាមោមយា នងនាមជាតិជា ឧកញ៉ាព្រះឃ្លាំង គន់គិតកាព្យកិច្ច ពាក្យពេចន៍ទុកតាំង ជាកេរ្តិ៍តំណាំង តំណាសាស្នា។ ,,(ត្រង់ពាក្យ="ឯក ស័ប្ត ទោឆ សកា,,=មហាសករាជ ១៧២៦។ <<ជូតចូលវស្សន្ត សាវណែមាសា ភុម្មពារា បុណ្ណ មិយំ>>=គឺថ្ងៃអង្គារ ១៥ កើត ខែស្រាពណ៍ ឆ្នាំជូតក្នុងវស្សានរដូវ។ <<នាមោមយា>> នាមរបស់ខ្ញុំ..។

ប្រសិនបើយើងស្រាវជ្រាវពិនិត្យមើលដល់ទៅសិលាចារឹកទាំងឡាយតទៅទៀត នឹងឃើញថាស្ទើរតែគ្រប់ផ្ទាំងសិលាចារឹក ច្រើនតែឃើញមានបញ្ជាក់សករាជ ឬកាលបរិច្ឆេទដែលគេបានចាប់ផ្ដើមឆ្លាក់ចារឹក លើផ្ទាំងសិលានោះៗ ដូចសិលាចារឹកភាសាខ្មែរលេខ ៤ បន្ទាត់ ទី ៤-៥ (ក្រុមសិលាចារឹកនគរវត្ត)= "សុភមស្តុ ១៤៨៨ សកខាលអ្នកក្សត្របុរមី (៥) កេតខេហមាគិសីរ ព្រហស្បតិ៍ពារមន្តិ ... >>។ (សុភមស្តុសករាជ ១៤៨៨ ឆ្នាំ ខាល ១៥ កើតខែមិគសិរ ថ្ងៃព្រហស្បតិ៍ នេះ គឺ...)។

សិលាចារឹកលេខ២ បន្ទាត់ទី ១០-១១(ក្រុមសិលាចារឹកនគរវត្ត) = «មន្តិលុះត ១៥៩៩ ឆ្លូន-ក្សត្រ (១១) ចតុទ្ទិតិកេតអាសាឍ្យសោរពារ ខ្ញុំអំចស្បយល...»។ (នេះគឺលុះដល់សករាជ ១៥៩៩ ឆ្នាំឆ្លូវ ១៤កើតខែអាសាឍ ថ្ងៃសៅរ៍ខ្ញុំអម្ចាស់យល់...)។

គប្បីជ្រាបថា របៀបប្រើសករាជទូទៅតាមផ្លូវការក្នុងសម័យបុរាណនោះ គេនិយមប្រើតែមហាសករាជមួយប៉ុណ្ណោះ។ ឯមហាសករាជនោះកើតក្រោយគ្រិស្តសករាជ ៧៨ឆ្នាំ ដូច្នេះបើយើងចង់ដឹងជាគ្រិស្តសករាជវិញត្រូវបន្ថែម ៧៨ឆ្នាំ លើមហាសករាជនោះ នឹងបានជ្រាបជាគ្រិស្តសក-រាជប៉ុន្មានៗតាមចំណង់។

ឯរឿងណាមួយ ដែលអ្នកនិពន្ធមិនបានប្រើមធ្យោបាយរក្សាទុកនូវកេរ្តិ៍ឈ្មោះកាលបរិច្ឆេទរបស់ខ្លួន នៅខាងដើមអត្ថបទឬខាងចុងអត្ថបទរបស់ខ្លួនទេ មុខជារកនាមនិងកាលបរិច្ឆេទរបស់អ្នកនិពន្ធ ដែលបានផ្ដើមនិពន្ធរឿងនោះ ពុំឃើញឡើយដូចច្បាប់ផ្សេងៗ ច្បាប់ក្រម កេរកាល កូនចៅ ហៃមហាជន ច្បាប់ប្រុស-ស្រី...) រឿងព្រេងផ្សេងៗ(អាឡេវ អាធុង អាសាញ់ សុភាទន្សាយ ធនញ្ជ័យ...) ក្នុងចំណោមអក្សរសាស្ត្រខាងផ្នែកសាសនាក៏ច្រើន តែមានទំនងដូច្នេះដែរ ដូចជារឿងទសជាតក បឋមសម្ពោធិ រឿងជាតកផ្សេងៗ អានិសង្សផ្សេងៗជាដើម។ គេមិនសូវប្រទះឃើញនាមនិងកាលបរិច្ឆេទរបស់អ្នកនិពន្ធមុនដំបូងបង្អស់នោះសោះ។

នៅទីបំផុតខ្ញុំសូមជម្រាបថា ការបាត់លំដាប់ប្រវត្តិកាលនៃផ្នែកអក្សរសាស្ត្រខ្មែរនេះ ខ្ញុំបានរៀបចំធ្វើដោយបន្ទាន់ប្រញាប់យកទៅបោះពុម្ពផ្សាយក្នុងទស្សនាវដ្តី នៃវិទ្យាស្ថានជាតិគរុកោសល្យឲ្យបានទាន់ពេលវេលា។ ប៉ុន្តែនៅឱកាសជាលំដាប់តៗទៅខ្ញុំនឹងខំប្រឹងស្រាវជ្រាវពិនិត្យរៀបចំ ឬកែប្រែឲ្យសមរម្យទៅតាមកាលៈទេសៈ។ ដូច្នេះតារាងប្រវត្តិកាលនៃអក្សរសាស្ត្រខ្មែរនេះគង់នៅមានតក់ឆ្គង ឬភ្លាំងភ្លាត់ខ្វះខាតខ្លះជាមិនខានដែលខ្ញុំសូមទទួលយកនូវសេចក្តីពន្យល់បំភ្លឺដ៏សមហេតុផល អំពីសំណាក់អ្នកអានទាំងឡាយដោយក្តីគោរពដ៏ខ្ពង់ខ្ពស់។

ខ្ញុំសូមថ្លែងអំណរអរគុណចំពោះអស់លោកទុកជាមុន៕

**ញ៉ុក ថែម**

មជ្ឈដ្ឋានផ្នែកស្រាវជ្រាវនៅវិទ្យាស្ថានជាតិគរុកោសល្យ

## អាំម្លែងទេ?

ខ្ញុំមានមិត្តម្នាក់ ជាសាស្ត្រាចារ្យទើបនឹងចេញពីវិទ្យាស្ថានជាតិដូចគ្នា ដែលមានទេពកោសល្យម៉្យាង ខាងមិន "ធ្វើអ្វីធ្វើឲ្យហើយ កុំទុកឡើយ..." ។ សូម្បីតែក្នុងការពន្យល់ក៏គេមិនបញ្ចប់ប្រយោគគេដែរ គេទុកឲ្យសិស្សណាមានចិត្ត"ជួយធ្វើការសហប្រតិបត្តិការ" នឹងគេចុះ!

ខ្ញុំក៏មិនហ៊ានយល់ថា តើគេជាអ្នកខ្ជិល ឬក៏ជាអ្នកមានល្បិចមាន"ការសម្ងាត់" ក្នុងវិធីពន្យល់ដែរ...ពីព្រោះមានអ្នក"គរុកោសល្យ" ខ្លះអះអាងថា វិធីនេះធ្វើឲ្យថ្នាក់មានជីវិត"ខ្លះនិយមថា ធ្វើថ្នាក់" មិនឲ្យស្លាប់"ខ្លះទៀតថាធ្វើថ្នាក់" មិនឲ្យត្រជាក់" ថានាំឲ្យសិស្សប្រុងប្រយ័ត្នតាមគំនិតរបស់សាស្ត្រាចារ្យ ថាជួយសិស្សខ្សោយឲ្យទាន់គេ ថា...ថា...ចេះតែថាទៅ...!

ប៉ុន្តែ........ប៉ុន្តែ មានថ្ងៃមួយនោះ ខ្ញុំមានភ័ព្វវាសនា នឹងបានទៅបង្រៀនជាប់នឹងថ្នាក់របស់ "អ្នកមានគរុកោសល្យ" ហើយស្រាប់តែភ្ញាក់ព្រើតនឹងសំឡេងគឹលៗ ព្រមៗគ្នានៃសិស្សថ្នាក់គេ។

ខ្ញុំក៏ផ្ទៀងស្តាប់:

គ្រូ៖ ហើយភ្លៀវទាំងឡាយ ក៏ឡើងយន្តហោះប្រតិ...

សិស្ស៖ (គឹលព្រមៗគ្នា) ...កិរិយា!

ខ្ញុំលបមើលទឹកមុខរបស់គ្រូ ឃើញស្មឿក!

**អរកោស**

**ទស្សនាវដ្តី សាស្ត្រាចារ្យ ឆ្នាំទី៥ លេខ ៨ (១៩៦២)**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សមាគមបុគ្គលិកសិក្សាខ្មែរ**
**គណៈកម្មាធិការកណ្ដាល**
**លេខ: ០៤/១៨ គ.ក**

**សេចក្ដីជូនដំណឹងមរណភាពប្រចាំខែ កុម្ភៈ ឆ្នាំ២០១៨**
**តាងនាមសមាគមបុគ្គលិកសិក្សាខ្មែរទាំងមូលគណៈកម្មាធិការកណ្ដាលនៃ ស.ប.ស.ខ.**
**សូមសម្ដែងក្ដីសោកស្ដាយជាទីបំផុតចំពោះការបាត់បង់ជីវិតនៃមិត្តយើង និងគ្រួសារ**
**ហើយសូមចូលរួមរំលែកទុក្ខមរណសញ្ញាជាមួយគ្រួសារនៃសពទាំងនោះ**

| ល.រ | គោត្តនាម-នាម | អាយុ | ភេទ | ក្របខ័ណ្ឌ | អង្គភាពបម្រើការងារ | ថ្ងៃខែឆ្នាំមរណៈ | មូលហេតុ | លេខប័ណ្ណ | សពទី |
|---|---|---|---|---|---|---|---|---|---|
| | | | | | ក.មរណភាពសមាជិក | | | | |
| 1 | វ៉ិត វុទ្ធា | ៤៩ | ប | មធ្យមប.ភូមិ | វិទ្យាល័យ ទួលស្វាយព្រៃ រាជធានីភ្នំពេញ | 08.12.17 | គ្រិនថ្លើម | 5683 ភព | 12403 |
| 2 | ហេង ហ្គេចយូ | ៤៥ | ស | បឋមសិក្សា | បឋម សិក្សា ព្រែកលៀប រាជធានីភ្នំពេញ | 11.12.17 | លើសឈាម | 4166 ភព | 12404 |
| 3 | ពាង ផង់ | ៦៦ | ស | និវត្តជន | វិទ្យាល័យ ព្រះស៊ីសុវត្ថិ រាជធានីភ្នំពេញ | 04.12.17 | លើសឈាម | 14819 ភព | 12405 |
| 4 | ឈុំ ឆោម | ៦៣ | ប | និវត្តជន | សាលាបឋម សិក្សា ហស ឬស្សីសាញ់ ភ្នំពេញ | 13.12.17 | លើសឈាម | 633 ភព | 12406 |
| 5 | កាំង ប៊ុនរី | ៦៥ | ប | បឋម | និវត្តជន បឋម.ព្រះក្រសាំង ស្រុកកំពង់ ស្វាយកំង់ធំ | 10.01.17 | ជរាពាធ | 1863 កធ | 12407 |
| 6 | ញ៉ក់ ស៊ីប | ៤៧ | ប | បឋម | បឋមសិក្សា ទីពោ ស្រុក សន្ទុក ខេត្ត កំពង់ធំ | 20.07.17 | ជរាពាធ | 3151 កធ | 12408 |
| 7 | កៅ យ៉ិន | ៦៨ | ប | បឋម | និវត្តជន បឋម.មាសគង់ ស្រុកបារាយណ៍ កំពង់ធំ | 15.07.17 | ជរាពាធ | 1267 កធ | 12409 |
| 8 | គុជ សំអុល | ៥២ | ប | បភម | ការិ.អប់រំ យុវជននិងកីឡា ក្រុងស្ទឹងសែន កំពង់ធំ | 22.06.17 | គ្រោះចរាចរ | 3206 កធ | 12410 |
| 9 | គីម សារ៉េត | ៦២ | ប | មធ្យម កំ.១ | និវត្តជន ស្រុករមាសហែក ខេត្ត ស្វាយរៀង | 16.11.17 | តាំងបេះដូង | 1039 ស្វរ | 12411 |
| 10 | ព្រុំ ម៉ុក | ៧១ | ប | កម្រិតបឋម | និវត្តជន ស្រុកកំពង់រោទិ៍ ខេត្ត ស្វាយរៀង | 27.10.17 | បុសក្រពើ | 2792 ស្វរ | 21412 |
| 11 | ភោគ វណ្ណា | ៥៧ | ប | កម្រិតបឋម | បឋមក្រោលគោ ស្រុកស្វាយជ្រំ ខេត្ត ស្វាយរៀង | 01.12.17 | លើសឈាម | 356 ស្វរ | 12413 |
| 12 | យោក យ៉ុត | ៥៤ | ស | កម្រិតបឋម | បឋមក្រោលគោ ស្រុកស្វាយជ្រំ ខេត្ត ស្វាយរៀង | 03.12.17 | រលាកក្រពះ | 340 ស្វរ | 12414 |
| 13 | គួយ ជិន | ៨០ | ប | បឋម | និវត្តជន បឋមសំរោងបុរី ស្រុកត្បូងឃ្មុំ ត្បូងឃ្មុំ | 14.10.17 | ជរាពាធ | 045 តឃ | 12415 |
| 14 | ស៊ាង ស្រឿន | ៦០ | ប | បឋម | និ.វ បឋម រកាពប្រាំ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ | 18.10.17 | ជរាពាធ | 461 តឃ | 12416 |
| 15 | ហែម ស្រេង | ៦៨ | ប | បឋម | និ.វ បឋម សង្គមមានជ័យ ស្រុកក្រូចឆ្មារ ត្បូងឃ្មុំ | 11.11.17 | ជរាពាធ | 2436 តឃ | 12417 |
| 16 | ហុង សារិន | ៧១ | ប | បឋម | និ.វ បឋមប្រជាកុមារសួង ក្រុងសួង ខេត្តត្បូងឃ្មុំ | 07.11.17 | ជរាពាធ | 1478 តឃ | 12418 |
| 17 | អ៊ី យឿន | ៧០ | ប | កំ.មូលដ្ឋាន | និ.វ វិទ្យាល័យទន្លេបិទ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ | 18.11.17 | ជរាពាធ | 10282 តឃ | 12419 |
| 18 | ដួង មៀន | ៦៧ | ប | បឋម | និ. បឋមសិក្សាទ្រា ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង | 07.11.17 | គ្រិនថ្លើម | 1926 កឆ | 12420 |
| 19 | ប្រាក់ ណុំ | ៧២ | ប | បឋម | និ. បឋមសិក្សាស្វាយជ្រុំ ស្រុករលាប្អៀរ កំពង់ឆ្នាំង | 15.12.17 | ស្ទះទឹកនោម | 1936 កឆ | 12421 |
| 20 | តាន់ នីសៀង | ៦១ | ប | មធ្យម | និ.មន្ទីរ អយកខេត្ត ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង | 01.01.18 | ឡើងឈាម | 048 កឆ | 12422 |
| 21 | លឹម សុវណ្ណនី | ៦៣ | ស | បឋម | និ. បឋមសិក្សាកំរូក្រុង ក្រុងកំពង់ឆ្នាំង កំពង់ឆ្នាំង | 28.12.17 | គ្រោះ ចរាចរ | 1430 កឆ | 12423 |
| 22 | ម៉ាត់ ទីន | ៤៥ | ប | មធ្យម | វិ. អាពូប៉ាកើរឥស្លាមកម្ពុជា ស្រុកកំពង់ត្រឡាច កំពងឆ្នាំង | 23.12.17 | កកឈាមខួរក្បាល | 5475 កឆ | 12424 |
| 23 | ឡឹក គី | ៧៧ | ស | អ្នកជាំបាយ | និ. សាលាគរុកោសល្យ និងវិក្រឹតការ កំពង់ឆ្នាំង | 17.10.17 | របេងសួត | 163 កឆ | 12425 |
| 24 | មាស ស៊ីម | ៦៤ | ប | មធ្យម | និ. វិ ហ៊ុន សែន រលាប្អៀរ ស្រុករលាប្អៀរ កំពង់ឆ្នាំង | 05.11.17 | ទឹកនោមផ្អែម | 1975 កឆ | 12426 |
| 25 | គុយ ឡេច | ៦៣ | ស | មធ្យម | និ. ហ៊ុន សែន កំពង់ត្រឡាចស្រុកកំពង់ត្រឡាច កំពង់ឆ្នាំង | 15.10.17 | មហារីកសួត | 0799 កឆ | 12427 |
